

របាយការណ៍

ការស្វែងយល់អំពីចរាចរណ៍នៃការត្រួតពិនិត្យផលិតផលឈើ នៅកម្ពុជា សម្រាប់ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្មឈើ (FLEGT)

This report was jointly prepared by Global Forestry Services, the Forestry Administration of Cambodia and the EU FLEGT Facility, 2014



បញ្ជីតារាង

តារាង ១ ប្រភេទការប្រើប្រាស់ដី 1

តារាង ២ ស្ថិតិឆ្នាំ២០១០របស់រដ្ឋបាលព្រៃឈើស្តីពីប្រភេទព្រៃ (រដ្ឋបាលព្រៃឈើ ២០១២) 28

តារាង ៣ ចំណាត់ថ្នាក់ការប្រើប្រាស់ដីបច្ចុប្បន្ន (យោងតាមកម្មវិធីព្រៃឈើជាតិ) ការទទួលខុសត្រូវរបស់ក្រសួង ប្រភេទការប្រើប្រាស់ដី និងទំហំដីប្រហាក់ប្រហែល (ហិកតា) (រាជរដ្ឋាភិបាលកម្ពុជា ២០១០) 31

តារាង ៤ តំបន់ការពារធម្មជាតិតាមប្រភេទនៃការគ្រប់គ្រង (ក្រសួងបរិស្ថាន ២០១១) 33

តារាង ៥ តំបន់ព្រៃការពារតាមបណ្តាខេត្ត (រាជរដ្ឋាភិបាលកម្ពុជា ២០១២) 34

តារាង ៦ សហគមន៍ព្រៃឈើតាមបណ្តាខេត្ត 36

តារាង ៧ ព្រៃសម្បទាន(ឯកជន) 37

តារាង ៨ តំបន់ចម្ការឈើ (ស្ថានីយ៍) គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ 39

តារាង ៩ អាជ្ញាប័ណ្ណព្រៃគុបនៅក្នុងព្រៃផ្តល់ផល 43

តារាង ១០ បញ្ជីតំបន់ដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តមណ្ឌលគិរី (យោងតាមប្រភពព័ត៌មានពីខណ្ឌរដ្ឋបាលព្រៃឈើ មណ្ឌលគិរី និងគេហទំព័រ Open Development) 47

តារាង ១១ មាឌឈើមូលផលិតចេញពីដីសម្បទានសេដ្ឋកិច្ច ផ្អែកតាមទិន្នន័យលិខិតបើកផ្លូវ ដឹកជញ្ជូនផល-អនុផលព្រៃឈើ របស់រដ្ឋបាលព្រៃឈើ 51

តារាង ១២ ផលិតកម្មឈើពីតំបន់សម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ ២០១១ និង ២០១២ តាមបណ្តាខេត្ត 52

តារាង ១៣ បញ្ជីឈ្មោះតំបន់អាជីវកម្ម២ និងបរិមាណផលិតផលឈើមូល ឆ្នាំ២០១១ និង ២០១២ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ 55

តារាង ១៤ បរិមាណឈើពីគម្រោងទំនប់វារីអគ្គិសនី (របាយការណ៍ប្រចាំឆ្នាំ២០១១ និង ២០១២ របស់រដ្ឋបាលព្រៃឈើ) 57

តារាង ១៥ ឈើនាំចូលពី២០០៧-១២ នៅក្នុងស្ថិតិព្រៃឈើកម្ពុជា ២០១១ (រដ្ឋបាលព្រៃឈើ ២០១២) 62

តារាង ១៦ ចំនួនរោងកែច្នៃឈើដែលមានសុពលភាពតាមខេត្ត ស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង បរិមាណផលិតផលនាំចេញឆ្នាំ ២០១២ (នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ) 71

តារាង ១៧ សង្ខេបទិន្នន័យស្តីពីបរិមាណផលិតផលឈើ (ម^{3}) នាំចេញ និងឈើចំណាំង (តោន) ឆ្នាំ ២០០៣ ដល់ ២០១២ (រដ្ឋបាលព្រៃឈើ ២០១២) 76

តារាង ១៨ ផលិតផលឈើនាំចេញក្នុងតំបន់ (ម^{3}) ក្នុងឆ្នាំ ២០១១ (រដ្ឋបាលព្រៃឈើ ២០១២) 77

តារាង ១៩ កំណត់ត្រាឈើរឹបអូស ឆ្នាំ ២០០៨ - ២០១២ (នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ ២០១៣) 90

តារាង ២០ កំណត់ត្រាសង្ខេបអំពីការផ្តត់ផ្តង់ និងចរាចរឈើនៅកម្ពុជា 93

បញ្ជីរូបភាព

រូបទី ១ ផែនទី អធិការដ្ឋាន ខណ្ឌ និងផ្នែករដ្ឋបាលព្រៃឈើក្នុងប្រទេសកម្ពុជា (រដ្ឋបាលព្រៃឈើ ២០១២) 21

រូបទី ២ ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ (រដ្ឋបាលព្រៃឈើ ២០១២) 28

រូបទី ៣ ផែនទីចំណាត់ថ្នាក់ការប្រើប្រាស់ដីនិងព្រៃឈើក្នុងប្រទេសកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០១២) 31

រូបទី ៤ ផែនទីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៣ (Open Development Cambodia 2013 shape files) 48

រូបទី ៥ ឧទាហរណ៍អំពីផែនទីប្រើប្រាស់ដីក្នុងផែនការមេរបស់ក្រុមហ៊ុន COVIPHAMA CO.,LTD 49

រូបទី ៦ ផែនទីតំបន់សម្បទានរ៉ែ (ប្រភព Open Development Cambodia ២០១៣) 56

រូបទី ៧ ផែនទីគម្រោងវារីអគ្គិសនី (ប្រភព Open Development ២០១៣) 59

រូបទី ៨ ឧទាហរណ៍នៃលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើចេញពីព្រៃផ្តល់ផលក្រៅដែនព្រៃសម្បទាន(លេខ ១៤២ រព.ក.ក/LP/B) ដែលបានប្រើប្រាស់ដោយរដ្ឋបាលព្រៃឈើ 66

រូបទី ៩ ឧទាហរណ៍លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ លេខ ២៩៥ ផរព.លដជ ..... របស់រដ្ឋបាលព្រៃឈើ 67

រូបទី ១០ ឧទាហរណ៍ស្តីពីលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ៖ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផល ព្រៃឈើ-២ លេខ ៩៧ ផរព.លដជ ដែលចេញដោយផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង 73

រូបទី ១១ ចំណុចប៉ុស្ត៍ត្រួតពិនិត្យសំខាន់ៗរបស់គយ (យោងតាមរាជរដ្ឋាភិបាលកម្ពុជា ២០០១) 75

រូបទី ១២ គំរូផ្ទត់ផ្ទង់ឈើនៅក្នុងប្រទេសកម្ពុជា 80

អក្សរកាត់

Camcontrol	អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញអាហ៍រណ នីហ៍រណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) (Cambodia Import-Export Inspection and Fraud Repression Directorate General)
CoC	ខ្សែសង្វាក់ផលិតកម្ម (Chain of custody)
DFI	នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ (Department of Forest Industry and International Cooperation)
DLE	នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ (Department of Legislation and Law Enforcement)
ELC	សម្បទានដីសេដ្ឋកិច្ច (Economic Land Concession)
ESIA	ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម (Environmental and Social Impact Assessment)
FAO	អង្គការស្បៀងអាហារនិងកសិកម្ម របស់អង្គការសហប្រជាជាតិ (Food and Agriculture Organization of the United Nations)
FLEGT	ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្មឈើ (Forest Law Enforcement, Governance and Trade)
GDCE	អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (General Department of Customs and Excise of Cambodia)
ITTO	អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក (International Tropical Timber Organization)
IUCN	អង្គការអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (International Union for the Conservation of Nature)
MAFF	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture Forestry and Fisheries)
MOC	ក្រសួងពាណិជ្ជកម្ម (Ministry of Commerce)
MEF	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance)
NFP	កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩ (National Forestry Programme 2010-2029)
NTFP	អនុផលព្រៃឈើ (Non-Timber Forest Products)
PFE	សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ (Permanent Forest Estate)
RGC	រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia)
VPA	កិច្ចព្រមព្រៀងភាពជាដៃគូស្ម័គ្រចិត្ត (Voluntary Partnership Agreement)
TLAS	ប្រព័ន្ធធានាភាពស្របច្បាប់របស់ផលិតផលឈើ (Timber Legality Assurance System)

ប្រភេទលិខិតអនុញ្ញាតដឹកជញ្ជូន

LP	លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតនេះផ្តល់ដោយរដ្ឋបាលព្រៃឈើ។
PC	លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតនេះផ្តល់ដោយផ្នែករដ្ឋបាលព្រៃឈើ
PC-1	លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១
PC-2	លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២
PC-IMEX	លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូល-នាំចេញ
Loglists = Log Book A	បញ្ជីឈើមូល = បញ្ជីផល-អនុផលព្រៃឈើ

មាតិកា

សេចក្តីសង្ខេប 1

១. សាវតាគម្រោង 9

១.១ គោលបំណងនៃការសិក្សា 10

១.២ វិធីសាស្ត្រ និងបណ្តាសកម្មភាពសំខាន់ៗ 10

១.៣ ក្រុមការងារសិក្សា 10

២. វិធីសាស្ត្រនៃការសិក្សា 11

២.១ ការចាប់ផ្តើមការសិក្សា 11

២.២ ការប្រមូលទិន្នន័យ 12

៣. តួនាទីរបស់អង្គភាពរាជរដ្ឋាភិបាល 16

៣.១ មូលដ្ឋានច្បាប់(បទប្បញ្ញត្តិ) 16

៣.២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ 19

៣.៣ ក្រសួងបរិស្ថាន 24

៣.៤ ក្រសួងពាណិជ្ជកម្ម 25

៣.៥ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា 26

៤. ព្រៃឈើកម្ពុជា 27

៤.១ គម្របព្រៃឈើ និងប្រភេទព្រៃឈើ 27

៤.២ ប្រភេទនៃការប្រើប្រាស់ដីព្រៃ 30

៤.៣ ព្រៃឯកជន/ចម្ការឈើ 38

៥. ការផ្តត់ផ្គង់ឈើ 41

៥.១ ព្រៃសម្បទាន 42

៥.២ ព្រៃផ្តល់ផល-តំបន់ព្រៃគុប 42

៥.៣ សម្បទានដីសេដ្ឋកិច្ច - ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ 43

៥.៤ សហគមន៍ព្រៃឈើ 54

៥.៥ ចម្ការឈើ និង ដីឯកជន 54

៥.៦ គម្រោងអាជីវកម្ម៖ 54

៥.៧ ទំនប់វារីអគ្គិសនី 56

៦. ឈើនាំចូល 60

៦.១ ប្រព័ន្ធសម្រាប់ការនាំឈើចូល 60

៦.២ ទិន្នន័យនៃការនាំឈើចូល 61

៧. ការដឹកជញ្ជូន និងការលក់ដូរឈើមូលក្នុងស្រុក 64

៧.១ ការពិពណ៌នាអំពីបទប្បញ្ញត្តិក្នុងការប្រមូលផលឈើ និងការដឹកជញ្ជូនឈើមូល 64

៨. ផលិតកម្មឈើ និងការនាំចេញ 70

៨.១ រោងចក្រកែច្នៃ និងទិន្នន័យផលិតកម្មឈើ 70

៨.២ ផលិតកម្មរោងចក្រកែច្នៃ និងការដឹកជញ្ជូនផលិតផល 71

៨.៣ ប្រព័ន្ធ/ដំណើរការសម្រាប់ការនាំឈើចេញ 74

៨.៤ ស្ថិតិនាំចេញ 75

៩. គំរូនៃការផ្គត់ផ្គង់ឈើ 79

៩.១ រចនាសម្ព័ន្ធនៃការផ្គត់ផ្គង់និងចរាចរឈើ 79

៩.២ ការពិពណ៌នាអំពីចរាចរឈើ និងការនាំចេញ 81

១០. ប្រព័ន្ធតាមដានត្រួតពិនិត្យ 86

១០.១ ការពិពណ៌នាអំពីប្រព័ន្ធតាមដានត្រួតពិនិត្យ 87

១០.២ ឈើរឹបអូស 88

១១. ការពិភាក្សា និង ការផ្តល់អនុសាសន៍ 91

១១.១ ប្រភពធនធាន 91

១១.២ ការផ្គត់ផ្គង់ឈើ 92

១១.៣ ការដឹកជញ្ជូនឈើ និង ការលក់ដូរ 95

១១.៤ ផលិតកម្មក្នុងស្រុក និងការនាំចេញ 96

១១.៥ ការតាមដានត្រួតពិនិត្យ 97

១១.៦ កិច្ចព្រមព្រៀងភាពជាដៃគូស្ម័គ្រចិត្ត 98

ឯកសារយោង 101

ឧបសម្ព័ន្ធ ១ ÷ លក្ខខណ្ឌការងារ 104

ឧបសម្ព័ន្ធ ២ ÷ កម្មវិធីចុះសិក្សានៅទីវាល 106

ឧបសម្ព័ន្ធ ៣ ÷ បញ្ជីតំបន់ដីសម្បទានសេដ្ឋកិច្ច និងផលិតកម្មឈើក្នុងឆ្នាំ ២០១១ និង ២០១២ 109

សេចក្តីសង្ខេប

គោលបំណងសំខាន់នៃការសិក្សានេះ គឺដើម្បីបង្កើនការយល់ដឹងអំពីចរាចរឈើនៅក្នុងប្រទេសកម្ពុជា និងដើម្បីយល់ដឹងអំពីតួនាទីរបស់អង្គភាពរាជរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ចាប់ផ្តើមពីតំបន់ព្រៃ ឬ ចំណុចនាំចូល/នាំចេញ រហូតដល់ការកែច្នៃ និងការធ្វើពាណិជ្ជកម្ម។ ការសិក្សានេះបានធ្វើការវិភាគអំពីបទដ្ឋានគតិយុត្ត និងនីតិវិធីដែលមានបច្ចុប្បន្ននៅកម្ពុជា ហើយកំណត់បណ្តាបញ្ហាចាំបាច់ដែលត្រូវដោះស្រាយ ដើម្បីធានាភាពស្របច្បាប់ក្នុងការផ្គត់ផ្គង់ឈើនៅកម្ពុជា។ ការសិក្សានេះ គឺផ្អែកលើមូលដ្ឋានទិន្នន័យដែលបានប្រមូលពីបណ្តាអង្គភាពរាជរដ្ឋាភិបាល និងការចុះដល់មូលដ្ឋាន នៅភ្នំពេញ ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តព្រះសីហនុ។

រាជរដ្ឋាភិបាលកម្ពុជាបានអោយដឹងថាប្រទេសកម្ពុជាមានព្រៃឈើចំនួន ១០,៨ លានហិកតា។ យោងតាមផែនទីគម្របព្រៃឈើ គឺមានព្រៃល្អោះចំនួន ២៥% ព្រៃស្រោង (មិនមែនប្រភេទស្លឹកម្ទុល)ចំនួន១៩% និងព្រៃពាក់កណ្តាលស្រោងចំនួន ៧%។ រាជរដ្ឋាភិបាលបានរៀបចំកម្មវិធីព្រៃឈើជាតិ ២០១០-២០២៩។ កម្មវិធីព្រៃឈើជាតិបានចាត់ថ្នាក់ព្រៃឈើចំនួន១០,៨លានហិកតាជា ៥ប្រភេទការប្រើប្រាស់ដី(មើលតារាង ១)។

តារាង ១ ប្រភេទការប្រើប្រាស់ដី

តំបន់	ផ្ទៃដី	គ្រប់គ្រងដោយ
តំបន់ការពារធម្មជាតិ	៣ លានហិកតា	ក្រសួងបរិស្ថាន
ព្រៃការពារ	៣ លានហិកតា	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហគមន៍ព្រៃឈើ	២ លានហិកតា	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ព្រៃសម្បទាន	០,៣ លានហិកតា	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ព្រៃផ្តល់ផល	២,៦ លានហិកតា	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អង្គភាពរាជរដ្ឋាភិបាលសំខាន់ៗដែលចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ មានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងបរិស្ថាន និងបណ្តាមន្ទីរ-ការិយាល័យតាមខេត្ត ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ព្រៃឈើ និងព្រៃផ្តល់ផល។ ក្រសួងពាណិជ្ជកម្ម រដ្ឋបាលព្រៃឈើ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) គឺចូលរួមក្នុងការផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ ការនាំចូល-នាំចេញ ផលិតផលឈើ។

កម្ពុជាបានចេញបទបញ្ជាផ្អាកការធ្វើអាជីវកម្មឈើក្នុងព្រៃសម្បទាននាខែមករា ឆ្នាំ២០០២ ដូច្នេះ ឈើស្ទើរតែទាំងអស់ គឺមានប្រភពមកពីការកាប់សម្អាតព្រៃនៅក្នុងសម្បទានដីសេដ្ឋកិច្ច ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ តំបន់ព្រៃផ្តល់ផលអាចផ្តល់អាជ្ញាប័ណ្ណជាព្រៃគុបប្រចាំឆ្នាំ និងអាចបង្កើតជាព្រៃសហគមន៍ផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅបង្កើតព្រៃសហគមន៍លើផ្ទៃដីព្រៃ ២លានហិកតា។ បច្ចុប្បន្ន ព្រៃសហគមន៍មានប្រហែល ២០០.០០០ ហិកតា បានចុះកិច្ចព្រមព្រៀង និងកំពុងរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍។

ប្រទេសកម្ពុជាមានប្រព័ន្ធបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រងការធ្វើអាជីវកម្មឈើនៅតំបន់ដែលមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឬក្រសួងបរិស្ថាន ដូចជា ការរៀបចំផែនការមេសម្រាប់សម្បទានដីសេដ្ឋកិច្ច សហគមន៍ព្រៃឈើ និងព្រៃគុប។ បញ្ជីផល-អនុផលព្រៃឈើអំពីឈើហុបទាំងអស់ដែលបានមកពីការកាប់ដកហូត ត្រូវបានរៀបចំឡើង ដើម្បីប្រើប្រាស់ក្នុងការទទួលបាននូវអាជ្ញាប័ណ្ណប្រមូលផល និងបង់ថ្លៃសួយសារនិងបុព្វលាភ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ (PC-1) សម្រាប់ដឹកឈើពីព្រៃទៅកាន់រោងចក្រកែច្នៃឈើស្របច្បាប់។ ដំណើរការផលិតកម្មកែច្នៃឈើក្នុងរោងចក្រកែច្នៃឈើ គឺមិនមានការគ្រប់គ្រងហ្មត់ចត់ទេ ហើយក៏មិនតម្រូវឱ្យរាយការណ៍ជាផ្លូវការជូនរដ្ឋបាលព្រៃឈើ ឬក្រសួងបរិស្ថាន អំពីឈើមូលចូលនិងផលិតផលឈើកែច្នៃដែរ។ ក្នុងឆ្នាំ ២០១៤នេះ រដ្ឋបាលព្រៃឈើមានផែនការបង្កើតប្រព័ន្ធកត់ត្រាឈើចូល-ឈើចេញ ប្រចាំថ្ងៃសម្រាប់រោងចក្រកែច្នៃឈើទាំងអស់។ រោងចក្រកែច្នៃឈើដែលផលិតឈើអារត្រូវតែមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដើម្បីដឹកជញ្ជូនឈើ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ដើម្បីនាំចូលឬនាំចេញផលិតផលឈើ។ រដ្ឋបាលព្រៃឈើធ្វើការកត់ត្រាផលិតផលឈើមូលដែលដកហូតចេញពីព្រៃទាំងអស់ តាមរយៈបញ្ជីផល-អនុផលព្រៃឈើ និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ប្រើសម្រាប់កំណត់យថាប្រភេទវត្ថុធាតុដើម(ឈើមូល) ដែលត្រូវដឹកជញ្ជូនពីព្រៃមកកាន់រោងចក្រកែច្នៃឈើ។ រដ្ឋបាលព្រៃឈើក៏ប្រមូលព័ត៌មានផងដែរ អំពីផលិតផលឈើដែលដឹកជញ្ជូនទៅកាន់ទីផ្សារក្នុងស្រុកតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ហើយក៏ដូចជាផលិតផលឈើនាំចេញតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផល ព្រៃឈើ នាំចេញ-នាំចូល។ កន្លងមកនេះ រដ្ឋបាលព្រៃឈើមិនអាចផ្តល់ទិន្នន័យអំពីផលិតផលឈើចេញពីរោងចក្រកែច្នៃឈើតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដល់ក្រុមការងារសិក្សាឡើយ ដោយសារតែឯកសារទាំងនេះគឺចេញដោយរដ្ឋបាលព្រៃឈើនៅមូលដ្ឋាន។

ជាទូទៅទិន្នន័យ និងកំណត់ត្រាដែលមានស្រាប់ គឺមានភាពមិនស៊ីសង្វាក់គ្នាទេ ដូចជាទិន្នន័យអំពីការប្រើប្រាស់ដី និងការគ្រប់គ្រងតំបន់ព្រៃឈើក្នុងប្រទេសកម្ពុជា។ ព្រៃផ្តល់ផលដែលមានផ្ទៃដី សរុប១,២ លានហិកតា គឺមិនទាន់បានកំណត់ឱ្យបានច្បាស់នៅតាមបណ្តាខេត្តនៅឡើយ ក៏ដូចជាកំណត់ក្នុងផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែរ។ តំបន់សម្បទានដីសេដ្ឋកិច្ចក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន មិនមានបញ្ជីជាផ្លូវការ ឬផែនទីដែលគូរដោយក្រសួងទាំងនោះទេ។ រដ្ឋបាលព្រៃឈើមានស្តានីយ៍ដាំឈើមួយចំនួនដែលមានទំហំ ៩៦.០០០ ហិកតា ដែលស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែល

ក្នុងនោះ បានដាំឈើរួច បានចំនួន ១៤.០០០ហិកតា។ ក្រសួងបរិស្ថាន គ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយបានកំណត់ជា តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ ក៏ប៉ុន្តែ ការបែងចែកតំបន់ទាំងនេះក្នុងតំបន់ការពារធម្មជាតិមិនទាន់បានកំណត់ចប់សព្វគ្រប់នៅឡើយ ដូចជា តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដែលជាតំបន់អាចប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ឈើ។

នាពេលអនាគត មានប្រភពឈើចំនួន៦ដែលរំពឹងថាអាចនឹងផ្គត់ផ្គង់ឈើមូលនិងឈើអារដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ពីការធ្វើអាជីវកម្មឈើ និងពីការកាប់សម្អាតដីព្រៃឈើ ដល់អ្នកកែច្នៃ/អ្នកនាំចេញ និងអ្នកលក់ចែកចាយក្នុងស្រុក។ ប្រភពសំខាន់សម្រាប់ការផ្គត់ផ្គង់ឈើសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ គឺមានប្រភពមកពីសកម្មភាពកាប់សម្អាតព្រៃឈើក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ (ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន) និងក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចស្ថិតក្នុងចំណាត់ថ្នាក់ប្រើប្រាស់ដីព្រៃដទៃទៀត (ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ)។ បច្ចុប្បន្ននេះ ពុំទាន់មានការបោះផ្សាយបញ្ជីសម្បទានដីសេដ្ឋកិច្ចនៅឡើយ ទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទាំងក្រសួងបរិស្ថាន ដូច្នេះពុំមានទិន្នន័យផ្លូវការសម្រាប់ផ្តល់ឱ្យក្រុមការងារសិក្សាអំពីការផ្គត់ផ្គង់ឈើនេះទេ។ ទិន្នន័យមិនផ្លូវការ ពីអង្គការមិនមែនរដ្ឋាភិបាល Open Development Cambodia (ODC 2013) ដែលដាក់នៅក្នុងគេហ៍ទំព័រ www.opendevelopmentcambodia.net ត្រូវបានក្រុមការងារសិក្សាប្រើប្រាស់សម្រាប់ធ្វើអត្តសញ្ញាណកម្ម និងគូរផែនទីសម្បទានដីសេដ្ឋកិច្ច តាមប្រភេទការប្រើប្រាស់ដីក្នុងខេត្តនីមួយៗ (រូបទី ៤)។ រដ្ឋបាលព្រៃឈើមានទិន្នន័យប្រចាំឆ្នាំអំពីផលិតកម្មឈើមូលដែលប្រមូលបានតាមរយៈសៀវភៅ “ក” និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ ការបូកសរុបកំណត់ត្រាមាន ១៨០.៩៥២ ម៣ ជាបរិមាណឈើដែលបានមកពីគ្រប់ប្រភពទាំងអស់ក្នុងឆ្នាំ២០១២។ ភាគច្រើននៃឈើទាំងនេះ(៩០%) គឺបានមកពីសកម្មភាពកាប់សម្អាតព្រៃឈើក្នុងដីសម្បទានសេដ្ឋកិច្ចមាន ១២៧.១៤២ ម៣ ជាឈើមូលក្នុងឆ្នាំ២០១២ និង ១២៩.៣០០ ម៣ ក្នុងឆ្នាំ២០១១ ពីគ្រប់សម្បទានដីសេដ្ឋកិច្ចទាំងអស់ក្នុងប្រទេសកម្ពុជា។ មានបរិមាណឈើតិចតួចប៉ុណ្ណោះដែលមានប្រភពពីគម្រោង វារីអគ្គិសនីដែលបានកត់ត្រាថាបានផ្គត់ផ្គង់ក្នុងឆ្នាំ២០១១ មាន ៧.៧៨១ ម៣ និង២០១២ មាន ៨.៣៩៦ ម៣ ពុំមានបរិមាណឈើ ដែលបានកត់ត្រាថាចេញមកពីព្រៃសហគមន៍ ចម្ការឈើដាំ និងតំបន់យករ៉ែទេ។ ផលិតផលឈើពីតំបន់ព្រៃធម្មជាតិ ចាំបាច់ត្រូវធ្វើការកែច្នៃក្នុងស្រុកមុននឹងធ្វើការនាំចេញ។

បច្ចុប្បន្ន មានរោងចក្រកែច្នៃឈើប្រហែល៥០កន្លែងនៅក្នុងប្រទេសកម្ពុជា (ក្នុងនោះមានរោងចក្រកែច្នៃមួយ ដែលអាចកែច្នៃបន្ថែមដើម្បីផលិតជាឈើក្បាច់លម្អនិងការ៉ូឈើ)។ ភាគច្រើនរោងចក្រកែច្នៃឈើមានទីតាំងស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ច ហើយឈើមូលគឺបានមកពីសកម្មភាពកាប់សម្អាតព្រៃនៅក្នុងដីសម្បទាន។ រោងចក្រកែច្នៃឈើ ដែលស្ថិតនៅក្រៅដីសម្បទាន គឺតម្រូវឱ្យទិញឈើពីប្រភពឈើក្នុងស្រុកដើម្បីធ្វើការកែច្នៃ។ មិនទាន់មានការកត់ត្រាវត្ថុធាតុដើម (ឈើមូល) ចូល និងផលិតផលឈើកែច្នៃរួចនៅឡើយទេ។

រដ្ឋបាលព្រៃឈើ មិនអាចផ្តល់ទិន្នន័យអំពីផលិតផលឈើដែលប្រើប្រាស់ក្នុងស្រុកបានទេ ប៉ុន្តែ មានការរក្សាទុកទិន្នន័យឈើនាំចេញ។ តាមកំណត់ត្រានេះ ឈើ ២៧.៨០០ ម៣ បាន

នាំចេញក្នុងឆ្នាំ ២០១១ និងមានការធ្លាក់ចុះមក ១៤.១៩២ ម^{3} ក្នុងឆ្នាំ ២០១២។ តាមកំណត់អត្រាឈើនាំចេញ នៅឆ្នាំ២០១១ ផលិតផលនាំចេញភាគច្រើនជាឈើជ្រុង (ការ៉ /ចតុកោណ) និងមានមុខអតិបរមា ទំហំ ២៥ស.ម ហើយស្ទើរតែទាំងអស់គឺនាំចេញទៅប្រទេសចិន(៨៥%) និង១៣% ទៅប្រទេសវៀតណាមនេះ យោងតាមកំណត់ត្រានាំចេញឆ្នាំ ២០១១។ ក៏ប៉ុន្តែ យោងតាមស្ថិតិឆ្នាំ ២០១១ របស់អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ (FAO) បានរាយការណ៍តួលេខខុសគ្នាថា បរិមាណឈើសរុបនាំចេញទៅវៀតណាមមាន ៧១% ហើយនាំចេញទៅប្រទេសចិនមានតែ១១% ប៉ុណ្ណោះ។ យោងតាមស្ថិតិទាំងកម្ពុជា និងទាំងអង្គការ FAO ឈើចំណាំង (wood chips) ទាំងអស់ គឺបាននាំចេញទៅប្រទេសចិន។ ទិន្នន័យអំពីផលិតផលឈើនាំចេញក្នុងឆ្នាំ២០១១ គឺមានតួលេខ មិនត្រូវគ្នាទេ ខាងរាជរដ្ឋាភិបាលរាយការណ៍ថា បរិមាណឈើច្រើនបំផុតបាននាំចេញទៅប្រទេសចិន រីឯអង្គការ FAO រាយការណ៍ថាបរិមាណឈើច្រើនបំផុតបាននាំចេញទៅប្រទេសវៀតណាមទៅវិញ។ ក៏មានរបាយការណ៍ខុសគ្នាដែរស្តីពីផលិតផលឈើនាំចេញ ដូចជាប្រភពអង្គការ FAO រាយការណ៍ថា បរិមាណឈើមូលនាំចេញមានចំនួន ១.០៧៧ ម^{3} តែប្រភពខាងកម្ពុជាមិនឃើញមានតួលេខឈើមូលនាំចេញក្នុងឆ្នាំ ២០១១ទេ។ ភាពខុសគ្នានៃរបាយកាណ៍ រវាងស្ថិតិព្រៃឈើកម្ពុជា និងអង្គការ FAO បានឆ្លុះបញ្ចាំងនូវបញ្ហាសំខាន់មួយ រវាងការចងក្រងទិន្នន័យស្ថិតិ និងរបាយការណ៍ថ្នាក់ជាតិ។ ពុំមានទិន្នន័យអំពីបរិមាណផលិតផលឈើដែលបានប្រើប្រាស់សម្រាប់ទីផ្សារក្នុងស្រុកទេ។

បើនិយាយអំពីការគោរពតាម “ការពង្រឹងអនុវត្តច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើ” (FLEGT) និងការឆ្លើយតបតាមលក្ខខណ្ឌនៅក្នុង “ប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ” (Timber Legality Assurance System = TLAS) ក្នុង FLEGT គឺឃើញថា ពុំទាន់មានព័ត៌មានគ្រប់គ្រាន់ស្តីពីប្រភពផ្គត់ផ្គង់ឈើមូល ក៏ដូចជាប្រព័ន្ធចងក្រងឯកសារអំពីបរិមាណឈើដែលបានប្រមូលពីតំបន់ព្រៃមានអាជ្ញាប័ណ្ណ ការដឹកជញ្ជូនទៅកាន់រោងចក្រកែច្នៃឈើ និង ឆ្លងកាត់ការកែច្នៃរហូតដល់ការនាំចេញនៅឡើយ។ គ្រប់ដើមឈើទាំងអស់ដែលបានដកហូតចេញពីតំបន់ព្រៃធម្មជាតិ គឺតម្រូវឱ្យចុះក្នុងបញ្ជីឈើមូល (សៀវភៅ “ក”) ដែលជាញឹកញយមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានជាអ្នកជួយរៀបចំសៀវភៅនេះ។ សៀវភៅនេះប្រើប្រាស់សម្រាប់សុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលផ្តល់ឱ្យដោយរដ្ឋបាលព្រៃឈើនៅភ្នំពេញ ហើយសម្រាប់កំណត់ការបង់ថ្លៃសួយសារនិងបុព្វលាភ។ បន្ទាប់ពីការបង់ប្រាក់នៅរតនាគាររួចហើយ សម្បទានិកទទួលបានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកឈើមូលពីព្រៃទៅកាន់រោងចក្រកែច្នៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ បង្ហាញព័ត៌មានសង្ខេបអំពីឈើមូល ដូចជា ចំណាត់ថ្នាក់គុណភាព ឈើនិងមាឌឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ គឺមិនបង្ហាញអំពីព័ត៌មានយោង ឬបង្ហាញអំពីបញ្ជីឈើមូលពិតប្រាកដ ដែលគេកំពុងដឹកជញ្ជូនឈើ លើរថយន្តនោះទេ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើមិនមានព័ត៌មានអំពីឈើមូលនីមួយៗ ដូចជាលេខឈើ ឬប្រភេទឈើ អង្កត់ផ្ចិតឈើ និងមាឌឈើឡើយ។ ដូច្នេះលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ មិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្ទៀងផ្ទាត់ប្រភពដើមនៃកំណាត់ឈើនីមួយៗ ដែលកំពុងដឹកជញ្ជូនពីតំបន់ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ឡើយ។

រដ្ឋបាលព្រៃឈើបានកត់ត្រានូវគ្រប់ឈើទាំងអស់ដែលបានកាប់សម្អាតក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច (ឈើមានអង្កត់ផ្ចិតធំជាងឬស្មើ ៣០ស.ម លើកលែងតែឈើប្រណីត) កូនឈើ (មានអង្កត់ផ្ចិតតូចជាង ៣០ស.ម) ក្នុងបញ្ជីឈើមូលសម្រាប់ប្លុកអាជីវកម្មនីមួយៗ និងផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើដល់សម្បទានិក ដើម្បីប្រើប្រាស់ឈើទាំងនោះ ក្រោយពីការបង់ថ្លៃសួយសារនិងបុព្វលាភរួចរាល់។ ក្រោយពីវាស់វែងរួច រដ្ឋបាលព្រៃឈើធ្វើការវាយញញ្ជរត្រាមួយលើឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.ម និង វាយញញ្ជរត្រាបន្ថែមចំនួនបីទៀតលើឈើក្រោយពីការបង់ថ្លៃសួយសារនិងបុព្វលាភរួច។ រដ្ឋបាលព្រៃឈើនៅភ្នំពេញ ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ហើយរដ្ឋបាលព្រៃឈើមូលដ្ឋានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកជញ្ជូនឈើមូលទៅកាន់រោងចក្រកែច្នៃឈើ។ ការតាមដានត្រួតពិនិត្យឈើរបស់រដ្ឋបាលព្រៃឈើ មានដូចជា ការវាស់វែង និងកំណត់ត្រាឈើមូល ការពិនិត្យអំពីគុណភាព និងវាយញញ្ជរត្រា។ ប៉ុន្តែគ្មានទិន្នន័យ បញ្ជាក់រវាងទិន្នផលឈើជាសក្តានុពល និងទិន្នផលឈើជាក់ស្តែងដែលបានប្រមូលផលចេញពីព្រៃមានអាជ្ញាប័ណ្ណទេ។

រដ្ឋបាលព្រៃឈើបានបង្កើតប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើដើម្បីកត់ត្រាអំពីបទល្មើសទាំងអស់ផ្ទុកក្នុងមូលដ្ឋានទិន្នន័យមួយ ដែលកត់ត្រាព័ត៌មានលម្អិតស្តីពីវត្ថុតាងរឹបអូស ដូចជាឈើមូល ផលិតផលឈើ និងមធ្យោបាយដឹកជញ្ជូន។ រដ្ឋបាលព្រៃឈើធ្វើរបាយការណ៍អង្កេតដំបូងនិងតាមដាន កំណត់ហេតុបទល្មើសព្រៃឈើ ដើម្បីកំណត់អំពី ប្រភេទបទល្មើស ថាត្រូវពិន័យឱ្យបង់ប្រាក់អន្តរកាល ឬ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការវិនិច្ឆ័យ។

ការសិក្សានេះផ្តល់អនុសាសន៍ដើម្បីគាំទ្រដល់ការរៀបចំប្រព័ន្ធ TLAS នាពេលអនាគតសម្រាប់ការផ្គត់ផ្គង់ឈើ និងមធ្យោបាយតាមដានភាពស្របច្បាប់របស់ឈើ រួមមាន ៖

1. ចំណាត់ថ្នាក់ការប្រើប្រាស់ដីរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា តំបន់ការពារធម្មជាតិ ព្រៃការពារ ព្រៃសហគមន៍ ព្រៃសម្បទាន និងព្រៃផ្តល់ផល ត្រូវកំណត់ឱ្យបានច្បាស់តាមខេត្ត នីមួយៗគួរជាផែនទី និងធ្វើការបោះផ្សាយ។

2. ការចែកប្រភេទតំបន់ប្រើប្រាស់នៅក្នុងតំបន់ការពារធម្មជាតិជា តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និង តំបន់សហគមន៍ ត្រូវកំណត់ឱ្យបានច្បាស់លាស់ គួរជាផែនទី និងធ្វើការបោះផ្សាយ ត្រូវអនុវត្តតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(២០០៨)។ ក្រសួងបរិស្ថានអាចប្រើប្រាស់ជំនួយពីខាងក្រៅដើម្បីកំណត់ប្រភេទតំបន់ទាំង៤នេះ នៅក្នុងតំបន់ការពារធម្មជាតិ។

3. ព្រៃសម្បទានមានប្រមាណជា ៣,៣ លានហិកតា ដែលស្ថិតក្នុងការផ្អាកដំណើរការអាជីវកម្ម គួរតែពិនិត្យឡើងវិញ ដើម្បីធ្វើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ស្របតាមស្តង់ដារអន្តរជាតិ។ ព្រៃសម្បទានដែលនៅមានសុពលភាពកិច្ចព្រមព្រៀងស្របច្បាប់ និងមានការគ្រប់គ្រងល្អ អាចផ្គត់ផ្គង់ឈើស្របច្បាប់មួយចំណែកធំដល់ទីផ្សារ។

4. ការបង្កើតសហគមន៍ព្រៃឈើ មានទិសដៅបង្កើនរហូតដល់ ២លានហិកតា។ បច្ចុប្បន្នព្រៃសហគមន៍មានទំហំ ៣០៨.៥៦៤ ហិកតា ដែលមានការទទួលស្គាល់ អាចនឹងក្លាយជាប្រភពឈើស្របច្បាប់មួយចំណែក ក្នុងការផ្គត់ផ្គង់ឈើដល់ទីផ្សារ។ ការគ្រប់គ្រងព្រៃសហគមន៍

តម្រូវឱ្យមានការគាំទ្រពីរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ព្រៃឈើសាមី ដើម្បីធានាថាព្រៃឈើត្រូវគ្រប់គ្រងបានល្អនិងផ្តល់ផល និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព។

5. រដ្ឋបាលព្រៃឈើគួរផ្តល់ព័ត៌មានច្បាស់លាស់អំពីតំបន់ព្រៃផ្តល់ផល ព្រៃឯកជន និងចម្ការឈើ ដែលអាចផ្តល់ឈើដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើក្នុងប្រទេសកម្ពុជានាពេលអនាគត។

6. តំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់ឱ្យបានច្បាស់តាមខេត្តនីមួយៗ គួរជាផែនទី និងធ្វើការផ្សព្វផ្សាយ។ តំបន់សម្បទានដីសេដ្ឋកិច្ចមិនគួរត្រួតគ្នាជាមួយនឹងតំបន់ព្រៃសម្បទានទេ លើកលែងតែមានកិច្ចព្រមព្រៀងជាផ្លូវការជាមួយព្រៃសម្បទានិក។

7. តំបន់ប្រើប្រាស់ដោយចីរភាពនៅក្នុងតំបន់ការពារធម្មជាតិ ចាំបាច់ត្រូវកំណត់ឱ្យបានរួចរាល់សិន មុនធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីឱ្យស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨)។

8. គួរតែធ្វើសារពើភ័ណ្ឌព្រៃ ប៉ាន់ស្មានបរិមាណឈើស្តុក ដែលជាផ្នែកមួយនៃការរៀបចំផែនការមេ កំណត់តំបន់សម្រាប់ដាំដុះ និងដើម្បីប៉ាន់ស្មានឱ្យបានច្បាស់លាស់អំពីធនធានឈើដែលអាចដកហូតបាននៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។

9. បរិមាណឈើដែលដកហូត និងតំបន់ដែលត្រូវកាប់សម្អាតក្នុងដីសម្បទានសេដ្ឋកិច្ច និងតំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណផ្សេងៗទៀត គួរមានកំណត់ត្រាច្បាស់លាស់ និងបញ្ចូលទិន្នន័យទាំងនេះក្នុងរបាយការណ៍ប្រចាំឆ្នាំ។

10. ផ្ទៃដីបានប្រមូលផលឈើ (កាប់សម្អាត) រួចក្នុងដីសម្បទានសេដ្ឋកិច្ច គួរធ្វើការដាំដុះស្របទៅតាមកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច។

11. ឈើពាណិជ្ជកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារ ដែលមានប្រភពមកពីសហគមន៍ព្រៃឈើដែលមានកិច្ចព្រមព្រៀង និង មានការឯកភាពលើផែនការគ្រប់គ្រង និងមានប្រភពឈើចេញពីចម្ការឈើ គួររៀបចំឯកសារតាមប្រព័ន្ធអនុវត្តបច្ចុប្បន្ន ដូចគ្នាទៅនឹងឈើដែលចេញពីព្រៃធម្មជាតិដែរ ដោយធ្វើការកត់ត្រាឈើដកហូតចូលទៅក្នុងសៀវភៅបញ្ជីឈើ ហើយការដឹកជញ្ជូនឈើ គឺត្រូវប្រើលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។

12. គួរធ្វើការតាមដានតាមការកាប់សម្អាតព្រៃក្នុងគម្រោងទំនប់វារីអគ្គិសនី និងធ្វើការកត់ត្រាឈើមូលដែលប្រមូលបាន ដោយផ្អែកតាមផែនការមេ។

13. ត្រូវរក្សាទុកកំណត់ត្រាការនាំឈើចូលជាមួយនឹងអាជ្ញាប័ណ្ណនាំចូល ឯកសារនេះត្រូវកំណត់ទម្រង់ព័ត៌មាន តាមស្តង់ដារអន្តរជាតិ(សុខដុមកម្មប្រព័ន្ធកូដ) ដូចជា ព័ត៌មានស្តីពីគោលដៅនៃការនាំចូល មាឌឈើ បរិមាណឈើ។ល។ ដែលអាចប្រើសម្រាប់ការផ្ទៀងផ្ទាត់ និង

រាយការណ៍ ទៅអង្គការអន្តរជាតិ ដូចជា អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក (ITTO) និងអង្គការ FAO។

14. លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ សង្ខេបព័ត៌មានអំពីមាឌឈើមូលដែលផ្អែកតាមគុណភាពឈើដាក់ចូលក្នុងបញ្ជីឈើមូលមួយដាច់ដោយឡែក និងបញ្ជាក់ឱ្យបានច្បាស់អំពីឈើដែលត្រូវដឹកជញ្ជូនតាមរថយន្តនីមួយៗ ដើម្បីអាចផ្ទៀងផ្ទាត់ព័ត៌មានរបស់ឈើទាំងនោះបាន។ មាឌឈើអាចនឹងខុសគ្នារវាងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ និង បញ្ជីផល-អនុផលព្រៃឈើ ព្រោះថាលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ អាចមានមាឌឈើមូលច្រើនជាង ដែលត្រូវដឹកជញ្ជូនតាមរថយន្តលើសពីមួយគ្រឿង។ បញ្ហានេះ ធ្វើឱ្យលំបាកក្នុងការផ្ទៀងផ្ទាត់បរិមាណឈើដែលកំពុងដឹកជញ្ជូនថាជាចំណែកណាមួយនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដែលអាចពិនិត្យផ្ទៀងផ្ទាត់រវាងសៀវភៅ “ក” និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១។

15. លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ (PC-1) សង្ខេបព័ត៌មានអំពីឈើមូលដែលត្រូវដឹកជញ្ជូនពីគំនរ ឆ្ពោះទៅកាន់រោងចក្រកែច្នៃឈើ។ ប៉ុន្តែតាមការអនុវត្តបច្ចុប្បន្ននេះ PC-1 អាចមានមាឌឈើមូលច្រើនជាង ដែលត្រូវដឹកជញ្ជូនតាមរថយន្ត លើសពីមួយ គ្រឿង។ PC-1 គួរតែចេញឲ្យតាមបរិមាណឈើដែលអាចផ្ទុកលើរថយន្តតែ ០១គ្រឿង និងបង្ហាញព័ត៌មានតាមបញ្ជីឈើមូល ដូចជា លេខឈើ ប្រភេទឈើ ទំហំឈើ និងមាឌរបស់ឈើដែលកំពុងដឹកជញ្ជូនលើមធ្យោបាយដឹកជញ្ជូនណាមួយ ពីតំបន់មានអាជ្ញាប័ណ្ណណាមួយ និងមានលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ (LP) ទៅកាន់គោលដៅណាមួយ។ PC-1 គួរតែមានព័ត៌មានគ្រប់គ្រាន់ដែលអាចធ្វើការផ្ទៀងផ្ទាត់ឱ្យដឹងថាឈើដែលកំពុងដឹកជញ្ជូន គឺត្រូវគ្នាជាមួយនឹងបណ្តាឯកសារដែលកំពុងប្រើប្រាស់សម្រាប់ការដឹកជញ្ជូន។

16. ទោះបីមានការតម្រូវជាផ្លូវការឱ្យម្ចាស់រោងចក្រកែច្នៃឈើត្រូវមានសៀវភៅកត់ត្រាឈើចូលនិងឈើចេញពីរោងចក្រកែច្នៃឈើក៏ដោយ រដ្ឋបាលព្រៃឈើក៏ត្រូវប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយ ស្តីពីរោងចក្រកែច្នៃឈើ និង ផលិតផលឈើកែច្នៃដែរ គឺតាមរយៈកំណត់ត្រាដែលមានក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ និង លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល សម្រាប់ធ្វើការវិភាគ និង ធ្វើផែនការក្នុងវិស័យព្រៃឈើ។ រដ្ឋបាលព្រៃឈើបានចាប់ផ្តើមតម្រូវឱ្យរោងចក្រកែច្នៃឈើរាយការណ៍ជាផ្លូវអំពីឈើចូល-ឈើចេញប្រចាំថ្ងៃ តាមទម្រង់កត់ត្រាស្តង់ដារមួយ។

17. ការកត់ត្រាវត្ថុធាតុដើមឈើចូលដែលមិនទាន់កែច្នៃ ដូចជា ចំនួនឈើមូល មាឌឈើ និងឯកតាផលិតកម្ម (ទិន្នផលឈើកែច្នៃចេញពីឈើមូល) ដើម្បីអាចផ្តល់ជាប្រព័ន្ធមួយដែលអាចផ្ទៀងផ្ទាត់បានរវាងបរិមាណឈើមូលចូល និងបរិមាណផលិតផលឈើកែច្នៃដែលទទួលបាន(ចេញ)។

18. កំណត់ត្រាការនាំចេញឈើ តម្រូវឱ្យរក្សាទុកអាជ្ញាប័ណ្ណនាំចេញ ដែលអាចផ្ទៀងផ្ទាត់ផលិតផល ជាមួយឯកតាផលិតកម្ម។ កំណត់ត្រាផលិតផលឈើនាំចេញ គួរកំណត់ឱ្យបានច្បាស់

លាស់តាមស្តង់ដារអន្តរជាតិ (សុខដុមកម្មប្រព័ន្ធកូដ) អំពីទិសដៅ (កន្លែងទទួល) មាឌ ឈើ បរិមាណឈើ។ល។ ដែលអាចប្រើប្រាស់ការតាមដានដឹងអំពីប្រភពផលិតផលឈើ និង អាចរាយការណ៍ទៅអង្គការ អន្តរជាតិ ដូចជា អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក (ITTO) និងអង្គការ FAO។

19. កង្វះទិន្នន័យស្តីពីកម្រិតកំណត់ទិន្នផលក្នុងការប្រមូលផលធ្វើឱ្យការតាមដានត្រួតពិនិត្យ បរិមាណឈើ ដកហូត និងការដឹកជញ្ជូនពីតំបន់ប្រមូលផលនិងតំបន់កាប់សម្អាតព្រៃ មិនសូវ មានប្រសិទ្ធភាពទេ។ ទិន្នផលប៉ាន់ស្មាន ចេញពីទិន្នន័យសារពើភ័ណ្ឌព្រៃឈើអាចប្រើប្រាស់ សម្រាប់តាមដាន បរិមាណផលិតកម្មដែលបានកត់ត្រានៅក្នុងបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ “ក”) និងលិខិតបើកផ្លូវ ដឹកជញ្ជូនផល-អនុផលព្រៃឈើ ហើយនិងការដឹក ជញ្ជូនតាមរយៈលិខិត អនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។

20. ការតាមដានឈើមូលក្នុងការដឹកជញ្ជូន និងឈើចូលរោងចក្រកែច្នៃឈើ អាចកែលម្អកាន់តែ ប្រសើរថែមទៀត បើសិនជាលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ មានព័ត៌មាន ស្តីពីអត្តសញ្ញាណច្បាស់លាស់របស់ឈើមូលដែលកំពុងដឹកជញ្ជូន(ពីតំបន់ព្រៃឈើមាន អាជ្ញាប័ណ្ណ) នៅលើមធ្យោបាយដឹកជញ្ជូនណាមួយនោះ ដូចជា លេខឈើ ប្រភេទឈើ និង ខ្នាតឈើ ដែលអាចធ្វើការវាស់វែងនិងផ្ទៀងផ្ទាត់បាន។

ការសិក្សាអំពីចរាចរឈើគឺ ដើម្បីផ្តល់ព័ត៌មានលម្អិតអំពីប្រព័ន្ធនិងនីតិវិធីបច្ចុប្បន្ននៅប្រទេស កម្ពុជា ហើយកំណត់វិធីសាស្ត្រចាំបាច់ដែលអាចធ្វើការផ្ទៀងផ្ទាត់ភាពស្របច្បាប់ក្នុងការគ្គត់ផ្គង់ ឈើនៅកម្ពុជា។ សហភាពអឺរ៉ុបបានចេញច្បាប់ថ្មីស្តីពីការធ្វើពាណិជ្ជកម្មឈើ ដែលបានចូលជា ធរមានតាំងតែពីខែមីនា ឆ្នាំ២០១៣ ហើយបច្ចុប្បន្ននេះ ផលិតផលឈើខុសច្បាប់ត្រូវបានហាម ឃាត់មិនឱ្យចូលទីផ្សារសហភាពអឺរ៉ុបទៀតទេ។

ការចូលរួមក្នុងដំណើរការឆ្ពោះទៅកាន់កិច្ចព្រមព្រៀងដែគូស្ម័គ្រចិត្ត (Voluntary Partnership Agreement= VPA) ជាមួយសហភាពអឺរ៉ុប អាចចាត់ទុកថាជាការប្តេជ្ញាជាផ្លូវការរបស់កម្ពុជា ដើម្បីដោះស្រាយចំណុចខ្សោយដែលបានរកឃើញនៅក្នុងការសិក្សាអំពីចរាចរឈើនេះ។ ការពង្រឹង ការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច អាចជាជំហានដំបូងដើម្បីឆ្ពោះទៅរកឈើមានអាជ្ញាប័ណ្ណ ក្នុងFLEGT។ ដំណើរការចរចាដើម្បីទទួលបានកិច្ចព្រមព្រៀង VPA អាចចាប់ផ្តើមបាន បើសិន ប្រទេសកម្ពុជាធ្វើការទាក់ទងជាផ្លូវការទៅសហភាពអឺរ៉ុប ដើម្បីបង្ហាញអំពីការប្តេជ្ញារបស់កម្ពុជាក្នុង ការចរចា និងអាចឈានទៅការរៀបចំនិងការអនុវត្តប្រព័ន្ធ TLAS។ នៅពេលទទួលបានកិច្ចព្រម ព្រៀង ពេលនោះ ផលិតផលឈើរបស់កម្ពុជាអាចទទួលបានអាជ្ញាប័ណ្ណសម្រាប់នាំចេញទៅទីផ្សារ សហភាពអឺរ៉ុប។ ដំណើរការចរចាដើម្បីទទួលបានកិច្ចព្រមព្រៀង VPA គឺតម្រូវឱ្យអ្នកពាក់ព័ន្ធនៅ ថ្នាក់ជាតិទាំងអស់ត្រូវចូលរួមក្នុងការកំណត់ភាពស្របច្បាប់របស់ឈើ ការរៀបចំប្រព័ន្ធ TLAS និង ពិភាក្សាអំពីតម្លាភាព ដើម្បីធានាថា ការចរចាសុំកិច្ចព្រមព្រៀង VPA នេះ ទទួលបានការជឿជាក់និង ការគាំទ្រពីថ្នាក់ជាតិនៃប្រទេសកម្ពុជា។

១. សាវតាគម្រោង

ការសិក្សានេះ គឺជាផ្នែកមួយនៃផែនការការងារនៃកិច្ចសម្របសម្រួលក្នុងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឈើរបស់សហភាពអឺរ៉ុប (EU FLEGT Facility) ដែលឧបត្ថម្ភដោយវិទ្យាស្ថានព្រៃឈើអឺរ៉ុប។

ក្នុងបរិបទសម្រាប់រាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីយល់ដឹងអំពីផែនការសកម្មភាព EU FLEGT និងការរៀបចំ សម្រាប់ការចរចាសុំកិច្ចព្រមព្រៀងដៃគូស្ម័គ្រចិត្ត (VPA) ជាមួយសហភាពអឺរ៉ុប។ ការសិក្សានេះ គឺជាបេសកកម្មក្នុងការជូនព័ត៌មានដល់រាជរដ្ឋាភិបាលកម្ពុជានិងសហភាពអឺរ៉ុប អំពីការតាមដាន និងត្រួតពិនិត្យចរាចរឈើនៅក្នុងប្រទេសកម្ពុជា។

ការសិក្សានេះមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសជាមួយគណៈកម្មការដឹកនាំនិងគ្រប់គ្រងការសិក្សាស្វែងយល់អំពីចរាចរឈើ និងការត្រួតពិនិត្យផលិតផលឈើនៅកម្ពុជាដែលមានការចូលរួមពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ សមាសភាពនៅក្នុងគណៈកម្មការដឹកនាំ ការសិក្សានេះរួមមាន៖

1.	ឯ.ឧ. បណ្ឌិត ឆេង គឹមស៊ុន	ប្រធានរដ្ឋបាលព្រៃឈើ	ប្រធាន
2.	ឯ.ឧ. បណ្ឌិត ជា សំអាង	អនុប្រធានរដ្ឋបាលព្រៃឈើ	អនុប្រធាន
3.	លោក កែវ សុខឃាង	ប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន គយ និងរដ្ឋាករ	សមាជិក
4.	លោក ហោ អៀងឆាយ	អនុប្រធានការិយាល័យ ក្រសួងពាណិជ្ជកម្ម	សមាជិក
5.	លោក Alexander Hinrichs	ទីប្រឹក្សា EFI FLEGT តំបន់អាស៊ី	សមាជិក
6.	លោក Koen Everaert	ជំនួយការប្រតិភូសហភាពអឺរ៉ុប ប្រចាំភ្នំពេញ	អ្នកសង្កេតការណ៍
7.	លោក សូ លន	អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានឧស្សាហកម្ម ឈើ និង សហប្រតិបត្តិការអន្តរជាតិ នៃរដ្ឋបាលព្រៃឈើ	ភាគីដៃគូ
8.	លោក សួន សុវណ្ណ	អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋាន នីតិកម្ម និងពង្រឹងការអនុវត្តច្បាប់នៃ រដ្ឋបាលព្រៃឈើ	ភាគីដៃគូ
9.	លោក ហង់ ស៊ីនត្រា	អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានឧស្សាហកម្មឈើ និងសហប្រតិបត្តិការអន្តរជាតិ នៃរដ្ឋបាលព្រៃឈើ	លេខាធិការ

១.១. គោលបំណងនៃការសិក្សា

ការសិក្សានេះគឺដើម្បីផ្តល់ការយល់ដឹងអំពីចរាចរណ៍ឈើក្នុងប្រទេសកម្ពុជា និងការត្រួតពិនិត្យឈើ ដោយរដ្ឋបាលព្រៃឈើនិងអង្គភាពរាជរដ្ឋាភិបាលពាក់ព័ន្ធផ្សេងៗទៀតនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ បន្ថែមពីនេះ ការសិក្សាក៏ផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជាឱ្យយល់ដឹងបន្ថែមទៀតអំពីទស្សនទានៃកិច្ចព្រមព្រៀង VPA និងវិធីសាស្ត្រដែលអាចជឿជាក់បាន ក្នុងការចងក្រងឯកសារឈើស្របច្បាប់ ជាពិសេសគឺតាមរយៈប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ(TLAS)។ គោលបំណងចម្បងនៃការសិក្សានេះ គឺដើម្បីកំណត់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ផលិតផលឈើក្នុងប្រទេសកម្ពុជាដោយ ផ្អែកតាមក្របខ័ណ្ឌច្បាប់និងការទទួលខុសត្រូវរបស់ស្ថាប័ននិងអង្គភាពនៃប្រទេសកម្ពុជា ចំពោះផលិតផលឈើ និងប្រភពឈើសំខាន់ៗដូចជា ៖ ព្រៃផ្តល់ផល ចម្ការឈើដាំ ការបង្វែរការប្រើប្រាស់ដីព្រៃឈើ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្បទានដីសេដ្ឋកិច្ច(ELCs) តំបន់អាជីវកម្ម(ដ) សហគមន៍ព្រៃឈើ និងឈើនាំចូល។ ខ្សែសង្វាក់ផ្គត់ផ្គង់ឈើ សម្រាប់ផលិតផលឈើលក់នៅទីផ្សារក្នុងស្រុក ក៏ដូចជា ផលិតផលឈើសម្រាប់ធ្វើការនាំចេញ។

ដើម្បីរៀបចំឱ្យមានសក្តានុពលក្នុងកិច្ចចរចាសុំកិច្ចព្រមព្រៀង VPA ការសិក្សានេះនឹងបរិយាយអំពីលិខិតបទដ្ឋានគតិយុត្តិ៣ពាក់ព័ន្ធនៅក្នុងប្រព័ន្ធតាមដានឈើ និងការចងក្រងឯកសារ៣ពាក់ព័ន្ធនឹងចរាចរណ៍ឈើ។ ការសិក្សានឹងកំណត់អំពីខ្សែសង្វាក់ផ្គត់ផ្គង់ឈើពីតំបន់ព្រៃឈើ រួមមាន ព្រៃធម្មជាតិ ព្រៃសហគមន៍ ដីសម្បទានសេដ្ឋកិច្ច និងកន្លែងផ្សេងៗទៀត (និងឈើនាំចូលតាមរយៈ ផលិតកម្ម ពាណិជ្ជកម្ម ការលក់និងការនាំចេញ)។ ការសិក្សានឹងបរិយាយផងដែរ អំពីកិច្ចការផ្ទៀងផ្ទាត់ និងតួនាទីរបស់អង្គភាពរាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចលើខ្សែសង្វាក់ផ្គត់ផ្គង់ឈើជាពិសេសក្នុងការតាមដាន ការប្រមូលទិន្នន័យ និងកិច្ចការត្រួតពិនិត្យ។

ការសិក្សានេះពិនិត្យមើលស្ថានភាពបច្ចុប្បន្ននៃការផ្គត់ផ្គង់ឈើ ការដឹកជញ្ជូនឈើ ការកែច្នៃឈើ ផលិតកម្មឈើ និងទិន្នន័យនៃការនាំចេញឈើ។ ការសិក្សានេះកំណត់អំពីភាពចន្លោះប្រហោងសំខាន់ៗក្នុងប្រព័ន្ធបច្ចុប្បន្ន (ឧទាហរណ៍ បណ្តាចំណុចដែលឈើមិនទាន់បានផ្ទៀងផ្ទាត់ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ហើយផ្តល់អនុសាសន៍សម្រាប់ធ្វើការកែលម្អ។)

១.២. វិធីសាស្ត្រ និងបណ្តាសកម្មភាពសំខាន់ៗ

គោលបំណងសំខាន់នៃការសិក្សាដើម្បីស្វែងយល់ដឹងអំពីចរាចរណ៍ឈើនៅកម្ពុជានេះ គឺដើម្បីធ្វើការវាយតម្លៃ អំពីខ្សែសង្វាក់ផ្គត់ផ្គង់ឈើនៅកម្ពុជា អំពីប្រភពឈើនិងផលិតផលឈើដែលលក់នៅទីផ្សារក្នុងស្រុក ឬជាចំណែកមួយនៃទីផ្សារនាំចេញទៅប្រទេសជិតខាង ដូចជា ប្រភពឈើចេញពីតំបន់ព្រៃគុប ឈើបានមកពីការកាប់សម្អាតព្រៃក្នុងសម្បទានដីសេដ្ឋកិច្ច ចម្ការឈើដាំ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងពីឈើនាំចូល។ ព័ត៌មានទាំងនេះមានសារសំខាន់ណាស់សម្រាប់កំណត់និយមន័យភាពស្របច្បាប់របស់ឈើ និងការរៀបចំប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ TLAS ដែលជាចំណែកមួយសម្រាប់ការចរចាសុំកិច្ចព្រមព្រៀង VPA នាពេលអនាគត។

១.៣. ក្រុមការងារសិក្សា

លោកបណ្ឌិត Kevin Grace	ប្រធានក្រុម
អ្នកស្រី ម៉ៅ មុនីរតនា	ទីប្រឹក្សាក្នុងស្រុក
លោកបណ្ឌិត កុយ រ៉ា	ទីប្រឹក្សាក្នុងស្រុក

Photo: GFS

២. វិធីសាស្ត្រនៃការសិក្សា

២.១. ការចាប់ផ្តើមការសិក្សា

ការសិក្សានេះរួមមាន ការពិនិត្យរបាយការណ៍ដែលមានស្រាប់ស្តីពីការការពារព្រៃផ្តល់ផល តំបន់អភិរក្ស ផលិតកម្មឈើ និងចរាចរឈើ ដែលមាន៤ប្រភពសំខាន់ៗ គឺ ព្រៃគុបអាជីវកម្ម សម្បទានដីសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍចម្ការ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឈើនាំចូល និងឈើរឹបអូស។ របាយការណ៍ចាប់ផ្តើមការសិក្សាផ្តល់នូវគំរូខ្សែសង្វាក់ផ្គត់ផ្គង់ឈើទូទៅមួយ ដែលនឹងត្រូវធ្វើការកែសម្រួលតាមរយៈការរកឃើញក្នុងការសិក្សានេះ។

នៅភ្នំពេញក្រុមការងារសិក្សាបានជួបមន្ត្រីមួយចំនួនរបស់ EU FLEGT Facility និងមន្ត្រីរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក៏ដូចជាអង្គការផ្សេងៗទៀត ដើម្បីទទួលបានព័ត៌មានសំខាន់ៗសម្រាប់រៀបចំរបាយការណ៍ចាប់ផ្តើមការសិក្សាអំពីគំរូចរាចរឈើទូទៅមួយក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធត្រួតពិនិត្យចរាចរឈើផ្សេងៗនៅកម្ពុជាបានវិវឌ្ឍន៍ជាច្រើនទសវត្សរ៍មកហើយ។ ការប្រែប្រួលនូវលក្ខខណ្ឌទីផ្សារ និងគោលនយោបាយបានធ្វើការកែសម្រួលប្រព័ន្ធនេះ។ គំរូខ្សែសង្វាក់ផ្គត់ផ្គង់ឈើដំបូងនេះចាត់ទុកថាជាសេចក្តីព្រាងនៃការងារសិក្សានេះ។ វិធីសាស្ត្រនៃការសិក្សានេះគឺផ្តោតលើការប្រមូលទិន្នន័យនៅទីវាលក្នុងខេត្តចំនួន ៣ សម្រាប់ចងក្រងជារបាយការណ៍សិក្សា។

វិធីសាស្ត្រប្រើក្នុងការសិក្សានេះ គឺសិក្សាពីថ្នាក់ក្រោមឡើងទៅថ្នាក់លើដើម្បីវាយតម្លៃប្រព័ន្ធនាបច្ចុប្បន្ននេះ និងការចុះទៅប្រមូលទិន្នន័យពីបណ្តាប្រភពសំខាន់ៗនៃការផ្គត់ផ្គង់ឈើនៅតាមបណ្តាអង្គភាពដែលរៀបចំឯកសារស្តីពី ការធ្វើអាជីវកម្មឈើ រោងចក្រកែច្នៃឈើនៅខេត្ត និង

ទិន្នន័យស្តីពីការនាំចេញឈើនៅខេត្ត ដើម្បីបង្ហាញជា គំរូតាងមួយ ស្តីពីខ្សែសង្វាក់ផ្គត់ផ្គង់ឈើនៅប្រទេសកម្ពុជា និងរកមើលអំពីសកម្មភាពអ្វីខ្លះដែលកំពុងតែអនុវត្តនៅមូលដ្ឋាន ចំពោះតម្រូវការនីតិវិធី "បន្តិចបន្តួច" ដែលបានកំណត់ដោយរាជរដ្ឋាភិបាលថ្នាក់ជាតិ។

២.២. ការប្រមូលទិន្នន័យ

ការសិក្សាអំពីការផ្គត់ផ្គង់ឈើនេះ បង្ហាញអំពីទិដ្ឋភាពសំខាន់ៗ ដូចជា ការប្រមូលទិន្នន័យ និងការវាយតម្លៃនៅទីវាលអំពីការអនុវត្តប្រព័ន្ធនេះ។

ការសិក្សាបានដំណើរការចាប់ពីខែសីហាដល់ខែវិច្ឆិកា ឆ្នាំ ២០១៣ នៅភ្នំពេញ ខេត្តមណ្ឌលគីរី ខេត្តកោះកុង និងខេត្តព្រះសីហនុ តាមការចង្អុលបង្ហាញរបស់គណៈកម្មការដឹកនាំការសិក្សា។ ការសិក្សានេះ បានទទួលការសម្របសម្រួលពីរដ្ឋបាលព្រៃឈើ ដើម្បីផ្តល់លទ្ធភាពដល់ក្រុមការងារសិក្សាបានជួបពិគ្រោះយោបល់ជាមួយនឹងអង្គភាពរាជរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃឈើ និងពាណិជ្ជកម្មឈើនៅកម្ពុជា។ ក្រុមការងារបានជួបជាមួយអង្គភាពរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅភ្នំពេញដើម្បីប្រមូលព័ត៌មាន និងបានទៅពិនិត្យផ្ទាល់នៅមូលដ្ឋាន ក្នុងរយៈពេល ៣០ ថ្ងៃ ក្នុងខេត្តមណ្ឌលគីរី ខេត្តកោះកុង និងខេត្តព្រះសីហនុ ចាប់ពីខែកញ្ញារហូតដល់វិច្ឆិកា ឆ្នាំ២០១៣ ដើម្បីធ្វើការវាយតម្លៃអំពីការផ្គត់ផ្គង់ឈើ និងបណ្តាប្រព័ន្ធដែលបានប្រើប្រាស់ក្នុងរៀបចំឯកសារឈើ ដែលត្រូវផ្គត់ផ្គង់ឈើទៅឱ្យឧស្សាហកម្មឈើក្នុងស្រុក និងសម្រាប់ ធ្វើការនាំចេញ (ឧបសម្ព័ន្ធ២ កម្មវិធីចុះមូលដ្ឋាន)។

ក្រុមការងារសិក្សាបានជួបប្រាស្រ័យទាក់ទងជាមួយនឹងអង្គភាពរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល មានដូចជា៖

- រដ្ឋបាលព្រៃឈើ
- អង្គការ WWF (World Wide Fund for Nature)-ការិយាល័យនៅភ្នំពេញ
- ក្រសួងពាណិជ្ជកម្ម
- សមាគមឧស្សាហកម្មឈើកម្ពុជា
- ខណ្ឌរដ្ឋបាលព្រៃឈើ (មណ្ឌលគីរី កោះកុង ព្រះសីហនុ)
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អង្គការ CI (Conservation International) នៅភ្នំពេញ
- អង្គការស្បៀងអាហារ និងកសិកម្ម របស់អង្គការសហប្រជាជាតិ (FAO)

ក្រុមការងារសិក្សាបានធ្វើការវាយតម្លៃបឋមអំពីវិស័យព្រៃឈើ ផ្អែកទៅតាមវត្ថុធាតុដើមឈើដែលចេញពីប្រភពព្រៃឈើផ្សេងៗ។

ប្រទេសកម្ពុជាមានដីព្រៃឈើចំនួន ១០,៨ លានហិកតា ដែលមានប្រភេទការប្រើប្រាស់ដីខុសៗគ្នាជាច្រើន និង ស្ថិតក្រោមគ្រប់គ្រងរបស់ក្រសួងចំនួនពីរ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់

និងនេសាទ និងក្រសួងបរិស្ថាន។ ចាប់តាំងពីការបញ្ឈប់ការធ្វើអាជីវកម្មឈើក្នុងព្រៃធម្មជាតិនាខែមករា ឆ្នាំ ២០០២ មក ភាគច្រើននៃឈើផ្តត់ផ្គង់ គឺបានមកពីការប្រមូលផលឈើនិងការកាប់សម្អាតព្រៃសម្រាប់បង្វែរដីទៅជាចម្ការដំណាំពីគម្រោងអភិវឌ្ឍន៍កសិកម្ម និងពីគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមការងារសិក្សាបានពិពណ៌នាអំពីតំបន់ព្រៃឈើ ដោយអនុលោមទៅតាមចំណាត់ថ្នាក់ការប្រើប្រាស់ដី ដែលបានកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងភាពស្របច្បាប់នៃការប្រមូលផលឈើ។

ការសិក្សានេះ បានចងក្រងឯកសារស្តីពីតួនាទីរបស់អង្គភាពរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ឈើ និងចរាចរឈើ ដើម្បីកំណត់អំពីភាពរឹងមាំរបស់ប្រព័ន្ធនិងសមត្ថភាពរបស់អង្គភាពផ្សេងៗក្នុងការត្រួតពិនិត្យចរាចរឈើ។ ក្រុមការងារសិក្សាបានសង្កេតអំពីនីតិវិធីនៅមូលដ្ឋាន ដោយចុះទៅទស្សនកិច្ចរោងចក្រកែច្នៃឈើមួយចំនួន និងជួបជាមួយផលិតករនិងមន្ត្រីអង្គភាពរាជរដ្ឋាភិបាល ដើម្បីសង្កេតមើលគំនរឈើក្នុងរោងចក្រកែច្នៃ ចំណុចត្រួតពិនិត្យតាមដងផ្លូវ ប៉ុស្តិ៍ត្រួតពិនិត្យរបស់គយតាមព្រំដែន ដើម្បីវាយតម្លៃអំពីនីតិវិធី និងការអនុវត្តប្រព័ន្ធបច្ចុប្បន្ន។

ក្រុមការងារសិក្សាបានវាយតម្លៃការផ្គត់ផ្គង់ឈើចេញពីតំបន់ព្រៃតាមចំណាត់ថ្នាក់ការប្រើប្រាស់ដីផ្សេងៗនៅតាមបណ្តាខេត្តដែលបានចុះទៅសិក្សា ដើម្បីយកជាឧទាហរណ៍អំពីការអនុវត្តប្រព័ន្ធនេះ។

ខេត្តដែលបានជ្រើសរើសសម្រាប់ចុះទៅសិក្សា រួមមាន៖

ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ គឺដើម្បីធ្វើការវាយតម្លៃការដាំដុះក្នុងដីសម្បទាន ការបង្កើតព្រៃគុប គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ តាមរយៈរូបភាពសម្បទានដីសេដ្ឋកិច្ច និងរោងចក្រកែច្នៃឈើ និងកំណត់ត្រាការដឹកជញ្ជូនឈើ។

ខេត្តកោះកុង គឺដើម្បីបរិយាយអំពីដំណើរការរបស់គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ទំនប់ទឹក ការបង្វែរការប្រើប្រាស់ដីតាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច រោងចក្រកែច្នៃឈើ ដែលមានទីតាំងក្នុងព្រៃឬទីតាំងរបស់រោងចក្រ កំណត់ត្រាការដឹកជញ្ជូន។

ខេត្តព្រះសីហនុ គឺដើម្បីស្រង់យកទិន្នន័យស្តីពីការនាំចូលនិងនាំចេញ ដើម្បីវាយតម្លៃអំពីការអនុវត្តប្រព័ន្ធគយ ដែលបានប្រើក្នុងប្រទេសកម្ពុជា។

បណ្តាកន្លែងដែលបានចុះទស្សនកិច្ច គឺដើម្បីវាយតម្លៃប្រព័ន្ធបច្ចុប្បន្នស្តីពីការចងក្រងឯកសារតំបន់ប្រមូលផល ទៅតាមប្រភេទការប្រើប្រាស់ដីព្រៃឈើ ដែលរួមមានគុបប្រមូលផល សហគមន៍ព្រៃឈើចម្ការឈើឯកជន តំបន់សម្បទានដីសេដ្ឋកិច្ចសម្រាប់បង្កើតជាចម្ការដំណាំកសិកម្ម និងការអភិវឌ្ឍ ដូចជា ទំនប់ទឹក និងតំបន់យកវ៉ែ។ ប្រព័ន្ធបច្ចុប្បន្ន និងកំណត់ត្រាទិន្នន័យស្តីពីការផ្តល់អាជ្ញាប័ណ្ណ ការប្រមូលផល និងការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មឈើមកពីតំបន់ប្រមូលផលផ្សេងៗ ត្រូវបានធ្វើការវាយតម្លៃតាមខេត្តនីមួយៗដែលបានចុះទៅសិក្សា។ ក្រុមការងារសិក្សាបានសង្កេត រោងចក្រកែច្នៃឈើមួយចំនួនដែលមានទីតាំងនៅក្នុងដីសម្បទានសេដ្ឋកិច្ច ឬក៏នៅតំបន់ដទៃទៀត។ ក្រុមការងារសិក្សា បានធ្វើការវាយតម្លៃអំពីកំណត់ត្រាទិន្នន័យឈើដែលជាប្រព័ន្ធមួយសម្រាប់កត់ត្រាឈើចូល និងផលិតផលឈើចេញពីរោងចក្រកែច្នៃឈើ។

ក្រុមការងារសិក្សាបានធ្វើការជាមួយរដ្ឋបាលព្រៃឈើ និងបានជួបជាមួយក្រសួងបរិស្ថានដើម្បីយកទិន្នន័យស្តីពីតំបន់ព្រៃឈើនិងបរិមាណឈើផ្គត់ផ្គង់ដែលបានកត់ត្រាអំពីប្រភពផ្គត់ផ្គង់ឈើសំខាន់ៗ(ដីសម្បទានសេដ្ឋកិច្ច សហគមន៍ព្រៃឈើ ចម្ការឈើដាំ និងការនាំចូល)។ ក្រុមការងារសិក្សាបានជួបអគ្គនាយដ្ឋានគយ និងរដ្ឋាករដើម្បីយកទិន្នន័យ ស្តីពីការនាំចូលនិងការនាំចេញផលិតផលឈើសម្រេច។ ក្រុមការងារសិក្សាបានទៅជួបជាមួយមន្ត្រីអង្គភាពរាជរដ្ឋាភិបាល នៅមូលដ្ឋានខេត្ត ដើម្បីឱ្យជួយសម្របសម្រួលក្នុងការប្រមូលទិន្នន័យ ក៏ប៉ុន្តែ តែងតែជួបការលំបាកណាស់ក្នុងការរកបានទិន្នន័យ ដោយសារតែអង្គភាពទាំងនោះមានតួនាទីខុសៗគ្នានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ដែលបណ្តាលឱ្យការរក្សាទុកទិន្នន័យទាំងនោះនៅរាយប៉ាយ។ ភាពរាយប៉ាយនេះ បណ្តាលឱ្យមានការកត់ត្រាទិន្នន័យមិនស៊ីសង្វាក់គ្នានៅក្នុងប្រព័ន្ធនៃការផ្គត់ផ្គង់ឈើទាំងមូល។

ក្រុមការងារសិក្សាបានប្រមូលផ្តុំព័ត៌មានដែលទទួលបានពីអង្គភាពរាជរដ្ឋាភិបាល ហើយបំពេញបន្ថែមជាមួយនឹងទិន្នន័យដែលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាក្រុមហ៊ុនឯកជន។ ក្រុមការងារសិក្សាចងក្រងឯកសារព័ត៌មានដែលមានស្រាប់ក្នុងរបាយការណ៍ដើម្បីវិភាគមើលតំបន់សម្រាប់ការផ្គត់ផ្គង់ឈើ និងរកមើលប្រព័ន្ធសម្រាប់កត់ត្រាទិន្នន័យឈើ និងការត្រួតពិនិត្យផលិតកម្ម ឈើមូល រហូតដល់ការកែច្នៃឈើ ការលក់ឈើក្នុងស្រុក និងការនាំឈើចេញ។ វិធីសាស្ត្រនេះអាចថាមិនមានលក្ខណៈជាប្រព័ន្ធ ក៏ប៉ុន្តែតាមពិត វាផ្តល់នូវមធ្យោបាយល្អបំផុតគឺអាចទទួលបានព័ត៌មាន ច្រើនអំពីប្រព័ន្ធបច្ចុប្បន្នដែលកំពុងអនុវត្តនៅតាមបណ្តាខេត្តដែលកំពុងធ្វើការសិក្សា ហើយបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃទិន្នន័យ ដែលយើងត្រូវចងក្រងរក្សាទុក និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ទិន្នន័យអំពីការផ្គត់ផ្គង់ឈើនៅក្នុងបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ "ក") របស់រោងចក្រកែច្នៃឈើ មួយត្រូវបានសង្កេត អំពីការកត់ត្រាឈើចូល ដើម្បីវាយតម្លៃលទ្ធភាពតាមដានវត្ថុធាតុដើមឈើចូលរហូតដល់ការកែច្នៃឈើ។ ក្រុមការងារសិក្សាចង់ពិនិត្យទិន្នន័យផលិតផលឈើចេញពីរោងចក្រកែច្នៃឈើ ព្រោះវាមានទំនាក់ទំនងជាមួយកំណត់ត្រានៃការផ្គត់ផ្គង់ឈើ ដើម្បីវាយតម្លៃអំពីបរិមាណវត្ថុធាតុដើមឈើដែលអាចមាន សម្រាប់ផ្គត់ផ្គង់តម្រូវការទៅតាមសមត្ថភាពផលិតកម្មរបស់រោងចក្រកែច្នៃឈើ។ រដ្ឋបាលព្រៃឈើខ្វះទិន្នន័យអំពីផលិតកម្មឈើនៅតាមខេត្តនីមួយៗ បណ្តាលឱ្យការវាយតម្លៃអំពីបរិមាណឈើផ្គត់ផ្គង់និងផលិតកម្មផលិតផលឈើនៅមានកម្រិត ឬ មិនមានប្រសិទ្ធភាព។ ទិន្នន័យទាំងនេះអាចប្រមូលចងក្រងបាន ដោយធ្វើការដកស្រង់ទិន្នន័យពីបញ្ជីផល-អនុផលព្រៃឈើ និងពីលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើដែលអនុញ្ញាតឱ្យសម្បទាននិកប្រើប្រាស់ឈើ និងពីទិន្នន័យឈើចូលទៅក្នុងរោងចក្រកែច្នៃឈើ ដោយផ្អែកតាមព័ត៌មានក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ (PC) និងពីទិន្នន័យផលិតកម្មឈើចេញពីរោងចក្រកែច្នៃឈើ ដោយផ្អែកតាមព័ត៌មានក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ (PC-1) និងក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល (PC-IMEX)។

ទិន្នន័យដែលប្រមូលបានពីបណ្តាខេត្តដែលបានធ្វើការវិភាគហើយនោះ ត្រូវបានយកមកប្រើសម្រាប់បង្កើតជាគំរូខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ដើម្បីគូសបង្ហាញអំពីចរាចរឈើពីបណ្តាប្រភពឈើ

ដូចបានកំណត់នៅក្នុងលក្ខខណ្ឌការងារ (ToR) របស់ក្រុមការងារសិក្សា។ បន្ទាប់ពីការចុះទស្សនកិច្ច នៅតាមបណ្តាខេត្តមក ក្រុមការងារសិក្សាបានស្នើសុំព័ត៌មានបន្ថែមពីអង្គភាពរាជរដ្ឋាភិបាល នៅទីក្រុងភ្នំពេញ អំពីតំបន់ផលិតកម្មឈើ ទិន្នន័យអំពីតំបន់សម្បទានដីសេដ្ឋកិច្ច នៅតាមខេត្ត និង កំណត់ត្រាអំពីបរិមាណប្រមូលផលឈើ និងបរិមាណផលិតកម្មឈើរបស់រោងចក្រកែច្នៃឈើ។ គំរូខ្សែសង្វាក់ផ្គត់ផ្គង់ឈើនេះបានឆ្លុះបញ្ចាំងនូវប្រព័ន្ធជាក់ស្តែងមួយ ដែលអាចចាត់ទុកថាកំពុង តែដំណើរការនៅមូលដ្ឋាន និងអាចធ្វើការប្រៀបធៀបជាមួយនឹងដំណើរការនិយ័តកម្ម។

ភាពរាយប៉ាយនៃទិន្នន័យនៅតាមបណ្តាអង្គភាពរាជរដ្ឋាភិបាល បណ្តាលឱ្យជួបការលំបាក ក្នុងការរៀបចំវិធីសាស្ត្រ មួយឱ្យមានសង្គតិភាពគ្នាក្នុងអំឡុងនៃការសិក្សានេះ ដែលត្រូវធ្វើការកែ លម្អ សម្រាប់ការរៀបចំការចរចាសុំកិច្ចព្រមព្រៀង VPA និងការរៀបចំប្រព័ន្ធធានាភាពស្រប ច្បាប់របស់ឈើ TLAS។ លទ្ធផលនៃការវាយតម្លៃបានពន្យល់ពិស្តារនៅក្នុងរបាយការណ៍នេះ ដោយ ផ្អែកតាមទិន្នន័យដែលបានទទួល។ ក៏ប៉ុន្តែ សុពលភាពនៃការវាយតម្លៃនេះ គឺអាស្រ័យ លើភាពរឹងមាំនៃទិន្នន័យនិងវិធីសាស្ត្រវិភាគ។ ដោយធ្វើការវិភាគទិន្នន័យរាយប៉ាយទាំងនេះ ការ សិក្សាបានរកឃើញភាពចន្លោះប្រហោងចំនួនពីរប្រភេទនៅក្នុងប្រព័ន្ធបច្ចុប្បន្ន ដែលចាំបាច់ត្រូវ ធ្វើការដោះស្រាយសម្រាប់ការបង្កើតប្រព័ន្ធធានាភាពស្របច្បាប់នៃឈើ TLAS រួមមាន៖ ពុំទាន់ មានទិន្នន័យដែលត្រូវការចាំបាច់ ឬ អង្គភាពរដ្ឋាភិបាលពុំទាន់បានប្រមូលចងក្រងទុក។ ប្រព័ន្ធ ឬក្របខ័ណ្ឌការងារ បើតាមទ្រឹស្តីគឺបានចែងអំពីការចងក្រងព័ត៌មានសម្រាប់រក្សាទុក ក៏ប៉ុន្តែ ការ អនុវត្តជាក់ស្តែងគឺនៅមានភាពចន្លោះប្រហោងក្នុងការប្រមូលទិន្នន័យនិងការគ្រប់គ្រងទិន្នន័យ។

Photo: Bryn Pinzgauer

៣. ឆ្នាទីរបស់អង្គភាពរាជរដ្ឋាភិបាល

៣.១. មូលដ្ឋានច្បាប់ (បទប្បញ្ញត្តិ)

ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ បានចែងថា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ (PFE) ត្រូវគ្រប់គ្រងប្រកបដោយនិរន្តរភាព ដើម្បីបង្កើនជាអតិបរមានូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន និងមរតក វប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០០២)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវចាត់ថ្នាក់ ចុះបញ្ជីកានិងកំណត់ព្រំប្រទល់ព្រៃឈើទាំងអស់នៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍។ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍មានបីប្រភេទគឺ ព្រៃផ្តល់ផល ព្រៃការពារ និងព្រៃសម្រាប់ផ្ទេរការប្រើប្រាស់ផ្សេងៗ។

អនុក្រឹត្យលេខ ៥៣ អនក្រ.បក (ចុះថ្ងៃទី១ មេសា ២០០៥) រួមមាននីតិវិធីសម្រាប់ការបង្កើតការចាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងផ្តល់អំណាចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការកំណត់ព្រំប្រទល់ដែនព្រៃឈើ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ដោយប្រើផែនទីគម្រប់ព្រៃឆ្នាំ ២០០២ ជាមូលដ្ឋាន។ ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍មួយចំនួនត្រូវបានកំណត់រួចតាំងពីការផ្តល់ព្រៃសម្បទាន តំបន់ការពារ ព្រៃការពារ តំបន់អភិរក្ស តំបន់សហគមន៍ព្រៃឈើ ក៏ប៉ុន្តែ ក្រសួងកសិកម្មទទួលស្គាល់ថា មានការប្រែប្រួលមួយចំនួនអាចនឹងធ្វើការពិនិត្យឡើងវិញ។

៣.១.១. គោលនយោបាយព្រៃឈើជាតិ

រាជរដ្ឋាភិបាលបានបង្កើតឡើងនូវកម្មវិធីព្រៃឈើជាតិ២០១០ដល់២០២៩ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ក្របខ័ណ្ឌការងារគោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានព្រៃឈើដ៏មានតម្លៃរបស់កម្ពុជា ដើម្បីឆ្លើយតបនឹងសេចក្ដីថ្លែងការណ៍គោលនយោបាយព្រៃឈើជាតិ (២០០២)។ ក្របខ័ណ្ឌការងារសម្រាប់ការអនុវត្តកម្មវិធីព្រៃឈើជាតិ មាន៦កម្មវិធីសំខាន់ៗដូចជា ៖

១. កម្មវិធី-ការកំណត់ព្រំប្រទល់ព្រៃឈើ ការចាត់ថ្នាក់ និងចុះបញ្ជិកា

ការកំណត់ព្រំប្រទល់ព្រៃឈើនិងការចាត់ថ្នាក់ព្រៃឈើ ត្រូវអនុវត្តតាមលក្ខណជាប្រព័ន្ធ មានតម្លាភាព មានសុខុដុមកម្មជាមួយនឹងក្របខ័ណ្ឌច្បាប់ផ្សេងៗទៀតតាមរយៈ ដំណើរការដោយមានការចូលរួម និងការលើកទឹកចិត្ត ឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមចំណែកដល់ការទប់ស្កាត់ទំនាស់ដីធ្លី ដូចជា ទំនាស់កម្មសិទ្ធិ សិទ្ធិប្រើប្រាស់។ កម្មវិធីនេះ មានអនុកម្មវិធីចំនួនពីរ ៖

- អនុកម្មវិធី ១.១ ការកំណត់ព្រំព្រទល់ព្រៃឈើ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- អនុកម្មវិធី ១.២ ការចាត់ថ្នាក់ព្រៃឈើជាតិតាមមុខងារ

២. កម្មវិធី-ការអភិរក្ស និងការអភិវឌ្ឍធនធានព្រៃឈើ និងជីវចម្រុះ

ការគ្រប់គ្រងនិងការអភិរក្សធនធានព្រៃឈើ ដោយផ្តោតលើការអនុវត្តគំរូគ្រប់គ្រងព្រៃឈើដែលមានស្រាប់ និង គំរូគ្រប់គ្រងព្រៃឈើថ្មីៗ និងការផ្តល់តម្លៃបន្ថែមក្នុងផលិតកម្មផលិតផលព្រៃឈើ ដើម្បីបង្កើនការចូលរួមចំណែកនៃវិស័យព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅ និងការអភិវឌ្ឍសេដ្ឋកិច្ច ទន្ទឹមនឹងការការពារសេវាកម្មបរិស្ថាន តាមរយៈការអនុវត្តអនុកម្មវិធី ចំនួន៩ ៖

- អនុកម្មវិធី ២.១ ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ
- អនុកម្មវិធី ២.២ ការអភិវឌ្ឍ និងការអនុវត្តបច្ចេកទេសគ្រប់គ្រងព្រៃផ្តល់ផល
- អនុកម្មវិធី ២.៣ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- អនុកម្មវិធី ២.៤ ការអភិរក្សធនធានជីវចម្រុះ និងសត្វព្រៃ
- អនុកម្មវិធី ២.៥ ការអភិរក្ស និងការអភិវឌ្ឍធនធានសេនេទិក និងប្រភពពូជ
- អនុកម្មវិធី ២.៦ ការដាំដុះដើមឈើ និងការអភិវឌ្ឍចម្ការព្រៃឈើដាំ
- អនុកម្មវិធី ២.៧ ការអភិវឌ្ឍផលិតផលព្រៃឈើនិងពង្រីកទីផ្សារ
- អនុកម្មវិធី ២.៨ ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងការកែច្នៃផល-អនុផលព្រៃឈើ
- អនុកម្មវិធី ២.៩ ការអភិវឌ្ឍប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើ

៣. កម្មវិធី-ការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច

អភិបាលកិច្ច និងការអនុវត្តច្បាប់ស្តីពីព្រៃឈើ គឺជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ។ កម្មវិធីព្រៃឈើជាតិជម្រុញឱ្យមានការចូលរួមពីសំណាក់គ្រប់អ្នកពាក់ព័ន្ធក្នុងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងពង្រឹងការអនុវត្តច្បាប់តាមរយៈការអនុវត្តអនុកម្មវិធីចំនួន៥ ៖

- អនុកម្មវិធី ៣.១ ការកែទម្រង់ច្បាប់ និងរដ្ឋបាល
- អនុកម្មវិធី ៣.២ ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ
- អនុកម្មវិធី ៣.៣ ការឆ្លើយតបរហ័សចំពោះព័ត៌មានឧក្រិដ្ឋកម្មព្រៃឈើ
- អនុកម្មវិធី ៣.៤ ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទំនាស់។ អនុកម្មវិធីនេះនឹងលើកឡើងនូវតម្រូវការសមត្ថភាពក្នុងការគ្រប់គ្រងទំនាស់ក្នុងសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ដើម្បីទប់ស្កាត់ ឬបង្ក្រាបទំនាស់ ចំពោះការបំផ្លាញព្រៃឈើ
- អនុកម្មវិធី ៣.៥ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងរាយការណ៍មួយ នឹងចែងលម្អិតក្នុងកម្មវិធីអនុវត្ត។ ប្រព័ន្ធត្រួតពិនិត្យធ្វើឱ្យមានតុល្យភាព និងការយល់ដឹងសម្រាប់ប្រសិទ្ធភាព និងនិរន្តរភាពក្នុងការអនុវត្ត។

៤. កម្មវិធីសហគមន៍ព្រៃឈើ

កម្មវិធីសហគមន៍ព្រៃឈើចូលរួមចំណែកក្នុងការសម្រេចគោលបំណងនៃកម្មវិធីព្រៃឈើជាតិ។ កម្មវិធីនេះផ្តល់លទ្ធភាពដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមបែបការចូលរួមសម្រាប់ផលប្រយោជន៍ដោយសមធម៌ និងបង្កើនជីវភាពរស់នៅ។ កម្មវិធីនេះមានអនុកម្មវិធីចំនួន៣ ៖

- អនុកម្មវិធី ៤.១ ការកំណត់តំបន់សក្តានុពល និងការបង្កើតសហគមន៍ព្រៃឈើ
- អនុកម្មវិធី ៤.២ ការអភិវឌ្ឍសហគមន៍ និងការបង្កើនជីវភាព
- អនុកម្មវិធី ៤.៣ ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

៥. កម្មវិធី-ការអភិវឌ្ឍសមត្ថភាពនិងការស្រាវជ្រាវ

កម្មវិធីនេះកំណត់អំពីតម្រូវការសមត្ថភាព និងផ្តួចផ្តើមកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ដើម្បីផ្តល់ដល់បណ្តាអ្នកពាក់ព័ន្ធ ដើម្បីសម្រេចគោលបំណងរបស់កម្មវិធីព្រៃឈើជាតិ។ កម្មវិធីនេះ មានអនុកម្មវិធី ចំនួន៣ ៖

- អនុកម្មវិធី ៥.១ ការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស
- អនុកម្មវិធី ៥.២ ការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ
- អនុកម្មវិធី ៥.៣ ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ

៦. កម្មវិធី-ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ

ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិស័យព្រៃឈើ ផ្តល់នូវក្របខ័ណ្ឌការងារ និរន្តរភាពសេដ្ឋកិច្ច និងតម្លាភាព ដើម្បីសម្រេចគោលបំណងទាំងអស់របស់កម្មវិធីព្រៃឈើជាតិ។ កម្មវិធីនេះនឹងសម្រេចបានតាមរយៈការអនុវត្តអនុកម្មវិធីចំនួន៥ ៖

- អនុកម្មវិធី ៦.១ ហិរញ្ញប្បទានផ្តល់ដោយរាជរដ្ឋាភិបាល
- អនុកម្មវិធី ៦.២ ចំណូលពីវិស័យព្រៃឈើ
- អនុកម្មវិធី ៦.៣ ចំណូលពីវិស័យឯកជន និងសហគមន៍ព្រៃឈើ
- អនុកម្មវិធី ៦.៤ ការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- អនុកម្មវិធី ៦.៥ ប្រភពហិរញ្ញប្បទានថ្មីៗពីសេវាកម្មបរិស្ថាន និងឥណទានកាបូន

៣.១.២. បទប្បញ្ញត្តិសម្រាប់ការផ្តត់ផ្គង់ឈើ

បទប្បញ្ញត្តិសម្រាប់ការផ្គត់ផ្គង់ឈើ មានដូចជា៖

- ច្បាប់ស្តីពីព្រៃឈើ (រាជរដ្ឋាភិបាលកម្ពុជា ២០០២)
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍ព្រៃឈើ (រាជរដ្ឋាភិបាលកម្ពុជា ២០០៣)
- អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ឆ្នាំ២០០០
- អនុក្រឹត្យស្តីពី នីតិវិធី ការបង្កើត ការចាត់ថ្នាក់ ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ឆ្នាំ ២០០៥
- សារាចរស្តីពី ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ឆ្នាំ២០០៧
- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី (រាជរដ្ឋាភិបាលកម្ពុជា ២០០៩)
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (រាជរដ្ឋាភិបាលកម្ពុជា ២០០៨)

៣.២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានអាណត្តិក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យកសិកម្ម (ព្រៃឈើ ជលផល ដំណាំកសិកម្ម និងការចិញ្ចឹមសត្ត) ក្នុងប្រទេសកម្ពុជា។ តួនាទីនិងភារកិច្ចសំខាន់ៗរបស់ក្រសួងកសិកម្ម រួមមាន ៖

- អនុវត្តគោលនយោបាយកសិកម្ម
- រៀបចំនិងអនុវត្តឧបករណ៍ច្បាប់ក្នុងវិស័យកសិកម្ម ដើម្បីថែរក្សាធនធានធម្មជាតិ កែលម្អកម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ច
- ចូលរួមក្នុងការរៀបចំគោលនយោបាយកំណែទម្រង់ ដីធ្លី
- សម្របសម្រួល និងសហប្រតិបត្តិការជាមួយអង្គការក្នុងនិងក្រៅប្រទេស អង្គការក្រៅរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍ វិស័យកសិកម្ម

- តាមដាននិងគ្រប់គ្រងធនធានធម្មជាតិរបស់វិស័យកសិកម្ម និងសម្របសម្រួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិ ដើម្បីបំពេញតម្រូវការរបស់ប្រទេសជាតិ និងរក្សាលំនឹងអេកូឡូស៊ី
- ណែនាំការងារអភិវឌ្ឍន៍ដី និងការកែលម្អគុណភាពដី និងប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្ត ជីគីមី និងថ្នាំ កសិកម្មអោយបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សាតុល្យភាពបរិស្ថានធម្មជាតិ

រដ្ឋបាលព្រៃឈើ គឺជាអង្គភាពសំខាន់ស្ថិតនៅក្រោមក្រសួងកសិកម្ម ក្នុងការគ្រប់គ្រងសកម្មភាពព្រៃឈើនៅក្នុងព្រៃផ្តល់ផល ព្រៃការពារ ព្រៃសម្បទាន និងសហគមន៍ព្រៃឈើ។

៣.២. ១. រដ្ឋបាលព្រៃឈើ

រដ្ឋបាលព្រៃឈើមាននាយកដ្ឋានចំណុះមួយចំនួនរួមមាន នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ និង នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ។ នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើទទួលខុសត្រូវ ក្នុងការចាត់ចែងនិងគ្រប់គ្រងព្រៃឈើប្រមាណជា ៧,៩លាន ហិកតា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការប្រើប្រាស់ ដីព្រៃឈើ រួមមាន ព្រៃផ្តល់ផល ព្រៃការពារ ព្រៃសម្បទាន និង ព្រៃសហគមន៍។

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម សម្រាប់ការគ្រប់គ្រងព្រៃឈើ និង ធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់ស្តីពីព្រៃឈើ (២០០២)។ រដ្ឋបាលព្រៃឈើមានភារកិច្ចអនុវត្តដូចតទៅ ៖

- រៀបចំបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងសកម្មភាពព្រៃឈើដើម្បីធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ប្រកបដោយនិរន្តរភាព។
- សិក្សាប្រមូលទិន្នន័យស្តីពីព្រៃឈើរដ្ឋ ដូចជា កត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់អំពី កម្រិតផ្តល់ផលប្រកបដោយនិរន្តរភាព
- វាយតម្លៃអំពីព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បីបង្កើតជាផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន
- រៀបចំនិងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅតាមថ្នាក់នីមួយៗនៃរដ្ឋបាលព្រៃឈើ
- បង្កើនការដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល និងដីព្រៃទំនេរ
- បង្កើនការអភិវឌ្ឍកិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើ ដោយផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប
- រៀបចំនិងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារ និងអភិរក្សធនធានព្រៃឈើ និងសត្វព្រៃ
- ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ ការកាប់ព្រៃ ដើម្បីធានាដល់ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព

- បង្កើនការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធីផ្សព្វផ្សាយអំពីសារសំខាន់ ក្នុងការគ្រប់គ្រង ការពារថែរក្សា ធនធានព្រៃឈើ ក៏ដូចជាចាត់វិធានការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងអភិរក្សព្រៃឈើ។
- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពក្នុងការការពារនិងអភិវឌ្ឍន៍ធនធានព្រៃឈើ
- វាយតម្លៃឱ្យទាន់ពេលវេលា អំពីសកម្មភាពព្រៃឈើណាដែលអាចមានផលប៉ះពាល់អាក្រក់ដល់សង្គម និង បរិស្ថាន មុនការអនុញ្ញាតឱ្យអនុវត្តសកម្មភាពទាំងនេះ។

រដ្ឋបាលព្រៃឈើ អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់ ត្រូវបំពេញភារកិច្ចទាំងនេះ។

រូបទី ១ ផែនទី អធិការដ្ឋាន ខណ្ឌនិងផ្នែករដ្ឋបាលព្រៃឈើក្នុងប្រទេសកម្ពុជា (ប្រភពរដ្ឋបាលព្រៃឈើ ២០១២)



៣.២. ១.១. រដ្ឋបាលព្រៃឈើ

រដ្ឋបាលព្រៃឈើមាននាយកដ្ឋានចំនួន៧ស្ថិតនៅថ្នាក់កណ្តាល ដែលមានតួនាទីនិងភារកិច្ចរបស់ខ្លួន តាមការចាត់តាំង។ បណ្តានាយកដ្ឋាននៅក្នុងរដ្ឋបាលព្រៃឈើ រួមមាន៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់
- នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន
- នាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ
- នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

- នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ។

៣.២. ១.២. អធិការដ្ឋានរដ្ឋបាលព្រៃឈើ

អធិការដ្ឋានរដ្ឋបាលព្រៃឈើត្រូវបានកំណត់ជាភូមិភាគ ដែលមានព្រំប្រទល់ត្រូវគ្នាទៅនឹងព្រំប្រទល់រដ្ឋបាល ខេត្តមួយចំនួន សម្រាប់ការគ្រប់គ្រងព្រៃឈើតាមភូមិភាគទាំងនោះ។ មានអធិការដ្ឋានចំនួន៤ ៖

- អធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ
- អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប
- អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប
- អធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រ

អធិការដ្ឋានរដ្ឋបាលព្រៃឈើមាន តួនាទីភារកិច្ច ត្រួតពិនិត្យ ណែនាំ សម្របសម្រួល និងធ្វើអធិការកិច្ចលើសកម្មភាពប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៣.២. ១.៣. ខណ្ឌរដ្ឋបាលព្រៃឈើ

ខណ្ឌរដ្ឋបាលព្រៃឈើមានចំនួន១៨ នៅក្នុងប្រទេសកម្ពុជា។ ព្រំប្រទល់ដែនសមត្ថកិច្ចរបស់ខណ្ឌរដ្ឋបាលព្រៃឈើមួយចំនួន មិនត្រូវគ្នាជាមួយនឹងព្រំប្រទល់រដ្ឋបាលរបស់ខេត្តនីមួយៗទេ។ ភារកិច្ចសំខាន់របស់ខណ្ឌរដ្ឋបាលព្រៃឈើ គឺរៀបចំផែនការគ្រប់គ្រងព្រៃឈើនិងផែនការសកម្មភាពដើម្បីសម្រេចតាមផែនការ។ តួនាទី និង ភារកិច្ចរបស់ខណ្ឌរដ្ឋបាលព្រៃឈើមានដូចជា៖

- ត្រួតពិនិត្យ ដឹកនាំ និងសម្របសម្រួលផ្នែករដ្ឋបាលព្រៃឈើ និងសង្កាត់រដ្ឋបាលព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អនុវត្តតាមគោលនយោបាយ និងផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ
- រៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំផែនការសកម្មភាពសម្រាប់ដាក់ឱ្យបណ្តាផ្នែករដ្ឋបាលព្រៃឈើ និងសង្កាត់រដ្ឋបាលព្រៃឈើ ហើយផែនការនេះ ត្រូវសុំសេចក្តីសម្រេចពីប្រធានរដ្ឋបាលព្រៃឈើ
- សិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍សម្រាប់ការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន
- ផ្តល់លិខិតកូតាអនុញ្ញាតឱ្យប្រមូលផល-អនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន
- ផ្តល់លិខិតអនុញ្ញាតឱ្យបង្កើតរោងសន្ទិធិលក់ ចែកចាយ ផល-អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើប្រភេទតូច
- ផ្តល់លិខិតអនុញ្ញាតឱ្យបង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល-អនុផលព្រៃឈើជាវត្ថុធាតុដើម មានលក្ខណៈ ជាឧស្សាហកម្ម ឬសិប្បកម្ម

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយសហគមន៍មូលដ្ឋានដែលរស់នៅក្នុងឬក្បែរដែនព្រៃ បម្រុងទុកអចិន្ត្រៃយ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារ វិស័យព្រៃឈើ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនប្រធានរដ្ឋបាលព្រៃឈើ

៣.២. ១.៤. ផ្នែករដ្ឋបាលព្រៃឈើ

ផ្នែករដ្ឋបាលព្រៃឈើទទួលខុសត្រូវជាសំខាន់ក្នុងការអនុវត្តសកម្មភាពវិស័យព្រៃឈើ ដើម្បីសម្រេចបានតាមផែនការគ្រប់គ្រងដែលបង្កើតឡើងដោយខណ្ឌរដ្ឋបាលព្រៃឈើ។ ផ្នែករដ្ឋបាលព្រៃឈើដើរតួនាទីសំខាន់ក្នុងការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។ តួនាទីនិងភារកិច្ចសំខាន់ៗរបស់ផ្នែករដ្ឋបាលព្រៃឈើរួមមាន៖

- អនុវត្ត វាយតម្លៃសារពើភ័ណ្ឌធនធានព្រៃឈើ សត្វព្រៃ និងធ្វើការកំណត់ព្រំប្រទល់ដែនព្រៃឈើ
- សិក្សាស្រាវជ្រាវ អនុវត្តការគ្រប់គ្រង ការពារ អភិរក្ស សត្វព្រៃ និងដែនជម្រកសត្វព្រៃ
- សិក្សារៀបចំ និងអនុវត្តផែនការគ្រប់គ្រងវិស័យព្រៃឈើក្នុងដែនសមត្ថកិច្ច
- រៀបចំ និងដាក់ស្នើផែនការគ្រប់គ្រងព្រៃផ្តល់ផលនៅក្រៅដីព្រៃសម្បទានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីពិនិត្យសម្រេច
- អនុវត្តការងារដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ ផ្សព្វផ្សាយ ការពារ និងប្រឆាំងភ្លើងឆេះព្រៃ
- សម្របសម្រួលពិនិត្យ និងផ្តល់ជំនួយបច្ចេកទេសព្រៃឈើដល់សហគមន៍ព្រៃឈើ
- ត្រួតពិនិត្យការប្រមូលផល-អនុផលព្រៃឈើ និងវាស់វែង វាយតម្លៃគុណភាពនិងបរិមាណផល-អនុផលព្រៃឈើ ដើម្បីចុះក្នុងកំណត់ហេតុបញ្ជីឈើសៀវភៅ “ក”
- ធ្វើការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ
- រៀបចំ ចងក្រង និងបញ្ជូនសំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃទៅតុលាការ
- ចេញលិខិតអនុញ្ញាតប្រមូលផល-អនុផលព្រៃឈើដែលលើសបរិមាណពីសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍
- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ចេញពីតំបន់ដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារ វិស័យព្រៃឈើ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូននាយខណ្ឌរដ្ឋបាលព្រៃឈើ

៣.២. ១.៥. សង្កាត់រដ្ឋបាលព្រៃឈើ

សង្កាត់រដ្ឋបាលព្រៃឈើ គឺជាអង្គភាពអនុវត្តថ្នាក់មូលដ្ឋាន ដើម្បីគាំទ្រដល់ផ្នែករដ្ឋបាលព្រៃឈើ។ តួនាទីនិងភារកិច្ច របស់សង្កាត់រដ្ឋបាលព្រៃឈើមាន ៖

- ដើរលេងជាអចិន្ត្រៃយ៍ដើម្បីត្រួតពិនិត្យការពារធនធានព្រៃឈើនិងសត្វព្រៃព្រមទាំងប្រយុទ្ធប្រឆាំងភ្លើងឆេះព្រៃ
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការយល់ដឹងស្តីពីព្រៃឈើនិងលើកទឹកចិត្តការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងការពារធនធានព្រៃឈើនិងសត្វព្រៃ
- រៀបចំថ្នាលបណ្តុះកូនឈើ អនុវត្តការងារដាំឈើ និងស្តារព្រៃឈើឡើងវិញ
- សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសដល់សហគមន៍ព្រៃឈើ
- ធ្វើសារពើភ័ណ្ឌព្រៃឈើនិងសត្វព្រៃ និងគ្រប់គ្រង
- អនុវត្តផ្ទាល់លើការវាស់វែង វាយតម្លៃ និងកំណត់បរិមាណផល-អនុផលព្រៃឈើ
- តាមដាន រាយការណ៍ ចងក្រងសំណុំរឿង ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ

៣.៣. ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានមានអាណត្តិក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យបរិស្ថានក្នុងប្រទេសកម្ពុជា។ ក្រសួងបរិស្ថានមានតួនាទីនិងភារកិច្ច៖

- អនុវត្តគោលនយោបាយបរិស្ថានដើម្បីធានាការអភិវឌ្ឍដោយចីរភាពក្នុងប្រទេសកម្ពុជា និងរៀបចំសំណើស្តីពីផែនការសកម្មភាពបរិស្ថានជាតិនិងក្នុងតំបន់ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- រៀបចំ និងអនុវត្តបទដ្ឋានច្បាប់បរិស្ថាននានា ដើម្បីជំរុញនិងធានាអោយមានការអភិវឌ្ឍដោយចីរភាពក្នុងប្រទេសកម្ពុជា។

ក្រសួងបរិស្ថានគ្រប់គ្រងតំបន់ការពារធម្មជាតិចំនួន ២,៨លានហិកតា។ ក្រសួងក៏មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ការធ្វើចម្ការកសិកម្ម ការដាំឈើ ឬការអភិវឌ្ឍសាងសង់ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។ រាជរដ្ឋាភិបាលបានបង្កើតច្បាប់តំបន់ការពារធម្មជាតិ នាឆ្នាំ២០០៨ ដើម្បីកំណត់ក្របខ័ណ្ឌការងារសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។ គោលបំណងនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ គឺដើម្បីធានាការគ្រប់គ្រង អភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពនៅក្នុងតំបន់ការពារធម្មជាតិ។

មាត្រា ១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិចែងថា តំបន់ការពារធម្មជាតិនីមួយៗត្រូវបែងចែកចេញជា៤ តំបន់គ្រប់គ្រងដូចខាងក្រោម៖

តំបន់ស្នូល

តំបន់ស្នូលជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្ត-រុក្ខជាតិដែលកម្រជិតផុតពូជទទួលរងគ្រោះថ្នាក់ រងការគម្រាមកំហែង និងប្រព័ន្ធអេកូឡូស៊ីផ្ទុយស្រួយ។

ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ

ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារនិងអភិរក្សធនធានធម្មជាតិ ជីវចម្រុះ និងបរិស្ថាន តែត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែ ក្នុងវិស័យសន្តិសុខ និងការពារជាតិ។

តំបន់អភិរក្ស

តំបន់អភិរក្ស ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់តំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ទេសភាពធម្មជាតិ។

ការចេញ-ចូលតំបន់នេះត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខនិងការពារជាតិ។

ការប្រើប្រាស់ផល-អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍ជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវចម្រុះ ហើយស្ថិតក្រោមការត្រួតត្រាហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។

តំបន់ប្រើប្រាស់ដោយចីរភាព

តំបន់ប្រើប្រាស់ដោយចីរភាព ជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាព សហគមន៍មូលដ្ឋាន និងជនជាតិភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនេះ យោងតាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានដោយអនុលោម តាមច្បាប់និងនីតិវិធីជាធរមាន។

តំបន់សហគមន៍

តំបន់សហគមន៍ ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់សហគមន៍និងជនជាតិដើមភាគតិច។ តំបន់សហគមន៍អាចមានលំនៅដ្ឋាន ដីស្រែ និងចម្ការ។

៣.៤. ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវក្នុងការគ្រប់គ្រង និងលើកកម្ពស់វិស័យពាណិជ្ជកម្មនៃប្រទេសកម្ពុជា។ ក្រសួងនេះផ្តល់អាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ក៏ដូចជា អាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រនាំចូល-នាំចេញ។ ក្រុមហ៊ុនអាចស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូលដែលផ្តល់ឱ្យដោយនាយកដ្ឋានអាហរ៍ណ-នីហរ៍ណនៃក្រសួងពាណិជ្ជកម្ម។ អាជ្ញាប័ណ្ណនាំចេញអាចផ្តល់ឱ្យដោយយោងតាមសំណើសុំ ដែលត្រូវភ្ជាប់មកជាមួយឯកសារមួយចំនួនដូចជា ៖

- សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល (ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការឯកភាពជាគោលការណ៍ អនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការនាំឈើចេញពីប្រទេសកម្ពុជា)
- លិខិតស្នើសុំការឯកភាពជាគោលការណ៍សម្រាប់ការនាំចូល-នាំចេញ ពីក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ

- លិខិតរបស់ក្រុមហ៊ុនស្នើសុំអាជ្ញាប័ណ្ណនាំចូល-នាំចេញ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ច្បាប់អនុញ្ញាតបង្កើតក្រុមហ៊ុន និងប៉ាតង់
- លិខិតផ្ទេរសិទ្ធិរបស់ប្រធានក្រុមហ៊ុន
- កិច្ចសន្យារវាងអ្នកទិញ និងអ្នកលក់
- លិខិត (ចំណារ) ឯកភាពពីប្រធានរដ្ឋបាលព្រៃឈើលើអាជ្ញាប័ណ្ណនាំចេញ
- វិក័យប័ត្រទូទាត់ (បន្ទាប់មក ទើបក្រសួងពាណិជ្ជកម្មផ្តល់អាជ្ញាប័ណ្ណនាំចេញ)

ជំហានបន្ទាប់

- បន្ទាប់ពីក្រសួងពាណិជ្ជកម្មបានផ្តល់អាជ្ញាប័ណ្ណនាំចេញ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (នៅភ្នំពេញ)
- រដ្ឋបាលព្រៃឈើធ្វើការវាស់វែង ផ្ទៀងផ្ទាត់បរិមាណ និងគុណភាពរបស់ផលិតផលឈើនាំចេញដែលផ្ទុកនៅក្នុង កុងតឺន័រ នៅរោងចក្រកែច្នៃឈើ ដើម្បីផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូល-នាំចេញ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើ ដើម្បីអនុញ្ញាតឱ្យដឹកជញ្ជូនកុងតឺន័រទៅកាន់កំពង់ផែ
- នៅពេលដែលកុងតឺន័រដឹកជញ្ជូនមកដល់កំពង់ផែ មន្ត្រីគយ និងមន្ត្រីអគ្គនាយដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ អាហារ៉ណ-នីហារ៉ណ និងបង្ក្រាបការក្លែងបន្លំ(ការកុងត្រូល)នៃក្រសួងពាណិជ្ជកម្ម រួមគ្នាពិនិត្យ និងផ្ទៀងផ្ទាត់ ទំនិញ ដោយប្រៀបធៀបនឹងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូល-នាំចេញរបស់រដ្ឋបាលព្រៃឈើរួចហើយ ទើបមន្ត្រីគយផ្តល់ឯកសាររដ្ឋបាល SAD
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ពិនិត្យនិងផ្ទៀងផ្ទាត់ចំនួនពន្ធដែលក្រុមហ៊ុនបានបង់រួច។

៣.៥. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាល និងមានអគ្គនាយករងចំនួន៥រូបជាជំនួយការ។ តួនាទីនិងភារកិច្ចសំខាន់ៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា រួមមាន ៖

- ប្រមូលប្រាក់ចំណូល (ពន្ធគយ ពន្ធ ប្រាក់ជាកពិន័យ និងប្រាក់ចំណូល និងកម្រៃសេវាផ្សេងៗទៀត)
- ទប់ស្កាត់ ស្រាវជ្រាវ ត្រួតពិនិត្យ និងបង្ក្រាបរាល់អំពើរត់ពន្ធ ឬបទល្មើសទាក់ទងនឹងពន្ធគយផ្សេងៗទៀត រួមទាំងចរាចរគ្រឿងញៀន រត់ពន្ធទំនិញសាយតេះ ចលនាឆ្លងដែនខុសច្បាប់នៃសារធាតុកាកសំណល់។ល។
- សម្របសម្រួលពាណិជ្ជកម្មក្រៅប្រទេស និងការពារសេដ្ឋកិច្ចនិងពាណិជ្ជកម្មជាតិ
- ប្រមូលចងក្រងស្ថិតិពាណិជ្ជកម្ម វិភាគលំនាំនៃការធ្វើពាណិជ្ជកម្ម និងផ្តល់អនុសាសន៍ដល់អ្នកតាក់តែងគោលនយោបាយ
- ទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មឈើ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ផ្តល់លិខិតអនុញ្ញាតឱ្យអ្នកនាំចូល-នាំចេញ និងត្រួតពិនិត្យទំនិញឈើនាំចូល-នាំចេញ

Photo: Forestry Administration of Cambodia

៤. ព្រៃឈើកម្ពុជា

៤.១ គម្របព្រៃឈើ និងប្រភេទព្រៃឈើ

ប្រទេសកម្ពុជាមានផ្ទៃដីទំហំ ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ដែលមានទន្លេមេគង្គហូរឆ្លងកាត់តំបន់ទំនាប កណ្តាល ពីទិសឧត្តរមកទិសអគ្នេយ៍។ ព្រៃឈើកម្ពុជាមានប្រភេទព្រៃសំខាន់ៗមួយចំនួន ដូចជា ព្រៃស្រោង (មិនមែន អំបូរស្រល់) ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃជាំ ព្រៃលិចទឹក ព្រៃកោងកាង និងព្រៃឫស្សី ដែលស្ថានភាពព្រៃខុសៗគ្នា ចាប់ពីព្រៃក្រាស់ដល់ព្រៃដែលរងការរំខាន និងសណ្ឋានជាស្បែកខ្លា។ ព្រៃស្រោង និងព្រៃល្បោះ គឺជាប្រភេទព្រៃដែលមានចំនួនច្រើនជាងគេ។ ផ្ទៃដីព្រៃឈើសរុបក្នុងឆ្នាំ ២០១០ មានចំនួន១០,៣៦ លានហិកតា គឺប្រហែល ៥៧% នៃផ្ទៃដីប្រទេស ដែលមាន ២៥% ជាព្រៃល្បោះ ១៩% ជាព្រៃស្រោង និង ៧% ជាព្រៃ ពាក់កណ្តាលស្រោង (មើលតារាង ២ និង រូប ២)។

យោងតាមច្បាប់ស្តីពីព្រៃឈើ(រាជរដ្ឋាភិបាលកម្ពុជា២០០២ក) មាត្រា ១០ "គ្រប់ប្រភេទព្រៃផ្តល់ផលទាំងអស់ ជាកម្មសិទ្ធិរបស់រដ្ឋ និងគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ"។ ច្បាប់ស្តីពីព្រៃឈើបានចែងថា ចម្ការឈើឯកជនត្រូវបានលើកទឹកចិត្ត។ ក្នុងគោលបំណងសេដ្ឋកិច្ច ព្រៃធម្មជាតិទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ថ្នាក់ដូចតទៅ (មាត្រា ១០)៖ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ រួមមាន ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមាន៣ប្រភេទ៖

តារាង ២ ស្ថិតិឆ្នាំ២០១០របស់រដ្ឋបាលព្រៃឈើស្តីពីប្រភេទព្រៃ (រដ្ឋបាលព្រៃឈើ ២០១២)

ប្រភេទព្រៃ	ផ្ទៃដី (ហិកតា)	%
ព្រៃស្រោង	3.499.185	19,27
ព្រៃពាក់កណ្តាលស្រោង	1.274.789	7,02
ព្រៃល្បោះ	4.481.214	24,68
ព្រៃផ្សេងៗ	1.108.600	6,10
សរុបផ្ទៃដីព្រៃឈើ	10.363.789	57.07
ដីមិនមែនព្រៃឈើ	7.796.885	42,93
សរុប	**18.160.674**	

រូបទី ២ ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ (រដ្ឋបាលព្រៃឈើ ២០១២)



Land Use classes data from 2002 to 2010

No	FOREST TYPES	FOREST COVER AREA					
		2002		2006		2010	
		Ha	%	Ha	%	Ha	%
1	Evergreen forest	3,720,493	20.49	3,668,902	20.2	3,499,185	19.27
2	Semi evergreen forest	1,455,183	8.01	1,362,638	7.5	1,274,789	7.02
3	Deciduous forest	4,833,887	26.62	4,692,098	25.84	4,481,214	24.68
4	Other forest	1,094,728	6.03	1,007,143	5.55	1,108,600	6.1
	Total forest land	**11,104,291**	**61.15**	**10,730,781**	**59.09**	**10,363,789**	**57.07**
5	Non forest	7,056,383	38.85	7,429,893	40.91	7,796,885	42.93
	TOTAL AREA	**18,160,674**	**100**	**18,160,674**	**100**	**18,160,674**	**100**

១. ព្រៃផ្គត់ផ្គង់ត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ដែលក្នុងនោះ មុខងារការពារត្រូវបានចាត់ទុកជាអាទិភាពបន្ទាប់។ គោលបំណងសំខាន់ របស់ព្រៃផ្គត់ផ្គង់ គឺសម្រាប់ផលិតកម្មផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាព។

ព្រៃផ្គត់ផ្គង់ មានដូចជា ៖

- ព្រៃសម្បទាន
- ព្រៃផ្គត់ផ្គង់ក្រៅតំបន់ព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ
- ព្រៃបម្រុងទុកសម្រាប់ដាំឈើឡើងវិញ ឬចម្ការព្រៃដាំ
- ព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ព្រៃរេចរឹល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង

២. ព្រៃការពារត្រូវបានរក្សាទុកជាចម្បងគឺសម្រាប់ការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ ព្រៃការពារនេះ សម្រាប់គោលបំណងការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ រួមមាន ៖

- រក្សានិយ័តកម្មប្រភពទឹក
- អភិរក្សជីវចម្រុះ ដី ទឹក ទីជម្រាលអាងរងទឹកភ្លៀង
- ព្រៃជម្រកសត្ត្ব មច្ឆាជាតិ ការពារការហូរច្រោះ ការពារការជ្រាបចូលនៃទឹកសមុទ្រ
- រក្សាជីជាតិដី
- មរតកវប្បធ៌មជាតិ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។

ព្រៃការពារនៅក្នុងច្បាប់ស្តីពីព្រៃឈើ គឺពុំចែងអំពីតំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងយុត្តាធិការរបស់ក្រសួងបរិស្ថាននោះទេ តំបន់ការពារធម្មជាតិ គឺស្ថិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ព្រៃការពាររួមមាន ៖

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃរក្សានិយ័តកម្មប្រភពទឹក
- ព្រៃការពារទីជម្រាល
- ព្រៃរំលែកសាន្ត
- សួនភូតគាម
- ព្រៃជំនឿសាសនា

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល-អនុផលព្រៃឈើជាលក្ខណៈប្រពៃណីរបស់សហ-គមន៍មូលដ្ឋាន ដែលមានផលប៉ះពាល់អប្បបរមា។

៣. ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវដាក់ឱ្យស្ថិតនៅ ក្នុងចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូតដល់មានការសម្រេចឱ្យប្រើប្រាស់និងអភិវឌ្ឍន៍ សម្រាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល។

ផ្ទៃដីព្រៃសម្រាប់ផ្ទេររួមមាន ព្រៃឯកជនដែលមានព្រៃដាំ ឬដើមឈើដែលដាំដុះ ឬដុះដោយធម្មជាតិ ដែលបានចុះបញ្ជីកា និងមានប័ណ្ណកម្មសិទ្ធិតាមបទដ្ឋាន និងគោលការណ៍ច្បាប់។ ដីឯកជនដែលបានចុះបញ្ជីគឺជាដីដោយឡូត៍ ដែលជាកម្មសិទ្ធិរបស់បុគ្គលឬគ្រួសារ។ បច្ចុប្បន្នដីឡូត៍ទាំងនោះពុំទាន់មានប័ណ្ណកម្មសិទ្ធិស្របច្បាប់នៅឡើយទេ។ ចាប់តាំងពីឆ្នាំ ២០០៥ មក អ្នកផ្តល់ជំនួយជាទ្វេភាគីនិងពហុភាគីបានសហការជាមួយរដ្ឋាភិបាលក្នុងការផ្តល់ជំនួយដើម្បីដំណើរការចុះបញ្ជីដី ដើម្បីផ្តល់ប័ណ្ណដីកម្មសិទ្ធិជាផ្លូវការដល់ម្ចាស់ដីឯកជនទាំងនោះ។ ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍនិងប្រមូលផលប្រើប្រាស់លក់ចែកចាយ ផលិតផលរបស់ខ្លួនដោយផ្ទាល់។

៤.២. ប្រភេទនៃការប្រើប្រាស់ដីព្រៃ

ប្រទេសកម្ពុជាមានផ្ទៃដីព្រៃឈើទំហំ ១០,៣៦លានហិកតា ស្ថិតនៅក្រោមចំណាត់ថ្នាក់ការប្រើប្រាស់ដីមួយចំនួន ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងពីរ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)។ យោងតាមកម្មវិធីព្រៃឈើជាតិ រាជរដ្ឋាភិបាលបានបែងចែកការប្រើប្រាស់ដីព្រៃឈើទៅជា៥ប្រភេទសំខាន់ៗ។ ក្រសួងបរិស្ថានមានសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិ និងត្រួតពិនិត្យការអនុញ្ញាតផែនការមេ។ល។ តួនាទីនៃរដ្ឋបាលព្រៃឈើក្នុងតំបន់ការពារធម្មជាតិ គឺគ្រាន់តែកត់ត្រាការដកហូតឈើសម្រាប់ការចេញលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ការបង់ថ្លៃ សួយសារ និងចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ការដឹកជញ្ជូនឈើមូល ពីព្រៃមកកាន់រោងចក្រកែច្នៃឈើ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចគ្រប់គ្រងព្រៃការពារ ព្រៃសហគមន៍ ព្រៃសម្បទាន ព្រៃផ្តល់ផល។ រាជរដ្ឋាភិបាលបានបង្ហាញអំពីគោលដៅសម្រាប់គ្រប់គ្រងប្រភេទព្រៃឈើទាំងនេះ ដែលអាចនឹងមានការប្រែប្រួលក្នុងពេលអនុវត្តកម្មវិធីព្រៃឈើជាតិ។

បច្ចុប្បន្ននេះមិនមានការកំណត់ជាក់លាក់ទេអំពីផ្ទៃដី ១,២ លានហិកតា ដែលបានចាត់ថ្នាក់ជាព្រៃផ្តល់ផល ដែលស្ថិតនៅក្រៅព្រៃសម្បទាននៅឡើយ នៅក្នុងកម្មវិធីព្រៃឈើជាតិ។ រដ្ឋបាលព្រៃឈើមានការិយាល័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ដែលមានព័ត៌មានអំពីដីព្រៃឈើកម្ពុជា ហើយអាចបង្កើតផែនទីប្រើប្រាស់ដី ផ្អែកទៅតាមចំណាត់ថ្នាក់នៅក្នុងកម្មវិធីព្រៃឈើជាតិ។ បច្ចុប្បន្ននេះនៅមិនទាន់មានផែនទីបង្ហាញអំពីព្រៃផ្តល់ផលដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើនៅឡើយ។ ដោយហេតុនេះ ផែនទីប្រើប្រាស់ដីព្រៃខាងលើនេះ មិនបង្ហាញអំពីដីព្រៃផ្តល់ផលទេ។

តារាង ៣ ចំណាត់ថ្នាក់ការប្រើប្រាស់ដីបច្ចុប្បន្ន (យោងតាមកម្មវិធីព្រៃឈើជាតិ) ការទទួលខុសត្រូវរបស់ក្រសួង ប្រភេទការប្រើប្រាស់ដី និងទំហំដីប្រហាក់ប្រហែល (ហិកតា) (រាជរដ្ឋាភិបាលកម្ពុជា ២០១០)

ក្រសួងបរិស្ថាន	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ / រដ្ឋបាលព្រៃឈើ			
តំបន់ការពារធម្មជាតិ	ព្រៃការពារ	សហគមន៍ព្រៃឈើ	ព្រៃសម្បទានឯកជន	ព្រៃផ្តល់ផល
3 លាន ហិកតា	1,5 លាន ហិកតា	2 លាន ហិកតា	3,2 លាន ហិកតា	1,2 លាន ហិកតា
ផ្សេងៗ និងមិនប្រើប្រាស់ 200.000 ហិកតា	ផ្សេងៗ និងមិនប្រើប្រាស់ 100.000 ហិកតា	ផ្សេងៗ និងមិនប្រើប្រាស់ 200.000 ហិកតា	ផ្សេងៗ និងមិនប្រើប្រាស់ 300.000 ហិកតា	ផ្សេងៗ និងមិនប្រើប្រាស់ 200.000 ហិកតា
បានប្រើប្រាស់ 2,8 លាន ហិកតា	បានប្រើប្រាស់ 1,4 លាន ហិកតា	បានប្រើប្រាស់ 1,8 លាន ហិកតា	បានប្រើប្រាស់ 2,9 លាន ហិកតា	បានប្រើប្រាស់ 1 លាន ហិកតា

រូបទី ៣ ផែនទីចំណាត់ថ្នាក់ការប្រើប្រាស់ដីនិងព្រៃឈើក្នុងប្រទេសកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០១២)



៤.២.១. តំបន់ការពារធម្មជាតិ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន

ក្រសួងបរិស្ថានជាស្ថាប័នទទួលខុសត្រូវចំពោះការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ។ ក្រសួងបរិស្ថាន ត្រូវបានប្រគល់សិទ្ធិអំណាចឱ្យគ្រប់គ្រងដីព្រៃប្រហែល ៣,២លានហិកតា ដែលត្រូវបានកំណត់ថា ជាតំបន់ការពារធម្មជាតិ រួមទាំងព្រៃលិចទឹកនិងព្រៃកោងកាងដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។ តំបន់ការពារធម្មជាតិ គ្រប់គ្រងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន (មើលតារាង ៤)។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(២០០៨) កំណត់ក្របខ័ណ្ឌការងារសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។ គោលបំណងនៃច្បាប់នេះ គឺដើម្បីធានាដល់ការគ្រប់គ្រង ការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យមានចីរភាពនៅក្នុងតំបន់ការពារធម្មជាតិ។ ច្បាប់នេះទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចដែលពឹងអាស្រ័យលើព្រៃឈើក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងការតាំងទីលំនៅនៅក្នុងតំបន់ការពារធម្មជាតិ។ ច្បាប់នេះបែងចែកតំបន់ការពារធម្មជាតិទៅជា៤តំបន់ សម្រាប់ការប្រើប្រាស់ដី និងការគ្រប់គ្រងតំបន់នីមួយៗ។ តំបន់ទាំងនេះរួមមាន តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ តំបន់ការពារធម្មជាតិ ស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន (ក្រសួងបិស្ថាន ២០១១)។ បញ្ជីឈ្មោះតំបន់ការពារ ធម្មជាតិត្រូវបានដាក់ក្នុង ផែនការសកម្មភាពមួយសម្រាប់ការអនុវត្តកម្មវិធីអនុសញ្ញាស្តីពីជីវចម្រុះក្នុងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា។ ក្រុមការងារសិក្សាបានជួបពិភាក្សាជាមួយក្រសួងបរិស្ថាន ដើម្បីសុំព័ត៌មានស្តីពីប្រព័ន្ធសម្រាប់ការបង្កើតសម្បទានដីសេដ្ឋកិច្ច និងទិន្នន័យអំពីផ្ទៃដី ការត្រួតពិនិត្យ ការប្រមូលផល និងបរិមាណឈើមូលដែលបានដកហូតសម្រាប់ការផ្គត់ផ្គង់ឈើ។ ក្រសួងបរិស្ថាន បានបញ្ជាក់ថា ដោយសារការខ្វះធនធានសម្រាប់សិក្សាអំពីបរិស្ថាន។ បច្ចុប្បន្ន កំពុងតែដំណើរការកំណត់និងបែងចែកតំបន់ប្រើប្រាស់ដីនៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ និងកំពុងតែស្វែងរកជំនួយពីខាងក្រៅដើម្បីជួយគាំទ្រដល់ការងារសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់កំណត់តំបន់ទាំងនេះ។ បច្ចុប្បន្នគេពុំបានដឹងអំពីស្ថានភាពនៃការបែងចែកតំបន់ប្រើប្រាស់ដីនៅក្នុងតំបន់ការពារធម្មជាតិទេ ក៏ប៉ុន្តែក្រសួងបរិស្ថានបានធ្វើការបង្កើតសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ណាដែលគេចាត់ទុកថា មិនមែនជាតំបន់ស្នូលនិងតំបន់អភិរក្ស។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) គឺជាច្បាប់សំខាន់ដែលសំដៅដល់កិច្ចការពារបរិស្ថាន ត្រួតពិនិត្យការបំពុល និងការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា។ គោលបំណងនៃច្បាប់នេះ គឺដើម្បី ៖

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ តាមរយៈការទប់ស្កាត់ ការកាត់បន្ថយ និងត្រួតពិនិត្យការបំពុលបរិស្ថាន
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសំណើទាំងអស់ មុននឹងរាជរដ្ឋាភិបាលចេញសេចក្តីសម្រេចអនុញ្ញាតឱ្យ
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព នូវធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា

តារាង ៤ តំបន់ការពារធម្មជាតិតាមប្រភេទនៃការគ្រប់គ្រង (ក្រសួងបរិស្ថាន ២០១១)

ឈ្មោះខេត្ត	ឈ្មោះ	ប្រភេទតំបន់	ទំហំ (ហិកតា)
កំពង់ស្ពឺ កោះកុង	គិរីរម្យ	ឧទ្យានជាតិ	33 855
កំពត	បូកគោ	ឧទ្យានជាតិ	149 895
កំពត	កែប	ឧទ្យានជាតិ	2 795
ព្រះសីហនុ	រាម	ឧទ្យានជាតិ	32 401
កោះកុង	បុទមសាគរ	ឧទ្យានជាតិ	183 408
សៀមរាប	ភ្នំគូលែន	ឧទ្យានជាតិ	37 373
ស្ទឹងត្រែង រតនគិរី	វីរៈជ័យ	ឧទ្យានជាតិ	334 173
សរុប		**ឧទ្យានជាតិ**	773 900
កោះកុង ពោធិ៍សាត់ កំពង់ឆ្នាំង	ភ្នំឱ៉រ៉ាល់	ដែនជម្រកសត្វព្រៃ	255 036
កោះកុង	ពាមក្រសោប	ដែនជម្រកសត្វព្រៃ	25 897
កោះកុង	ពាមក្រសោប	ដែនជម្រកសត្វព្រៃ	332 566
បាត់ដំបង	រនាមដូនសំ	ដែនជម្រកសត្វព្រៃ	178 750
ព្រះវិហារ សៀមរាប	គូលែន ព្រហ្មទេព	ដែនជម្រកសត្វព្រៃ	402 500
កំពង់ធំ	បឹងពែរ	ដែនជម្រកសត្វព្រៃ	249 694
រតនគិរី មណ្ឌលគិរី	លំជាត់	ដែនជម្រកសត្វព្រៃ	252 575
មណ្ឌលគិរី ក្រចេះ	ភ្នំព្រេច	ដែនជម្រកសត្វព្រៃ	222 500
មណ្ឌលគិរី	ភ្នំណាមលា	ដែនជម្រកសត្វព្រៃ	54 903
ក្រចេះ	ស្ទូល	ដែនជម្រកសត្វព្រៃ	75 335
សរុប		**ដែនជម្រកសត្វព្រៃ**	2 049 756
សៀមរាប	អង្គរ	ការពារទេសភាព	10 800
បន្ទាយមានជ័យ	បន្ទាយឆ្នា	ការពារទេសភាព	81 200
ព្រះវិហារ	ព្រះវិហារ	ការពារទេសភាព	5 000
សរុប		**ការពារទេសភាព**	97 000
កោះកុង	ដងពែង	ប្រើប្រាស់ច្រើនយ៉ាង	27 700
បាត់ដំបង	សំឡូត	ប្រើប្រាស់ច្រើនយ៉ាង	60 000
កំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់	ទន្លេសាប	ប្រើប្រាស់ច្រើនយ៉ាង	316 250
សរុប		**ប្រើប្រាស់ច្រើនយ៉ាង**	403 950
សរុបទាំងអស់		**តំបន់ទាំង ២៣**	**3 324 606**

តំបន់ឧទ្យានជាតិ - ប្រភេទ II នៃ IUCN
តំបន់ដែនជម្រកសត្វព្រៃ - ប្រភេទ IV នៃ IUCN
តំបន់ការពារទេសភាព - ប្រភេទ V នៃ IUCN
តំបន់ប្រើប្រាស់ច្រើនយ៉ាង - ប្រភេទ IV នៃ IUCN

- លើកទឹកចិត្ត និងផ្តល់លទ្ធភាពដល់សាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ទប់ស្កាត់ចំពោះសកម្មភាពទាំងឡាយណាដែលអាចបំផ្លាញបរិស្ថាន។

៤.២.២. ព្រៃការពារដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ

ជាព្រៃឈើដែលមានគោលបំណងសម្រាប់ការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ រួមមាន ៖

- រក្សានិយ័តកម្មប្រភពទឹក
- ការអភិរក្សជីវចម្រុះ ដី ទឹក និងទីជម្រាលផ្ទៃអាងរងទឹកភ្លៀង
- ការពារជម្រកសត្វព្រៃ ជម្រកមច្ឆាជាតិ ការពារការហូរច្រោះ ការទប់ស្កាត់ការជ្រាបចូលនៃទឹក សមុទ្រ
- ការពារជីជាតិដី
- ការពារមរតកវប្បធម៌ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។

ព្រៃការពារដែលស្ថិតនៅក្រោមច្បាប់ស្តីពីព្រៃឈើ គឺមិនបញ្ចូលតំបន់ការពារធម្មជាតិដែលស្ថិតក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថានទេ តែតំបន់ការពារធម្មជាតិមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (មើលតារាង ៥)

តារាង ៥ តំបន់ព្រៃការពារតាមបណ្តាខេត្ត (រាជរដ្ឋាភិបាលកម្ពុជា ២០១២)

ខេត្ត	ឈ្មោះ	ទំហំ (ហិកតា)
មណ្ឌលគិរី	ព្រៃការពារមណ្ឌលគិរី	429.438
មណ្ឌលគិរី	តំបន់ការពារជីវចម្រុះសីម៉ា	292.690
រតនគិរី	តំបន់ព្រៃការពារសម្រាប់រំហែ និងកីឡាប្រមាញ់	101.348
កោះកុង	ច្រករបៀងដំរីភ្នំក្រវ៉ាញភាគខាងត្បូង	144.275
កោះកុង ពោធិ៍សាត់	ព្រៃការពារភ្នំក្រវ៉ាញភាគកណ្តាល	401.313
សៀមរាប កំពង់ធំ	តំបន់អភិរក្សសត្វឱ្យឹប	31.159
ព្រះវិហារ	តំបន់ព្រៃការពារព្រះវិហារ	190.027
បន្ទាយមានជ័យ	តំបន់អភិរក្សសត្វគ្រៀលអាងត្រពាំងថ្ម	12.650
ព្រះសីហនុ	តំបន់ក្បាលឆាយ (ព្រៃកទឹកសាប)	6.202
តាកែវ	ឱទ្យានសួនសត្វភ្នំតាម៉ៅ	2.285
តាកែវ	តំបន់អភិរក្សសត្វគ្រៀល និងបក្សីទឹក	8.205
កំពត	តំបន់អភិរក្សសត្វគ្រៀល និងបក្សីទឹក	217
ស្ទឹងត្រែង	ព្រៃការពារសៀមប៉ាង	66.932
សរុប		**1.646.332**

៤.២.៣. សហគមន៍ព្រៃឈើ

សហគមន៍ព្រៃឈើគឺជាការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើរបស់សហគមន៍មូលដ្ឋាន ដោយមានការគាំទ្រពីរដ្ឋបាលព្រៃឈើទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រជាតិសម្រាប់ការកាត់បន្ថយភាពក្រីក្រ (រាជរដ្ឋាភិបាលកម្ពុជា ២០០២ង) តម្រូវឱ្យគ្រប់វិស័យចូលរួមចំណែកដល់ការសម្រេចគោលបំណងជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ទន្ទឹមនេះ គោលដៅអភិវឌ្ឍន៍សហស្ស-វត្សរ៍កម្ពុជាថា ត្រូវបង្កើនគម្របព្រៃបច្ចុប្បន្នដែលមាន ៥៧% ឱ្យឡើងដល់ ៦០% នៅឆ្នាំ ២០១៥។ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ (រាជរដ្ឋាភិបាលកម្ពុជា ២០០២គ) ផ្តល់អំណាចឱ្យរដ្ឋបាលព្រៃឈើក្នុងការផ្តល់ព្រៃផ្តល់ផលដល់សហគមន៍មូលដ្ឋានសម្រាប់គ្រប់គ្រង និងអាចទទួលផលពីធនធានទាំងនោះ។ សហគមន៍ អាចស្នើសុំរដ្ឋបាលព្រៃឈើ ដើម្បីបង្កើតសហគមន៍ព្រៃឈើនៅក្នុងតំបន់ព្រៃដែលស្ថិតនៅជិតភូមិរបស់គេ ដើម្បីរក្សាសិទ្ធិក្នុងការប្រើប្រាស់ដីព្រៃក្រោមការចុះកិច្ចព្រមព្រៀងរវាងគណៈកម្មការសហគមន៍ព្រៃឈើ និងខណ្ឌរដ្ឋបាលព្រៃឈើ។

ក្នុងខែធ្នូ ឆ្នាំ២០០៣ កម្ពុជាបានអនុម័តអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ(រាជរដ្ឋាភិបាលកម្ពុជា ២០០៣) ដែលធ្វើឱ្យសហគមន៍ព្រៃឈើក្លាយជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ការថែរក្សាគម្របព្រៃឈើ។ សហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីរដ្ឋបាលព្រៃឈើ យោងតាមការស្នើសុំរបស់សហគមន៍ និងក្រោមការចុះកិច្ចព្រមព្រៀង។ សហគមន៍ព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ដែលត្រូវអនុម័តពីរដ្ឋបាលព្រៃឈើ ដើម្បីអនុញ្ញាតឱ្យប្រមូលនិងលក់ដូរផល-អនុផលព្រៃឈើ។ ក្នុងមាត្រា ១២ចែងថា៖ ផ្អែកលើកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ សហគមន៍មានសិទ្ធិដាំ ចាត់ចែងប្រមូលផល-អនុផលព្រៃឈើ និងលក់ប្រភេទឈើផ្សេងៗដូចមានចែងក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍។ កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើមានសុពលភាព មិនលើសពី ១៥ឆ្នាំ និងអាចបន្តកិច្ចព្រមព្រៀងនេះជាថ្មីដែលមិនលើសពីរយៈពេល១៥ឆ្នាំ (យោងតាមមាត្រា ២៧)។

ប្រអប់ ១ ករណីសិក្សា សហគមន៍ព្រៃឈើពូក្រូច នៅខេត្តមណ្ឌលគិរី

ការធ្វើទស្សនកិច្ចនៅភូមិពូក្រូច ក្នុងខេត្តមណ្ឌលគិរី ដើម្បីពិភាក្សាអំពីការអភិវឌ្ឍសហគមន៍ព្រៃឈើមួយដែលមានទំហំ ១.២៣១ ហិកតា និងមានសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍ ដែលបានដាក់ជូនរដ្ឋបាលព្រៃឈើ សុំការអនុម័ត។ គោលបំណងសំខាន់នៃការគ្រប់គ្រង គឺដើម្បីប្រមូលអនុផលព្រៃឈើ ក៏ដូចជា ផលិតកម្មឈើនាពេលអនាគតចំនួន ៣៩ដើម ក្នុង១ឆ្នាំ សម្រាប់ឈើសំណង់។ អង្គការក្រៅរដ្ឋាភិបាលមួយបានជួយក្នុងការរៀបចំសេចក្តីព្រាងផែនការគ្រប់គ្រងនេះ ក៏ប៉ុន្តែ ក្រុមការងារសិក្សាបានកត់សម្គាល់ឃើញថាមានកង្វះខាតជាច្រើននៅក្នុងសេចក្តីព្រាងផែនការគ្រប់គ្រងនេះ។ តួនាទី ការទទួលខុសត្រូវ និងការបែងចែកផលប្រយោជន៍ សម្រាប់សហគមន៍ដែលមានសមាជិកប្រមាណ ៣០០ គ្រួសារនេះ គឺមិនបានកំណត់ច្បាស់ ហើយទិន្នន័យដែលបង្ហាញពីបរិមាណមាឌឈើឈរបច្ចុប្បន្នគឺមាន ១.១០០ម^{3}/ហិកតា គឺជាទិន្នន័យមិនពិត។ សហគមន៍មានគណៈកម្មការគ្រប់គ្រងចំនួន៧ រូប បានធ្វើការជាមួយរដ្ឋបាលព្រៃឈើដើម្បីរៀបចំសេចក្តីព្រាងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើនេះ។ សេចក្តីព្រាងផែនការគ្រប់គ្រងនេះមិនទាន់បានអនុម័តនៅឡើយ ហើយរដ្ឋបាលព្រៃឈើកំពុងតែពិនិត្យសំណើផែនការគ្រប់គ្រងនេះ។

ជាធម្មតា អ្នកភូមិមិនទាន់យល់ច្បាស់អំពីគោលការណ៍មូលដ្ឋានសម្រាប់គ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពនៅឡើយ។ ដូច្នេះ ផែនការគ្រប់គ្រងដែលអាចជឿជាក់បានត្រូវបញ្ជូលគោលការណ៍ណែនាំសម្រាប់ការអនុវត្តឱ្យបានច្បាស់ អំពីផលិតកម្មផលនិងអនុផលព្រៃឈើ និងកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់សមាជិកសហគមន៍ដែលកំពុងធ្វើការងារនៅក្នុងព្រៃឈើ។ គួរតែកំណត់ឱ្យបានច្បាស់អំពីផលប្រយោជន៍សម្រាប់អ្នកធ្វើការផ្ទាល់នៅក្នុងព្រៃ និងសម្រាប់សហគមន៍ទាំងមូល។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៦) បានសង្កត់ធ្ងន់បន្ថែមទៀតអំពីសារសំខាន់នៃការបង្កើតសហគមន៍ព្រៃឈើ និងមានគោលដៅ ២លានហិកតា សម្រាប់ការបង្កើតសហគមន៍ព្រៃឈើនេះ។ បច្ចុប្បន្នផ្ទៃដីសហគមន៍ព្រៃឈើមានប្រហែល២០៧.០០០ហិកតាត្រូវបានចុះហត្ថលេខានិងកំពុងដំណើរការ ទន្ទឹមនេះ មានគម្រោងសហគមន៍ព្រៃឈើប្រហែល ១០០.០០០ ហិកតា បន្ថែមទៀត ត្រូវបានអនុម័ត និងផ្ទៃដី ប្រមាណជិត ១០០.០០០ហិកតា បន្ថែមទៀតកំពុងតែមានផែនការបង្កើត។ ទិន្នន័យ ស្តីពីការអភិវឌ្ឍសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជាបានធ្វើការបោះពុម្ពផ្សាយនៅ ខែមិថុនា ឆ្នាំ២០១៣ ដោយរដ្ឋបាលព្រៃឈើដូចបង្ហាញក្នុងតារាង ៦។

តារាង ៦ សហគមន៍ព្រៃឈើតាមបណ្តាខេត្ត

លរ	ខេត្ត	មានផែនការរៀបចំ		បានអនុម័តរួច		បានចុះកិច្ចព្រមព្រៀង	
		សហគមន៍ព្រៃឈើ	ផ្ទៃដី (ហិកតា)	សហគមន៍ព្រៃឈើ	ផ្ទៃដី (ហិកតា)	សហគមន៍ព្រៃឈើ	ផ្ទៃដី (ហិកតា)
1	កែប	3	1 009	3	1 009	1	60
2	កោះកុង	13	17 514	13	17 514	1	3 046
3	ក្រចេះ	41	59 042	19	29 397	10	17 351
4	កំពង់ចាម	11	3 521	6	1 824	5	1 783
5	កំពង់ឆ្នាំង	34	11 571	15	6 714	15	6 714
6	កំពង់ធំ	82	80 907	64	53 902	57	48 478
7	កំពង់ស្ពឺ	48	19 030	18	8 280	15	5 877
8	កំពត	27	12 530	21	8 703	11	5 720
9	តាកែវ	13	10 791	13	10 791	4	1 843
10	បន្ទាយមានជ័យ	12	4 970	12	4 970	12	4 970
11	បាត់ដំបង	27	9 549	13	3 531	13	3 531
12	ប៉ៃលិន	4	858	4	858	4	858
13	ពោធិ៍សាត់	57	7 460	40	2 841	35	2 504
14	ព្រះវិហារ	21	45 344	18	37 063	8	19 347
15	ព្រះសីហនុ	2	1 274	2	1 274	1	592
16	មណ្ឌលគិរី	4	4 176	4	4 176	0	0
17	រតនគិរី	32	20 838	19	15 712	9	908
18	សៀមរាប	37	18 122	37	18 122	35	17 523
19	ស្ទឹងត្រែង	8	16 208	8	16 208	2	1 370
20	ស្វាយរៀង	2	504	2	504	2	504
21	ឧត្តរមានជ័យ	14	65 168	14	65 168	13	64 318
	សរុប	**492**	**410 386**	**345**	**308 561**	**253**	**207 297**

៤.២.៤. ព្រៃសម្បទាន (ឯកជន)

កម្ពុជាបានបង្កើតប្រព័ន្ធព្រៃសម្បទានក្នុងអំឡុងឆ្នាំ ១៩៩៤ ដល់ ១៩៩៧ ដែលរាជរដ្ឋាភិបាលបានផ្តល់ព្រៃសម្បទានចំនួន ៣៦ ដែលមានផ្ទៃដីព្រៃប្រហែល ៧លានហិកតា (ជិត ៧០% នៃដីព្រៃឈើសរុប) (រាជរដ្ឋាភិបាលគ្មានកាលបរិច្ឆេទ-ក)។ ភាពទន់ខ្សោយក្នុងការគ្រប់គ្រងនិងការត្រួតពិនិត្យព្រៃសម្បទាន បណ្តាលឱ្យរាជរដ្ឋាភិបាលកម្ពុជា ចេញបទបញ្ជាបញ្ឈប់ការធ្វើអាជីវកម្មឈើតាំងពីឆ្នាំ ២០០២ ក្នុងព្រៃសម្បទានទាំងអស់។ បន្ទាប់មក រាជរដ្ឋាភិបាលបានបង្កើតច្បាប់ជាអាទិភាពសម្រាប់ធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយអនុលោមតាមច្បាប់ស្តីពីព្រៃឈើ (រាជរដ្ឋាភិបាលកម្ពុជា ២០០២-ក)។ ព្រៃសម្បទានមួយចំនួនត្រូវបានលុបចោលដោយរាជរដ្ឋាភិបាលដូចនេះ បច្ចុប្បន្ននៅសល់ព្រៃសម្បទាន ប្រមាណជា ៣,៣ លានហិកតាប៉ុណ្ណោះដែលនៅមានសុពលភាព(តារាង ៧)។ អនាគតរបស់ព្រៃសម្បទានទាំងនេះ គឺមិនច្បាស់លាស់ទេ សម្រាប់ក្រុមហ៊ុនព្រៃសម្បទាននៅមានសុពលភាព ព្រោះថាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា ព្រៃសម្បទានទាំងនេះ អាចត្រូវបែងចែកឡើងវិញសម្រាប់ជាព្រៃការពារ និងព្រៃសហគមន៍។ ក្រុមហ៊ុនព្រៃសម្បទានអាចដំណើរការវិញបាន លុះត្រាតែចុះកិច្ចសន្យាសារជាថ្មីជាមួយរដ្ឋបាលព្រៃឈើ បើសិនជាក្រុមហ៊ុនមានផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

តារាង ៧ ព្រៃសម្បទាន(ឯកជន)

ខេត្ត	ឈ្មោះ	ផុតកំណត់	ផ្ទៃដី (ហិកតា)
កំពង់ធំ	សហគ្រាសកូឡ៊ិចស៊ីម		147 187
ក្រចេះ	សហគ្រាសកាសូទីម		131 380
មណ្ឌលគិរី ក្រចេះ កំពង់ចាម	សាមលីងអន្តរជាតិ		467 484
កំពង់ស្ពឺ កោះកុង	សាមលីងអន្តរជាតិ		298 598
ក្រចេះ កំពង់ធំ	ភាពីម៉ិច ហ្ជូឆាង កម្ពុជា		137 475
ស្ទឹងត្រែង	ភាពីម៉ិច ហ្ជូឆាង កម្ពុជា		221 250
ស្ទឹងត្រែង រតនគិរី	ភាពីម៉ិច ហ្ជូឆាង កម្ពុជា		350 000
ព្រះវិហារ	ចិន្តាឌ្ឌាយរ៉ូត កម្ពុជា	2021	103 300
សៀមរាប	សំរោងរ៉ូត		200 050
ក្រចេះ ស្ទឹងត្រែង	អេវ៉ីប្រាយ		136 376
ពោធិ៍សាត់ កំពង់ស្ពឺ	ស៊ូពែរ៉ូត		94 418
កំពង់ចាម ក្រចេះ ព្រះវិហារ	ធីម៉ាស់ រីសោ		161 450
កោះកុង ពោធិ៍សាត់	ស៊ីលវើ៉ូត រ៉ូត ប្រ្ជូដាក		215 460
កោះកុង	ស៊ីលវើ៉ូត រ៉ូត ប្រ្ជូដាក		100 000
ពោធិ៍សាត់ បាត់ដំបង	យ៉ូរីសាគរ		214 000
សៀមរាប ព្រះវិហារ ពោធិ៍សាត់	ធីភីភី		395 900
សរុប			3 374 328

៤.២.៥. ព្រៃផ្តល់ផល

ព្រៃផ្តល់ផល គឺជាព្រៃដែលមានមុខងារចម្បងសម្រាប់ផលិតកម្មផលនិងអនុផលព្រៃឈើ ប្រកបដោយនិរន្តរភាព។ យោងតាមកម្មវិធីព្រៃឈើជាតិ ប្រទេសកម្ពុជាមានព្រៃផ្តល់ផល ចំនួន ១,២លាន ហិកតា ដែលស្ថិតនៅក្រៅដែនព្រៃសម្បទាន។ ព្រៃផ្តល់ផលរួមមាន ៖

- ព្រៃដែលបានអនុញ្ញាតឱ្យប្រមូលផលនៅក្រៅតំបន់ព្រៃសម្បទាន
- ព្រៃរេចរឹល
- ព្រៃត្រូវស្តារឡើងវិញ
- ព្រៃបម្រុងទុកសម្រាប់ការបន្តពូជឡើងវិញ ឬចម្ការព្រៃឈើ
- តំបន់ព្រៃដាំឡើងវិញ
- ព្រៃស្ថិតនៅក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន

ផ្អែកតាមលទ្ធផលនៃការសិក្សាចរាចរឈើ រដ្ឋបាលព្រៃឈើមិនទាន់បានកំណត់តំបន់ព្រៃផ្តល់ផលស្ថិតនៅក្រៅព្រៃសម្បទាននៅតាមខេត្តនីមួយៗ ឬគូរផែនទីព្រៃផ្តល់ផលដែលមានផ្ទៃដីព្រៃ ១,២ ហិកតា ដូចដែលបានកំណត់នៅក្នុងកម្មវិធីព្រៃឈើជាតិនៅឡើយ។

៤.៣. ព្រៃឯកជន/ចម្ការឈើ

ព្រៃឯកជនរួមមាន ចម្ការព្រៃឬចម្ការឈើ ដែលបានមកពីការដាំឈើ ឬដុះដោយធម្មជាតិនៅលើដីឯកជន ដែលបានចុះបញ្ជិកា និងប័ណ្ណកម្មសិទ្ធិស្របច្បាប់។ ដីឯកជនក្រោមការចុះបញ្ជិកា គឺជាដីឡូត៍ កម្មសិទ្ធិរបស់បុគ្គល ឬ គ្រួសារ។ បច្ចុប្បន្ននេះ ភាគច្រើននៃដីឡូត៍ឯកជននៅក្នុងប្រទេសកម្ពុជាមិនទាន់មានប័ណ្ណកម្មសិទ្ធិផ្លូវការនៅឡើយទេ។ ចាប់តាំងពីឆ្នាំ ២០០៥មក អ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី និងរាជរដ្ឋាភិបាលបានផ្តល់ជំនួយគាំទ្រដល់ការចុះបញ្ជីដី ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិជាផ្លូវការដល់ម្ចាស់ដីឯកជន។ កម្មវិធីព្រៃឈើជាតិមានកម្មវិធីមួយស្តីពីការដាំឈើសម្រាប់គោលបំណងប្រើប្រាស់ច្រើនយ៉ាង និងការអភិវឌ្ឍចម្ការឈើ ដើម្បីជាសក្តានុពលក្នុងការផ្គត់ផ្គង់តម្រូវការឈើប្រើប្រាស់ក្នុងស្រុក និង បង្កើនប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន។ ប្រភេទឈើសំខាន់ៗដែលបានដាំ រួមមាន ៖ កៅស៊ូ ប្រេងខ្យល់ អាកាស្យា និងម៉ែសាក់។ ព្រៃឯកជនមិនត្រូវបានគិតថាជាសម្បទានដីសេដ្ឋកិច្ចទេ ព្រោះវាជាកម្មសិទ្ធិរបស់បុគ្គល។

រដ្ឋបាលព្រៃឈើក៏បានបង្កើតចម្ការឈើនៅក្នុងតំបន់ដីព្រៃរបស់រដ្ឋ ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ។ គម្រោងចម្ការឈើត្រូវបានរៀបចំឡើងដើម្បីជម្រុញឱ្យឯកជនធ្វើការដាំឈើ ចំណែកឯសហគមន៍អាចដាំឈើនៅលើដីទំនេររបស់ខ្លួន។

ទិន្នន័យដីដាំឈើរបស់រដ្ឋបាលព្រៃឈើនៅក្នុងស្ថានីយ៍នីមួយៗគឺពុំមានទេ។ មានតែកំណត់ត្រាផ្ទៃដីដាំដុះប្រចាំឆ្នាំប៉ុណ្ណោះដែលបានរក្សាទុក ឃើញមានផ្ទៃដីសរុប ១៤.៣៤៥ ហិកតាដែលបានដាំដុះ ពីឆ្នាំ ១៩៨៥ ដល់ ២០១១។

តារាង ៨ តំបន់ចម្ការឈើ (ស្ថានីយ៍) គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ

ឈ្មោះ	ខេត្ត	ឆ្នាំបង្កើត	ផ្ទៃដីសរុប (ហិកតា)
ទឹកឆារ	កំពង់ចាម	1996	72
មានក	កំពង់ឆ្នាំង	1997	10.000
ភ្នំក្រាយ	កំពង់ស្ពឺ	1988	298
ទួលព្រិច	កណ្តាល	1986	290
ភ្នំអដ្ឋរស្ស	កណ្តាល	1992	20
អង្គរជ័យ	កំពត	1999	3.909
កំចាយមារ	ព្រៃវែង	1995	8.705
រមាសហែក	ស្វាយរៀង	1990	8.002
ក្រសាំង	ស្វាយរៀង	1990	5.012
ភ្នំតាម៉ៅ	តាកែវ	1993	1.300
បន្ទាយអង្គរ	តាកែវ	1987	1.100
ក្បាលឆាយ(ទឹកសាប)	ព្រះសីហនុ	1997	6.027
ត្រពាំងធំ	តាកែវ	1998	1.015
ដងទង់	កំពង់ចាម	1997	4.800
តំបន់ទ្រនាប់ឧទ្យានជាតិភ្នំគូលែន	សៀមរាប	2000	14.000
បឹងលាច	ក្រចេះ	2000	5.662
ភ្នំសម្រុង	ក្រចេះ	1997	4.381
ភ្នំពោន	កែប	2001	32
សាលាក្រៅ	ប៉ៃលិន	2002	200
សរុប			**96.349**

ប្រអប់ ២ ការរកឃើញសំខាន់ៗអំពីព្រៃឈើរបស់ប្រទេសកម្ពុជា

១. រាជរដ្ឋាភិបាលបានកំណត់និងចាត់ថ្នាក់ដី ជាព្រៃឈើលើផ្ទៃដី១០,៨លានហិកតា ដោយយោងទៅតាមគម្រោងព្រៃឈើ ហើយបែងចែកទៅជា៥ប្រភេទដីប្រើប្រាស់តាមមុខងារ ៖ តំបន់ការពារធម្មជាតិ ព្រៃការពារ ព្រៃសហគមន៍ ព្រៃសម្បទាន និងព្រៃផ្តល់ផល បើអនុលោមតាមកម្មវិធីព្រៃឈើជាតិ។

២. បច្ចុប្បន្ន ចំណាត់ថ្នាក់ព្រៃផ្តល់ផល ដែលបានបញ្ជាក់ថាមានផ្ទៃដីសរុបចំនួន ១,២លាន ហិកតា នៅមិនទាន់បានកំណត់ច្បាស់នៅឡើយ ដូចជា ទីតាំង ព្រំប្រទល់ ទំហំដី និងគូរផែនទីតាមឯកតានីមួយៗនៅក្នុងខេត្តនីមួយៗ។

៣. ក្រសួងបរិស្ថានគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយកំណត់តំបន់សម្រាប់ការពារនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស និងតំបន់សម្រាប់ប្រើប្រាស់ដីនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍។ ក៏ប៉ុន្តែ រហូតមកដល់ពេលនេះ ការបែងចែកតំបន់ទាំងនេះនៅក្នុងតំបន់ការពារធម្មជាតិ មិនទាន់បានធ្វើចប់សព្វគ្រប់នៅឡើយ។ តំបន់ប្រើប្រាស់ ដោយចីរភាពនិងតំបន់សហគមន៍អាចប្រើប្រាស់ជាចំណែកមួយសម្រាប់ការផ្គត់ផ្គង់ឈើដោយស្របច្បាប់។

៤. ព្រៃសម្បទានមានប្រហែលជា ៣,៣ លានហិកតា ដែលកំពុងតែស្ថិតនៅក្រោមបទបញ្ជាហាមឃាត់ការប្រមូលផល។ ហើយបច្ចុប្បន្ននេះ គឺមិនមានការផ្តល់វត្ថុធាតុដើមឈើសម្រាប់ការផ្គត់ផ្គង់ឈើទេ។

៥. សហគមន៍ព្រៃឈើមានគោលដៅពង្រីករហូតដល់ ២ លានហិកតា ដែលបច្ចុប្បន្ន សហគមន៍ព្រៃឈើមាន ៣០៨.៥៦១ ហិកតាបានអនុម័ត។ សហគមន៍ព្រៃឈើអាចជាប្រភពឈើមួយសម្រាប់ផ្គត់ផ្គង់ទីផ្សារ។ ការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវការជំនួយគាំទ្រពីរដ្ឋបាលព្រៃឈើ ដើម្បីធានាថាព្រៃឈើត្រូវបានគ្រប់គ្រងល្អ និងផលិតកម្ម ផលនិងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព។

៦. រដ្ឋបាលព្រៃឈើមានស្តានីយ៍ដាំឈើចំនួន៩៦.000 ហិកតា ស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនោះ ផ្ទៃដី ១៤.000 ហិកតាត្រូវបានដាំឈើរួច។ តំបន់ព្រៃឯកជននិងចម្ការឈើដែលស្ថិតនៅក្រៅដីសម្បទានសេដ្ឋកិច្ច គួរត្រូវកំណត់ឱ្យបានល្អ ព្រោះថាតំបន់ទាំងនេះអាចនឹងផ្តល់ឈើដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើនៅកម្ពុជានាពេលអនាគត។

Photo: GFS

៥. ការផ្គត់ផ្គង់ឈើ

ប្រទេសកម្ពុជាមានព្រៃឈើទំហំ ១០,៨ លានហិកតា រួមមាន តំបន់ការពារធម្មជាតិដែលជាចំណែកមួយធំ (៤,៥ លានហិកតា) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន រីឯព្រៃការពារ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាង ៤ លានហិកតា ជាព្រៃសម្បទាន និងព្រៃផ្តល់ផល។ ដោយសារ បទបញ្ជាហាមឃាត់ការកាប់ឈើក្នុងព្រៃសម្បទាន នៅឆ្នាំ ២០០២ ការផ្គត់ផ្គង់ឈើស្ទើរតែទាំងអស់ គឺបានមកពីការប្រមូលផលឈើពីតំបន់កាប់សម្អាតព្រៃដើម្បីផ្ទេរទៅជាចម្ការដាំដុះ ពីគម្រោងអភិវឌ្ឍន៍កសិកម្ម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងដែនសម្បទានដីសេដ្ឋកិច្ច។

ការផ្គត់ផ្គង់ឈើនៅប្រទេសកម្ពុជា គឺគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ ផលិតផលឈើ អាចមានប្រភពមកពីតំបន់ព្រៃផ្តល់ផលដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ឬពីគម្រោងអភិវឌ្ឍន៍ ដូចជា សម្បទានដីសេដ្ឋកិច្ច តំបន់យកវ៉ែ គម្រោងវារីអគ្គិសនី និងគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ក្រសួងបរិស្ថានបានផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍នៅក្នុងតំបន់ការពារធម្មជាតិ។ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ព្រៃការពារ ឬព្រៃផ្តល់ផល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏អាចផ្តល់សម្បទានដីសង្គមកិច្ចផងដែរ សម្រាប់តែការអភិវឌ្ឍសហគមន៍ជនបទ និងការប្រើប្រាស់ជាចម្បងសម្រាប់ផលិតកម្មកសិកម្មខ្នាតតូច និងការពង្រីកភូមិ។ ដើមឈើ ដែលបានកាប់សម្អាតពីតំបន់ដីសម្បទានសង្គមកិច្ច គឺសម្រាប់តែការប្រើប្រាស់របស់សហគមន៍ប៉ុណ្ណោះ គឺមិនសម្រាប់ការធ្វើពាណិជ្ជកម្មទេ ហេតុនេះពុំមានទិន្នន័យឈើពីសម្បទានដីសង្គមកិច្ចសម្រាប់ការសិក្សាអំពីការផ្គត់ផ្គង់ឈើនេះទេ។

៥.១ ព្រៃសម្បទាន

ប្រទេសកម្ពុជា មានព្រៃឈើច្រើនតំបន់ដែលស្ថិតក្រោមរូបភាពជាព្រៃសម្បទាន (៣,៣ លានហិកតា) គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងពុំមានការប្រមូលផលឈើទេ ដោយរាជរដ្ឋាភិបាលបានដាក់បទបញ្ជាបញ្ឈប់ការធ្វើអាជីវកម្មឈើតាំងពីឆ្នាំ២០០២ មក តែនៅមានសុពលភាពកិច្ចព្រមព្រៀងនៅឡើយ។ ការដាក់បទបញ្ជាបញ្ឈប់ការធ្វើអាជីវកម្មឈើនេះ គឺដោយសារតែកង្វះខាតក្នុងការត្រួតពិនិត្យការធ្វើអាជីវកម្មឈើរបស់សម្បទានិក។ ប្រទេសកម្ពុជាបានបោះផ្សាយក្រមបច្ចេកទេសសម្រាប់ការប្រមូលផលឈើក្នុងឆ្នាំ ១៩៩៩ដែលបានទទួលការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ (AUSAID)។ ក្រមនេះមានគោលការណ៍ណែនាំសម្រាប់រៀបចំផែនការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព និងគោលការណ៍បច្ចេកទេសសម្រាប់ការប្រមូលផលឈើផងដែរ។

បទបញ្ជាបញ្ឈប់ការធ្វើអាជីវកម្មឈើនៅមានសុពលភាពនៅឡើយ ក៏ប៉ុន្តែតាមការឱ្យដឹងពីមន្ត្រីរដ្ឋបាលព្រៃឈើថា សម្បទានិកអាចនឹងដាក់សំណើសុំកិច្ចសន្យាសារជាថ្មី ដោយសន្យាថាធ្វើការគ្រប់គ្រងព្រៃសម្បទាននេះឱ្យមាននិរន្តរភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទអាចនឹងយល់ព្រមឱ្យព្រៃសម្បទានទាំងនេះមានដំណើរការឡើងវិញ។ មិនមានកំណត់ត្រាឈើដែលបានដកហូតចេញពីតំបន់ព្រៃសម្បទានទេ។ ព្រៃសម្បទានមួយចំនួនត្រូវបានផ្តល់អាជ្ញាប័ណ្ណជាសម្បទានដីសេដ្ឋកិច្ចរួចទៅហើយ។ ទីតាំងដីសម្បទានសេដ្ឋកិច្ចមិនមានការកំណត់ច្បាស់លាស់ដោយក្រសួងបរិស្ថាន ឬ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីកាត់ចេញតំបន់ព្រៃសម្បទានទេ។

៥.២ ព្រៃផ្តល់ផល-តំបន់ព្រៃគុប

ជម្រើសមួយក្នុងបណ្តាជម្រើសដែលអាចបំពេញការផ្គត់ផ្គង់ឈើសម្រាប់តម្រូវការក្នុងស្រុក ដូចដែលបានលើកឡើងខាងលើ គឺការបង្កើតព្រៃគុបដេញថ្លៃនៅក្នុងព្រៃផ្តល់ផល ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ។ “ព្រៃផ្តល់ផល” នេះ គឺសំដៅទៅតំបន់ព្រៃឈើដែលមិនស្ថិតនៅក្រោមព្រៃសម្បទានដែលនៅមានសុពលភាព។ យោងតាមកម្មវិធីព្រៃឈើជាតិ ព្រៃផ្តល់ផលមាន ១,២ លានហិកតា ដែលភាគច្រើនជាប្រភេទព្រៃស្រោង (មិនមែនអំបូរស្រល់) និងជាទូទៅជាតំបន់សើម។ តំបន់មួយចំនួនធំនៃព្រៃផ្តល់ផលដែលស្ថិតនៅក្រៅព្រៃសម្បទាន ត្រូវបានគេកាប់ឈើនិងបំផ្លាញនៅក្នុង ប៉ុន្មានទសវត្សរ៍ កន្លងមក ក៏ប៉ុន្តែនៅមានព្រៃខ្លះមិនទាន់បានធ្វើអាជីវកម្មដែរ។ រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ គ្រប់គ្រងនិងបែងចែកតំបន់ព្រៃផ្តល់ផលជាគុបដេញថ្លៃប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនឯកជនដេញថ្លៃ។ ព្រៃផ្តល់ផល ចំនួន ១,២ លានហិកតា មិនទាន់បានកំណត់ច្បាស់នៅលើផែនទី ឬកំណត់ទៅតាមខេត្ត ទាំងទីតាំង និងទំហំព្រៃ។ ហេតុនេះ គេមិនអាចយល់ដឹងច្បាស់លាស់អំពីសក្តានុពលឈើដែលអាចផ្គត់ផ្គង់ចេញពីតំបន់ព្រៃផ្តល់ផលទាំងនេះទេ។

ប្រអប់ ៣ ករណីសិក្សានៅខេត្តមណ្ឌលគិរី

នៅពេលធ្វើទស្សនកិច្ចសិក្សានៅខេត្តមណ្ឌលគិរី ខណ្ឌរដ្ឋបាលព្រៃឈើបានរៀបចំផែនការព្រៃគុបចំនួន ៤ សម្រាប់ការប្រមូលផលឈើ ដែលមានផ្ទៃដីសរុប ៥.០០៦ ហិកតា។ ពេលនោះ មានតែព្រៃគុបលេខ៤ ដែលមានដំណើរការនៅលើដីព្រៃ ១.៣៤២ ហិកតា និងបែងចែកជា ៨ ប្លុក។ ព្រៃគុបនេះមានផែនការមេ និងធ្វើសារពើភ័ណ្ឌឈើ ស្របតាមគោលការណ៍គ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព និងការកាប់ដកហូតឈើដោយការជ្រើសរើស។ ទិន្នន័យសារពើភ័ណ្ឌព្រៃបានប៉ាន់ស្មានថាមានឈើសរុប ៦.០៨៦ m^3 ជាឈើពាណិជ្ជកម្មដែលមានអង្កត់ផ្ចិតធំជាង ៤៥ស.ម ដែលជាមធ្យមគឺមានតែ ៤,៥m^3 ប៉ុណ្ណោះក្នុង១ហិកតា។ មន្ត្រីរដ្ឋបាលព្រៃឈើបានដៅដើមឈើសម្រាប់ការកាប់ដកហូតឈើ ទៅតាមផែនការគ្រប់គ្រងព្រៃឈើ។

ទិន្នផលឈើប្រមូលបានជាក់ស្តែងក្នុងព្រៃគុបលេខ៤ មាន ៤.៤៥៦,៥m^3 ដែលគិតជាមធ្យម គឺបានតែ ៣,៣m^3 ក្នុង១ ហិកតា ដែលចាត់ទុកថាជាចំនួនតិចបំផុត។ ភាគច្រើននៃការធ្វើអាជីវកម្មព្រៃគុប គឺត្រូវមានទិន្នផលឈើ ពាណិជ្ជកម្មលើសពី២០m^3 ក្នុង១ ហិកតា ដើម្បីធានាថាការប្រមូលផលឈើមានលក្ខណៈសេដ្ឋកិច្ច។ ការធ្វើអាជីវកម្មឈើនៅក្នុងព្រៃគុបលេខ៤ បានចប់សព្វគ្រប់នៅ ខែកក្កដា ឆ្នាំ២០១៣។

រាជរដ្ឋាភិបាលមានព្រៃគុបតែមួយគត់សម្រាប់ឆ្នាំ២០១២ ដែលស្ថិតក្នុងព្រៃផ្តល់ផលនៃប្រទេសកម្ពុជា ដូច្នេះព្រៃគុបនេះ ជាចំណែកមួយដ៏ស្តួចស្តើងសម្រាប់ការផ្គត់ផ្គង់ឈើនាបច្ចុប្បន្ននេះ (តារាង ៩)។

តារាង ៩ អាជ្ញាប័ណ្ណព្រៃគុបនៅក្នុងព្រៃផ្តល់ផល

ខេត្ត	តំបន់អនុញ្ញាត	ផ្ទៃដី (ហិកតា)	មាឌធ្វើសារពើភ័ណ្ឌ (m^3)	មាឌប្រមូលផល	ផុតកំណត់
មណ្ឌលគិរី	គុបលេខ ៤	1 342	6 086.6	4 456.5	កក្កដា ២០១៣
សរុប		**1 342**	**6 086.6**	**4 456.5**	

៥.៣ សម្បទានដីសេដ្ឋកិច្ច - ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ប្រភពផ្គត់ផ្គង់ឈើសំខាន់ក្នុងប្រទេសកម្ពុជា គឺបានមកពីដីសម្បទានសេដ្ឋកិច្ចដែលស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឬក្រសួងបរិស្ថាន។ សម្បទានដីសេដ្ឋកិច្ច ត្រូវបានឯកភាពនិងចុះបញ្ជីកា អនុលោមទៅតាមច្បាប់ភូមិបាលឆ្នាំ ២០០១ (រាជរដ្ឋាភិបាលកម្ពុជា ២០០១-ค) ដែលបញ្ជាក់អំពីចំណាត់ថ្នាក់ដី និង កម្មសិទ្ធិដី។ ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងអំពីសម្បទានដីសង្គមកិច្ច សិទ្ធិកាន់កាប់ដី របស់ជនជាតិដើមភាគតិច ការចុះបញ្ជីកា និងការដោះស្រាយទំនាស់ដីធ្លី។ ច្បាប់ភូមិបាលផ្តល់អំណាចក្នុងការផ្តល់សម្បទានដីសម្រាប់គោលបំណង សេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ គឺផ្តល់ដោយក្រសួងបរិស្ថាន និងនៅក្នុងតំបន់ព្រៃផ្សេងៗទៀត គឺផ្តល់ដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់សម្បទានដីសេដ្ឋកិច្ច ដោយអនុលោមទៅតាមអនុក្រឹត្យ ១៤៦ អនក្រ.បក និងក្រោមមាត្រា ៣៧ ថា ដីសម្បទានសេដ្ឋកិច្ចត្រូវបានកំណត់ត្រឹម ១០.០០០ ហិកតា ប៉ុន្តែអាចមានធំជាងនេះ ដោយយោងទៅតាមមាត្រា ៣៩(មើលប្រអប់ ៤)។

ប្រអប់ ៤ ខ្លឹមសារសង្ខេបក្នុងអនុក្រឹត្យស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ធ្នូ ២០០៥

អាជ្ញាធរផ្តល់កិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ និងប្រើអំណាចនេះដែលនាយករដ្ឋមន្ត្រីផ្តល់ឱ្យសម្រាប់ការផ្តល់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ក្នុងនាមរាជរដ្ឋាភិបាលដើម្បីបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ។

ស្ថាប័នបទប្បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់ឱ្យអនុវត្តនូវវិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។

លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច (ដែលមានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។

លេខាធិការដ្ឋានបច្ចេកទេសធ្វើការត្រួតពិនិត្យឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ច (ឯកសារគម្រោងត្រូវរួមមាន ផែនការមេ ផែនការសកម្មភាពលម្អិតសម្រាប់ការកាប់ឈើ និងការដាំដុះ) និងធ្វើការពិគ្រោះជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ ខេត្ត និងស្ថាប័នបទប្បញ្ញត្តិ។

លេខាធិការដ្ឋានបច្ចេកទេសរៀបចំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (ESIA) របស់គម្រោងសំណើសម្បទានដីសេដ្ឋកិច្ច (ដែលត្រូវធ្វើការពិគ្រោះយោបល់លម្អិតជាមួយអ្នកពាក់ព័ន្ធនៅគ្រប់ថ្នាក់ និងសហគមន៍មូលដ្ឋាន)។

ក្រោយពីទទួលបានអនុសាសន៍វិជ្ជមានពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមក លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំលក្ខខណ្ឌការងារយោង (ToR) សម្រាប់ដាក់សំណើសុំគម្រោង ដោយត្រូវភ្ជាប់មកជាមួយឯកសារ៖

- សំណើគម្រោងសម្បទានដីសង្គមកិច្ច និងឯកសារគាំទ្រ
- ផែនការអាជីវកម្មលម្អិតអំពី ផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូលចំណាយសម្រាប់អភិវឌ្ឍន៍ដី និងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទានដីនេះ
- សេចក្តីពណ៌នាអំពីតម្រូវការកម្លាំងពលកម្ម និងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទានដីនេះ
- ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាពដែលគ្រោងនឹងប្រើប្រាស់
- ការបង្ហាញពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការ ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន
- ការពិពណ៌នាអំពីទំនាក់ទំនង និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការពិពណ៌នាអំពីការកែច្នៃវត្ថុធាតុដើមដែលប្រមូលពីក្នុងស្រុក ប្រសិនបើមាន
- ថ្លៃឈ្នួលប្រើប្រាស់ដីដែលអ្នកដាក់សំណើ ផ្តល់ជូនរដ្ឋ
- ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទានដោយម្ចាស់សំណើ ប្រសិនបើមាន ស្របតាមការចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល
- កិច្ចធានានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំកិច្ចប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារសំណើយ៉ាងតិច ៣០ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើ និងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានលើកឡើង។ លេខាធិការដ្ឋានបច្ចេកទេសត្រូវបោះផ្សាយនូវពិន្ទុនៃការធ្វើចំណាត់ថ្នាក់គម្រោងសំណើនីមួយៗ ដោយផ្អែកលើលក្ខខណ្ឌដែលបានកំណត់។ គម្រោងសំណើដែលបានទទួលចំណាត់ថ្នាក់ខ្ពស់ជាងគេ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការចរចាផ្តល់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។

ដីសម្បទានសេដ្ឋកិច្ចមួយចំនួន មានទំហំធំជាង ១០.០០០ ហិកតា ហើយស្ទើរតែទាំងអស់នៃសម្បទានដីសេដ្ឋកិច្ច គឺមានកិច្ចសន្យារយៈពេល ៧០ ឬ ៩០ឆ្នាំ។ ក្រសួងបរិស្ថាន ផ្តល់សម្បទានដីសេដ្ឋកិច្ច ដោយអនុលោមតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ខែមករា ឆ្នាំ២០០៨ នៅពេលដែលរាជរដ្ឋាភិបាល អនុញ្ញាតឱ្យមានសកម្មភាពអភិវឌ្ឍន៍ និងវិនិយោគនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព។ គោលបំណងនៃតំបន់ប្រើប្រាស់ដោយចីរភាព គឺដើម្បីបង្កើតឡើងនូវតម្លៃសេដ្ឋកិច្ចខ្ពស់សម្រាប់ការគ្រប់គ្រងនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាការរួមចំណែកដល់សហគមន៍មូលដ្ឋាន និងលើកកម្ពស់ជីវភាពដល់សហគមន៍ជនជាតិដើមភាគតិច។ ដំណើរការចុះបញ្ជីការនៃការផ្តល់សម្បទានដី សេដ្ឋកិច្ច រួមមាន ការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់និងនីតិវិធី។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអំណាចនិងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគចាប់ពីពី ២.៥០០ ដុល្លាស.រ.អា(១០.០០០.០០០ រៀល) ឡើងទៅ ឬមានទំហំដីសម្បទានចាប់ពី ១.០០០ហិកតាឡើងទៅ។

ក្រសួងបរិស្ថានមានអំណាច និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់បណ្តាក្រុមហ៊ុនឯកជន (ទាំងក្នុងស្រុកនិងបរទេស) នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ដោយផ្អែកតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨)។ តំបន់សម្បទានដីសេដ្ឋកិច្ចណាដែលផ្តល់ដោយក្រសួងបរិស្ថាននៅមុនច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ ត្រូវបានផ្ទេរទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអ្នកគ្រប់គ្រងវិញ។

ក្នុងរយៈពេលចុះវាយតម្លៃនៅទីវាលក្នុងខេត្តមណ្ឌលគិរី ក្រុមការងារសិក្សាបានសង្កេតឃើញអំពីដំណើរការចុះបញ្ជីកាដីសម្បទានសេដ្ឋកិច្ចក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ក៏ឃើញមានការចូលរួមរបស់គណៈកម្មាធិការចម្រុះព្រំដែនផងដែរ បន្ថែមទៅក្នុងនីតិវិធីដែលមាននៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ២០០៨ ព្រោះថាសំណើសុំដី សម្បទានេះស្ថិតនៅជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម។ ដំណើរការមានដូចតទៅ ៖

១. ក្រុមហ៊ុនដាក់ពាក្យស្នើសុំទៅក្រសួងបរិស្ថាន(អាជ្ញាធរផ្តល់កិច្ចសន្យា)។ ក្នុងសំណើជាផ្លូវការថា សម្រាប់ការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម ដូចជា ការដាំដំណាំកៅស៊ូ។

២. ក្រសួងបរិស្ថានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដែលមានសមាសភាពមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច។

៣. ក្រសួងបរិស្ថានដាក់សំណើស្នើសុំសម្បទានដីសេដ្ឋកិច្ចនេះទៅឧទ្ធកាល័យនាយករដ្ឋមន្ត្រី។

៤. ឧទ្ធកាល័យនាយករដ្ឋមន្ត្រីដាក់សំណើស្នើសុំនេះ ទៅស្នើសុំការឯកភាពពីព្រះមហាក្សត្រ។

៥. គណៈរដ្ឋមន្ត្រីចេញលិខិតឯកភាពតាមសំណើសុំ ដែលអាចមានការកែសម្រួលមួយចំនួន ដូចជាការប្តូរសមត្ថកិច្ចពីក្រសួងបរិស្ថាន ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញជាដើម។

៦. ចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលស្ថិតតាមបណ្តោយព្រំដែនប្រទេសកម្ពុជា ត្រូវមានការចូលរួម និងការឯកភាព ពីគណៈកម្មាធិការចម្រុះព្រំដែន ក្នុងការកំណត់តំបន់ទ្រនាប់ (តំបន់ស) តាមបណ្តោយព្រំដែន។

៧. នាយករដ្ឋមន្ត្រីផ្តល់សិទ្ធិអំណាចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងការចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច។

៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនដើម្បីបង្កើតសម្បទានដី សេដ្ឋកិច្ច អនុលោមតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច លេខ ១៤៦ អនក្រ.បក។

បច្ចុប្បន្ន ទិន្នន័យនិងស្ថានភាពអំពីការបង្កើតសម្បទានដីសេដ្ឋកិច្ច មិនមានការបោះផ្សាយដោយក្រសួងទាំងពីរនេះទេ (ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ក្រុមការងារសិក្សាបានសង្កេតឃើញថា ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគីរីមានផែនទីថ្មីៗអំពីដីសម្បទានសេដ្ឋកិច្ច។ ទិន្នន័យដទៃទៀតដែលបានមកពីអង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញឱ្យឃើញថាមានតំបន់ដូចគ្នា ហើយមានតំបន់មួយចំនួនក៏ខុសគ្នាដែរ (មើលតារាង ១០)។

ទិន្នន័យរបស់ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគីរី និងគេហទំព័រ Open Development គឺមានទិន្នន័យដូចគ្នា ចំនួន១២ក្នុងចំនួនសរុប ២៥ តំបន់ដីសម្បទានសេដ្ឋកិច្ច ដែលបានបង្កើតក្នុងខេត្តមណ្ឌលគីរី។ គេហទំព័រ Open Development មានបញ្ជីសរុបចំនួន ២២ តំបន់ដីសម្បទានសេដ្ឋកិច្ច ក៏ប៉ុន្តែខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគីរី មានតែ១៨ តំបន់ដីសម្បទានសេដ្ឋកិច្ច។ តារាង១០ បង្ហាញភាពប្រែប្រួលនៃតួលេខដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងខណ្ឌរដ្ឋបាលព្រៃឈើ។ គោលបំណងសំខាន់មួយនៃការសិក្សាអំពីចរាចរឈើនេះ គឺដើម្បីកំណត់ឱ្យបានច្បាស់ទាំងការផ្គត់ផ្គង់ឈើ ក៏ដូចជា ប្រព័ន្ធប្រើប្រាស់សម្រាប់ត្រួតពិនិត្យចរាចរឈើពីតំបន់ដែលមានអាជ្ញាប័ណ្ណឆ្លងតាមខ្សែសង្វាក់ផ្គត់ផ្គង់ឈើរហូតដល់ការនាំចេញផលិតផលឈើ។ ដូចនេះ តំបន់ផ្គត់ផ្គង់ឈើគឺមានសារសំខាន់ សម្រាប់ការសិក្សា ក្នុងការវាយតម្លៃអំពីលទ្ធភាពតាមដាន ដើម្បីឆ្លើយតបតាមច្បាប់របស់សហភាពអឺរ៉ុប ស្តីពីឈើពាណិជ្ជកម្ម និងសម្រាប់សក្តានុពលការចរចាកិច្ចព្រមព្រៀង VPA នាពេលអនាគត។

តំបន់ និងទីតាំងនៃសម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនមានការបោះផ្សាយដោយក្រសួងទាំង២នេះទេ ដូច្នេះហើយ ក្រុមការងារសិក្សាក៏មិនមានព័ត៌មានសម្រាប់សិក្សាដែរ។ ព័ត៌មានស្តីពីផ្ទៃដីសម្បទានសេដ្ឋកិច្ច ដែលមានប្រភព ក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (http://www.elc.maff.gov.kh 2013) បានបង្ហាញថា ៖ “មកដល់ខែមិថុនា ឆ្នាំ២០១២ សរុបផ្ទៃដីសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា មានចំនួន១១៨ ក្រុមហ៊ុនមានផ្ទៃដីសរុប ១.២០៤.៧៥០ ហិកតា”។ បច្ចុប្បន្ន គេអាចរកបានបញ្ជីឈ្មោះនិងផែនទីរបស់សម្បទានដីសេដ្ឋកិច្ចតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ដែលមិនមែនផ្លូវការ ហើយអាចមានទិន្នន័យខុសគ្នាស្តីពីតំបន់ជាក់ស្តែងដែលក្រសួងទាំង២នេះបានផ្តល់ឱ្យ។ (ឧបសម្ព័ន្ធ ៣)

តារាង ១០ បញ្ជីតំបន់ដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តមណ្ឌលគិរី (យោងតាមប្រភពព័ត៌មានពីខណ្ឌរដ្ឋបាលព្រៃឈើ មណ្ឌលគិរី និងគេហទំព័រ Open Development)

លរ	ឈ្មោះក្រុមហ៊ុន	គេហទំព័រ Open Development ២០០៣	ខណ្ឌរដ្ឋបាលព្រៃឈើ មណ្ឌលគិរី ទិន្នន័យផែនទី ២០១២
		ផ្ទៃដី (ហិកតា)	ផ្ទៃដី (ហិកតា)
1	Wuzhishan L.S Group	10 000	0
2	Coviphama Co., Ltd	5 345	5 345
3	Agro Forestry Research	7 000	7 000
4	DTC Group Co., Ltd.	4 000	4 000
5	Land and Developing (Cambodia)	7 000	7 000
6	Mo Hy Pa Masu Orn Kampuchea Co	7 800	7 800
7	Mondul Agri-Resource Co., Ltd	9 100	10 570
8	Seang Long Green Land Investment	7 000	7 000
9	Unigreen Resource Co., Ltd.	8 000	8 000
10	Sitthi Agriculture Plantation Co., Ltd.	522	0
11	Villa Development	825	0
12	Sethikula Co., Ltd.	4 273	0
13	Pacific Lotus Joint-Stock Company	9 014	9 014
14	Pacific Pearl Joint-Stock Company	9 614	9 614
15	Pacific Grand Joint-Stock Company	9 656	9 656
16	Pacific Pride Joint-Stock Company	9 773	9 773
17	Mega First Corporation Berhad	9 477	0
18	Huor Ling (Cambodia) International Insurance (Forestry Administration Vogisan)	8 400	10 000
19	Kasekam Khmer Angkor Co., Ltd.	9 160	0
20	Heng Hean Siv Chan Tour Trading Co., Ltd.	4 000	4 000
21	Lim Royal Joint Stock Co., Ltd.	9 068	0
22	Benh Hoeurk Kratie Rubber (Forestry Administration Binh Phuoc)	8 926	10 000
23	Varanacy	0	2 346
24	Dak Lak	0	4 162
25	Tach Wood	0	11 642
	Totals	**157 953**	**126 932**

តំបន់សម្បទានដីសេដ្ឋកិច្ចដែលបានគូរជាផែនទីដោយអង្គការមិនមែនរដ្ឋាភិបាល Open Development គឺផ្អែកលើទិន្នន័យដែលបានផ្សព្វផ្សាយដោយរដ្ឋាភិបាលក្នុងអំឡុងដំណើរការចុះបញ្ជិកា ហើយអង្គការនេះទទួលបានព័ត៌មាននៅពេលនោះ។ ការសិក្សាអំពីចរាចរណ៍ដាក់ផែនទីតំបន់សម្បទានដីសេដ្ឋកិច្ចមិនផ្លូវការ ផ្អែកលើទិន្នន័យ និងឯកសារទន់ (shape files) របស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជាព័ត៌មានយោងនៃបញ្ជីសម្បទានដីសេដ្ឋកិច្ចតាមប្រភេទការប្រើប្រាស់ដី (រូបទី ៤)។ ចំនួនហិកតាដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ផែនទី គឺបានមកពីទិន្នន័យ ដែលបោះផ្សាយដោយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដែលបញ្ជីនេះមាននៅក្នុងរបាយការណ៍នេះ។ ដូច្នេះតំបន់ដែលបានកំណត់ដោយឯកសារទន់ (shape files) គ្រាន់តែបង្ហាញនូវអ្វីដែលមានជាក់ស្តែងក្នុងកំណត់សម្គាល់របស់ផែនទីប៉ុណ្ណោះ។

រូបទី ៤ ផែនទីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៣ (Open Development Cambodia 2013 shape files)



ទាំងក្រសួងបរិស្ថាន និងទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសុទ្ធតែតម្រូវឱ្យរៀបចំផែនការមេ ដើម្បីកំណត់ឱ្យបានច្បាស់អំពីផ្ទៃដីដែលត្រូវដាំដុះពិតប្រាកដក្នុងដីសម្បទានសេដ្ឋកិច្ច និងតំបន់ ត្រូវរក្សាទុកសម្រាប់ការពារ (រូបទី ៥)។ តំបន់ត្រូវរក្សាទុកសម្រាប់ការពារ រួមមានប្រព័ន្ធផ្លូវទឹកដែលជាទូទៅគឺជាតំបន់ព្រៃមាត់ទឹក តំបន់ទីជម្រាលខ្លាំង និងតំបន់សហគមន៍។ ការរៀបចំផែនការមេ រួមមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ដើម្បីកំណត់អំពីផលប៉ះពាល់ទៅលើបរិស្ថាន ក៏ដូចជាតំបន់ដែលសហគមន៍កំពុងប្រើប្រាស់ និងអំពីផលប៉ះពាល់សង្គម ទៅលើសហគមន៍មូលដ្ឋាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម គឺមានសារសំខាន់ជាទីបំផុតសម្រាប់កំណត់តំបន់ សម្រាប់ដាំដុះពិតប្រាកដ ដែលជាមូលដ្ឋាននៃការកាត់បន្ថយផល

ប៉ះពាល់ដល់សង្គម និងបរិស្ថានរបស់គម្រោង។ ការវាយតម្លៃផលប៉ះពាល់សង្គម គួរកំណត់ផ្ទៃដីទាំងឡាយណាដែលអាចជាន់គ្នាលើដីមានទំនាស់ ដែលក្រុមហ៊ុនត្រូវធ្វើការដោះស្រាយដោយកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច ឬតាមរយៈការចូលរួមរបស់សហគមន៍ ដើម្បីបង្កើតឡើងកិច្ចព្រមព្រៀង ដែលមានផលប្រយោជន៍ទាំងសងខាង។ តំបន់ទ្រនាប់សម្រាប់ផ្លូវទឹក ព្រៃស្រោង និងព្រៃដាំចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

រូបទី ៥ ឧទាហរណ៍អំពីផែនទីប្រើប្រាស់ដីក្នុងផែនការមេរបស់ក្រុមហ៊ុន COVIPHAMA CO.,LTD



Photo: GFS

ជាធម្មតា ការបែងចែកប្លុកនៅក្នុងផែនការមេរបស់សម្បទានដីសេដ្ឋកិច្ច គឺមានទំហំប្រមាណជា ១.000 ហិកតា ដែលជាប្លុកសម្រាប់ធ្វើការកាប់សម្អាត ការរៀបចំដី និងការដាំដុះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ការអនុញ្ញាតដោយឡែកៗពីគ្នាសម្រាប់ការប្រមូលផលឈើ និងកាប់សម្អាតព្រៃតាមប្លុកនីមួយៗ ក្នុងដីសម្បទានសេដ្ឋកិច្ច។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការសិក្សាដោយធ្វើការបែងចែកទូត៍គ្រូជាប្រព័ន្ធនៅប្លុកដើម្បីធ្វើការប៉ាន់ស្មានមាឌឈើសម្រាប់បង់ថ្លៃសួយសារ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់លិខិតអនុញ្ញាតឱ្យធ្វើការកាប់សម្អាតព្រៃ តាមប្លុកប្រមូលផលដោយឡែកៗពីគ្នា។ សកម្មភាពសិក្សាអំពីធនធានព្រៃជាផ្នែកមួយនៃសកម្មភាព ប្រតិបត្តិការនៅក្នុងតំបន់នោះ ការរៀបចំផែនការមេត្រូវបានបញ្ចប់និងទទួលបានការអនុម័តមុនការបញ្ចប់ការសិក្សាអំពីធនធានព្រៃឈើ ដូចបានសង្កេតឃើញនៅក្នុងក្រុមហ៊ុន សៀងឡុងគ្រីនឡែនអ៊ិនវេសមែន។

ក្រសួងបរិស្ថានមិនបានរក្ខាសារពើភ័ណ្ឌព្រៃក្នុងដីសម្បទានសេដ្ឋកិច្ច មុនពេលកាប់ឈើនោះទេ តែមានការកត់ត្រាឈើមូលដែលបានផលិតពីដីសម្បទានសេដ្ឋកិច្ច ហើយកត់ត្រាទៅក្នុងបញ្ជីបញ្ជីផល-អនុផលព្រៃឈើ ក្នុងជំហាននីមួយៗ (អនុប្លុក) នៅក្នុងប្លុកប្រមូលផលមួយ។ ប្លុកប្រមូលផលត្រូវបានកំណត់នៅក្នុងផែនការមេ អាស្រ័យតាមតំបន់ដែលបានកំណត់ សម្រាប់ប្រមូលផល ដោយដកចេញនូវតំបន់ត្រូវរក្សាទុកសម្រាប់ការពារ ដូច្នេះមិនមានទំហំ ស្តង់តា (និយាម) សម្រាប់ការបង្កើតប្លុកនោះទេ។ ពុំមានទិន្នន័យសារពើភ័ណ្ឌព្រៃសម្រាប់ធ្វើការប៉ាន់ស្មានមាឌឈើ ដែលត្រូវប្រមូលផលឈើពីតំបន់ដីសម្បទានសេដ្ឋកិច្ចទេ។ ការធ្វើសារពើភ័ណ្ឌព្រៃគឺមានសារសំខាន់ណាស់ សម្រាប់ប៉ាន់ស្មាន អំពីទិន្នផលបរិមាណឈើមូលកូនឈើ និង អុស សម្រាប់ការតាមដាននិងត្រួតពិនិត្យការដកហូតផល-អនុផលព្រៃឈើ និងអាចប្រើប្រាស់សម្រាប់ធ្វើការប្រៀបធៀបរវាងទិន្នផលប៉ាន់ស្មានក្នុងសារពើភ័ណ្ឌព្រៃ និងបរិមាណប្រមូលផលជាក់ស្តែងក្នុងប្លុកប្រមូលផល។

មន្ត្រីក្រសួងបរិស្ថានធ្វើការត្រួតពិនិត្យសៀវភៅឈើ ដោយយកមូលដ្ឋាន ៣0% ជាគំរូសំណាកនៃឈើមូលទាំងអស់ដែលបានដកហូតដែលបានកាប់ត្រឹមគល់ឈើនៅក្នុងប្លុក ហើយចេញរបាយ-ការណ៍ត្រួតពិនិត្យឱ្យ បើសិនជាការវាស់ឈើនេះអាចទទួលយកបាន។ ប្រសិនបើការវាស់វែងមិនត្រឹមត្រូវ នោះរដ្ឋបាលព្រៃឈើស្នើឱ្យត្រូវវាស់ឈើមូលទាំងអស់ឡើងវិញ។ មន្ត្រីផ្នែករដ្ឋបាល

ព្រៃឈើវាយញញួរត្រាចំនួនមួយលើកំណាត់ឈើមូលនីមួយៗ បញ្ជាក់ថាកំណាត់ឈើទាំងនេះត្រូវបានវាស់រួច។ រដ្ឋបាលព្រៃឈើ ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើឱ្យសម្បទានិក ដើម្បីបង់ថ្លៃសួយសារនៅរតនាគារជាតិ។ ក្រសួងបរិស្ថានចេញលិខិតឯកភាពឱ្យក្រុមហ៊ុនទៅបង់ថ្លៃសួយសារតាមប្រភេទនិងមាឌឈើ (ម^{3}) ដែលរួមមាន ៖ ឈើមូល (អង្កត់ផ្ចិតធំជាង ៣០ ស.ម) កូនឈើ (អង្កត់ផ្ចិតតូចជាង ៣០ ស.ម) និងអុស។ ការបង់ថ្លៃសួយសារមានតម្លៃខុសគ្នាៗរវាងឈើមូល កូនឈើ និងអុស។ រតនាគារចេញបង្កាន់ដៃបង់ថ្លៃសួយសារឱ្យក្រុមហ៊ុនៗ យកបង្កាន់ដៃនេះទៅស្នើមន្ត្រីផ្នែករដ្ឋបាលព្រៃឈើ ដើម្បីវាយញញួរត្រាចំនួនបីទៀតលើកំណាត់ឈើ ហើយផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកឈើពីដីសម្បទានសេដ្ឋកិច្ចទៅកាន់រោងចក្រកែច្នៃឈើ។

ចំពោះដីសម្បទានសេដ្ឋកិច្ចដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គឺមានប្រព័ន្ធច្បាស់លាស់ក្នុងការវាស់ឈើនៅក្នុងឡូត៍គំរូនៃប្លុកនីមួយៗ និងធ្វើការវាស់ឈើមូលដែលបានដកហូតតាមសៀវភៅកត់ត្រាឈើមូល។ រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលចេញលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ទៅតាមការបញ្ជាក់ក្នុងលិខិតបង់ថ្លៃសួយសារ ហើយបន្ទាប់មក ផ្នែករដ្ឋបាលព្រៃឈើចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលអាចដឹកទៅកាន់រោងចក្រកែច្នៃឈើ។

នៅមិនមានបញ្ជីច្បាស់លាស់ ស្តីពីតំបន់សម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានទេ រីឯទិន្នន័យដែលចេញផ្សាយដោយអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេចាត់ទុកថាមិនផ្ទៀងការ ព្រោះវាបង្ហាញតួលេខខុសគ្នាទៅនឹងទិន្នន័យរបស់រាជរដ្ឋាភិបាល។ ទិន្នន័យស្តីពីផលិតកម្ម ឈើមូលពីតំបន់សម្បទានដីសេដ្ឋកិច្ចទាំងអស់ គឺបានប្រមូលតាមរយៈលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើ។ បរិមាណឈើមូលផលិតចេញពីដីសម្បទានសេដ្ឋកិច្ចចាប់ពីឆ្នាំ ២០០៧ - ២០១២ គឺមាននៅក្នុងស្ថិតិ ព្រៃឈើកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០១២) ដែលបោះផ្សាយដោយរដ្ឋបាលព្រៃឈើ និងនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១១ និង ២០១២ (តារាង ១១)។

តារាង ១១ មាឌឈើមូលផលិតចេញពីដីសម្បទានសេដ្ឋកិច្ច ផ្អែកតាមទិន្នន័យលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ របស់រដ្ឋបាលព្រៃឈើ

ឆ្នាំ	មាឌឈើ (ម^{3})
2007	13 491
2008	31 049
2009	37 113
2010	48 644
2011	135 728
2012	128 482

ការសិក្សានេះបានដាក់បង្ហាញបញ្ជីឈ្មោះសម្បទានដីសេដ្ឋកិច្ចមិនមែនផ្លូវការ ជាមួយនឹងទិន្នន័យផលិតកម្មឈើមូល ដែលដកស្រង់ពីទិន្នន័យនៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើពីតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើឆ្នាំ ២០១១ និង ២០១២ ក្នុងឧបសម្ព័ន្ធ ៣។ បញ្ជីនេះគួរ ធ្វើការផ្ទៀងផ្ទាត់ និងពិនិត្យសារឡើងវិញតាមការចាំបាច់ដើម្បីទទួលបានបញ្ជីពេញលេញនៃតំបន់សម្បទានដីសេដ្ឋកិច្ច ក្នុងខេត្តនីមួយៗក្នុងប្រទេសកម្ពុជា។ បញ្ជីឈ្មោះសង្ខេបស្តីពីតំបន់សម្បទានដីសេដ្ឋកិច្ចជាមួយនឹងទិន្នន័យផលិតកម្ម ឈើតាមខេត្ត គឺមាននៅក្នុងរបាយការណ៍របស់រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ ២០១១ និង ២០១២។

តារាង ១២ ផលិតកម្មឈើពីតំបន់សម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ ២០១១ និង ២០១២ តាមបណ្តាខេត្ត

ខេត្ត	ចំនួនសរុបសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត**	ផ្ទៃដី (ហិកតា)*	ចំនួនសម្បទានដីសេដ្ឋកិច្ចដែលមានសកម្មភាពឆ្នាំ ២០១១*	បរិមាណឈើ ឆ្នាំ ២០១១*	ចំនួនសម្បទានដីសេដ្ឋកិច្ចដែលមានសកម្មភាពឆ្នាំ ២០១២*	បរិមាណឈើ ឆ្នាំ ២០១២*
បន្ទាយមានជ័យ	1	6 000	0	0	0	0
បាត់ដំបង	3	17 295	0	0	0	0
កំពង់ចាម	4	9 070	0	0	0	0
កំពង់ឆ្នាំង	1	315 028	0	0	0	0
កំពង់ស្ពឺ	20	101 521	4	3 352	4	3 089
កំពង់ស្ពឺ ព្រះសីហនុ	1	585	0	0	0	0
កំពង់ធំ	19	77 697	12	9 958	1	2 841
កំពង់ធំ ព្រះវិហារ	3	18 343	1	2 849	0	0
កំពត	5	38 672	0	0	0	0
កណ្តាល ភ្នំពេញ	1	2 572	0	0	0	0
កោះកុង	12	57 901	0	0	0	0

ខេត្ត	ចំនួនសរុប សម្បទានដី សេដ្ឋកិច្ច ក្នុងខេត្ត * *	ផ្ទៃដី (ហិកតា) *	ចំនួនសម្បទាន ដីសេដ្ឋកិច្ច ដែលមាន សកម្មភាព ឆ្នាំ ២០១១ *	បរិមាណ ឈើ ឆ្នាំ ២០១១ *	ចំនួនសម្បទាន ដីសេដ្ឋកិច្ច ដែលមាន សកម្មភាព ឆ្នាំ ២០១២ *	បរិមាណ ឈើ ឆ្នាំ ២០១២ *
កោះកុង កំពត	1	7 187	0	0	0	0
ក្រចេះ	37	188 752	14	59 402	14	50 657
ក្រចេះ ស្ទឹងត្រែង	1	34 007	0	0	0	0
ក្រចេះ កំពង់ធំ	1	58 658	0	0	0	0
ក្រចេះ មណ្ឌលគិរី	1	6 525	0	0	1	6 868
មណ្ឌលគិរី	24	157 953	7	4 994	10	15 082
ឧត្តរមានជ័យ	22	58 872	7	6 269	5	9 414
ឧត្តរមានជ័យ ព្រះវិហារ	1	6 500	0	0	0	0
ភ្នំពេញ	3	323	0	0	0	0
	4	3 624	0	0	0	0
កំពត	1	18 987	0	0	0	0
ព្រះវិហារ	21	141 692	5	11 582	5	14 678
ព្រះវិហារ សៀមរាប	1	6 000	0	0	0	0
ពោធិ៍សាត់	4	9 323	2	5 018	1	894
ឧត្តរមានជ័យ រតនគិរី	27	190 119	3	7 810	11	17 780
សៀមរាប	6	29 499	0	0	1	258
សៀមរាប ឧត្តរមានជ័យ	1	9 658	0	0	0	0
ស្ទឹងត្រែង	15	201 066	8	18 066	3	5 581
ស្វាយរៀង	1	1 200	0	0	0	0
សរុប	**242**	**1 774 629**	**63**	**129 300**	**56**	**127 142**

* ប្រភព ៖ របាយការណ៍រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ ២០១១ និង ២០១២

* * ប្រភព៖ គេហទំព័ររបស់អង្គការ Open Development Cambodia (វិច្ឆិកា ២០១៣)

៥.៤ សហគមន៍ព្រៃឈើ

ការអនុម័តការអភិវឌ្ឍសហគមន៍ព្រៃឈើទើបតែមានក្នុងពេលថ្មីៗនេះហើយសកម្មភាពស្ទើរតែទាំងអស់ របស់សហគមន៍ព្រៃឈើ គឺការប្រមូលអនុផលព្រៃឈើ។ បច្ចុប្បន្នមិនទាន់មានកំណត់ត្រាអំពីឈើដែលបានប្រមូលផលពី ៣៤៥ សហគមន៍ព្រៃឈើ ដែលបានអនុម័តរួចលើផ្ទៃដីសរុប ៣០៨.៥៦៤ ហិកតា ហើយបានកត់ត្រានៅក្នុងខ្សែសង្វាក់ ផ្គត់ផ្គង់ឈើនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១២ របស់រដ្ឋបាលព្រៃឈើនៅឡើយ។ រាជរដ្ឋាភិបាលបានកំណត់គោលដៅ បង្កើតសហគមន៍ព្រៃឈើឱ្យបានចំនួន ២លានហិកតានៅទូទាំងប្រទេសកម្ពុជា ដូចនេះសហគមន៍ព្រៃឈើ គឺជាប្រភពមួយយ៉ាងសំខាន់សម្រាប់ការផ្គត់ផ្គង់ឈើនាពេលអនាគតដល់រោងចក្រកែច្នៃឈើ។

៥.៥ ចម្ការឈើ និង ដីឯកជន

ចម្ការឈើស្ទើរតែទាំងអស់ទើបតែដាំក្នុងពេលថ្មីៗនេះ ហើយមិនទាន់អាចប្រមូលផលបាននៅឡើយ។ មិនមានកំណត់ត្រាស្តីពីការប្រមូលផលឈើដាំ នៅលើចម្ការឈើ ១៤.០០០ ហិកតា នៃស្ថានីយដាំឈើសរុប ៩៦.០០០ ហិកតា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើទេ។ ដីកម្មសិទ្ធិឯកជននិងតំបន់ដីសម្បទាន ដែលបានដាំឈើ គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាតឱ្យប្រមូលផលឈើដាំ លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ផលឈើដាំទាំងនោះទេ។ រដ្ឋបាលព្រៃឈើមិនមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការគ្រប់គ្រងការប្រមូលផលឈើដាំ និងកត់ត្រាបរិមាណឈើពីតំបន់ដាំឈើទាំងនោះទេ។

៥.៦ គម្រោងអាជីវកម្មរ៉ែ

យោងតាមទិន្នន័យរបស់ Open Development Cambodia ឆ្នាំ២០១៣ មានតំបន់អាជីវកម្មរ៉ែមួយចំនួនក្នុង ប្រទេសកម្ពុជា ដែលមានផ្ទៃដីសរុបជាង ៤០០.០០០ហិកតា នៅក្នុងតំបន់សម្បទានរ៉ែ (តារាង ១៣)។ រដ្ឋបាលព្រៃឈើ ពុំមានទិន្នន័យអំពីតំបន់អាជីវកម្មរ៉ែទាំងនោះទេ ព្រោះសកម្មភាពនេះមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលព្រៃឈើគ្រប់គ្រងតែសកម្មភាពកាប់ឈើ ដែលតម្រូវឱ្យក្រុមហ៊ុនធ្វើបញ្ជីឈើមូលសម្រាប់ប្រមូលផលឈើតាមរយៈសកម្មភាពអាជីវកម្មរ៉ែ។ រដ្ឋបាលព្រៃឈើទទួលខុសត្រូវក្នុងការវាស់ឈើដែលបានដកហូតវាយញញ្ជីរត្រាលើឈើ ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ស្របតាមនីតិវិធី។ សកម្មភាពអាជីវកម្មរ៉ែនៅក្នុងតំបន់ដីសម្បទាន គឺអាស្រ័យលើការរុករករ៉ែ និងអាចមានផលប៉ះពាល់តិចតួច។ បើពិនិត្យមើលក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើរបស់រដ្ឋបាលព្រៃឈើទាំងអស់ ពីតំបន់អាជីវកម្មរ៉ែ គឺមិនឃើញមានទិន្នន័យកំណត់ត្រាស្តីពីផលិតកម្មឈើ ក្នុងឆ្នាំ ២០១១ និង ២០១២ទេ។

តារាង ១៣ បញ្ជីឈ្មោះតំបន់អាជីវកម្មរ៉ែ និងបរិមាណផលិតផលឈើមូល ឆ្នាំ២០១១ និង ២០១២ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ

ឈ្មោះក្រុមហ៊ុន	ផ្ទៃដី (ហិកតា)	ខេត្ត	ប្រភេទរ៉ែ	២០១១ បរិមាណ (ម៣)	២០១២ បរិមាណ (ម៣)
Khaou Chuly Development Co. Ltd. and Tong Yang Cement Corporation	696	Kampot	Limestone	0	0
Khaou Chuly Development Co. Ltd. and Tong Yang Cement Corporation	344	Kampot	Limestone	0	0
Jupiter International Resources Inc.	29 552	Ratanakiri	Mineral exploration	0	0
Delcom Cambodia Pte Ltd.	43 234	Preah Vihear	Metallic minerals exploration	0	0
Serika Co. Ltd.	3 044	Koh Kong	White Sand Exploration	0	0
Lian Heng Trading Co., Ltd.	19 600	Takeo	Mineral exploration	0	0
Brewer Natural Resources Development Co. ltd	72 500	Ratanakiri	Mineral Exploration	0	0
Brewer Natural Resources Development Co Ltd	50 400	Ratanakiri	Mineral Exploration	0	0
Suntrading Co Ltd	9 400	Mondulkiri	No information	0	0
Golden Forwin trading Limited	638	Kampot	Limestone	0	0
Cambodia Iron and Steel Mining Industry Group	130 674	Preah Vihear	Iron ore exploration	0	0
Delcom Cambodia Pte. Ltd.	19 800	Kampong Thom	Mineral Exploration	0	0
Delcom Cambodia Pte. Ltd.	21 600	Preah Vihear	Mineral Exploration	0	0
Ultra Marine Kiri (Cambodia) Ltd.	400	Battambang	Gem Stone Exploration	0	0
សរុប	**401 882**			**0**	**0**

រូបទី ៦ ផែនទីតំបន់សម្បទានរ៉ែ (ប្រភព Open Development Cambodia ២០១៣)



៥.៧ ទំនប់ទារីអគ្គិសនី

ប្រទេសកម្ពុជាមានគម្រោងវារីអគ្គិសនីមួយចំនួនដែលកំពុងអភិវឌ្ឍ និងបានផ្តល់ឈើដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើ។ មិនមានព័ត៌មានស្តីពីសកម្មភាពកាប់សម្អាតដីព្រៃក្នុងគម្រោងទំនប់នីមួយៗទេ ដូច្នេះគេពុំអាចដឹងច្បាស់ទេអំពី បរិមាណឈើពីគម្រោងវារីអគ្គិសនីទាំងនេះ ដែលបានចូលរួមចំណែកក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ។ បច្ចុប្បន្នទិន្នន័យ អំពីផលិតកម្មឈើនៅក្នុងរបាយ-ការណ៍របស់រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ ២០១១ និង ២០១២ ឃើញមានឈើតែបន្តិចបន្តួចប៉ុណ្ណោះចេញពីប្រភពគម្រោងវារីអគ្គិសនី (មើលតារាង ១៤)។

តារាង ១៤ បរិមាណឈើពីគម្រោងទំនប់វារីអគ្គិសនី (របាយការណ៍ប្រចាំឆ្នាំ២០១១ និង ២០១២ របស់រដ្ឋបាលព្រៃឈើ)

ទំនប់	ខេត្ត	ផ្ទៃដី (ហិកតា)*	បរិមាណ (ម³) ២០១១**	បរិមាណ (ម³) ២០១២**
ស្ទឹងអាតៃ	ពោធិ៍សាត់	4 179	5 679	8 179
ស្ទឹងតាតៃ	កោះកុង	NA	0	217
ឫស្សីជ្រុំក្រោម	កោះកុង	1 481	1 189	0
គិរីរម្យ៣	កោះកុង	NA	913	0
អាងទំនប់កំចាយ	កំពត	1 990	0	0
សំបូរ	ក្រចេះ	62 000	0	0
ស្ទឹងត្រែង	ស្ទឹងត្រែង	21 100	0	0
ស្ទឹងសែនផ្នែកខាងលើ	កំពង់ធំ	6 900	0	0
ស្ទឹងសែនផ្នែកខាងលើ	កំពង់ធំ	86 000	0	0
ស្ទឹងសែនផ្នែកខាងក្រោម	កំពង់ធំ	33 800	0	0
សេសាន ២ ផ្នែកខាងលើ	រតនគិរី	40 300	0	0
សេសាន ២ ផ្នែកខាងក្រោម	រតនគិរី	35 500	0	0
ស្រែពក ២	រតនគិរី	12 000	0	0
អាងទំនប់កំពីងពួយ	បាត់ដំបង	0	0	0
សរុប		**299 590**	**7 781**	**8 396**

* ប្រភព៖ អង្គការ Open Development Cambodia (២០១៣)

** ប្រភព ៖ របាយការណ៍រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ ២០១១ និង ២០១២

ប្រអប់ ៥ ៖ ការរកឃើញសំខាន់ៗស្តីពីការផ្គត់ផ្គង់ឈើ

១. ទិន្នន័យស្តីពីការបង្កើតសម្បទានដីសេដ្ឋកិច្ច ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន ស្តីពីផ្ទៃដី ទីតាំង និងបរិមាណឈើផ្គត់ផ្គង់ទីផ្សារ គឺមិនមានច្បាស់លាស់ទេ។

២. ក្រសួងបរិស្ថានបានផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ ដោយមិនទាន់បានកំណត់តំបន់ប្រើប្រាស់ដោយចីរភាព។ ពុំមានការធ្វើសារពើភ័ណ្ឌព្រៃនៅក្នុងប្លុកប្រមូលផលក្នុងដីសម្បទានសេដ្ឋកិច្ចដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីប៉ាន់ស្មានបរិមាណឈើដែលអាចដកហូតបាននៅក្នុងប្លុកនីមួយៗទេ។

៣. បច្ចុប្បន្ន ចំណាត់ថ្នាក់ព្រៃផ្តល់ផល ប្រាប់ថាមាន ១,២ លានហិកតា តែមិនទាន់បានកំណត់ច្បាស់នៅតាមខេត្ត ឬ គួរជាផែនទីទេ ក៏ប៉ុន្តែអាចមានតំបន់សម្បទានដីសេដ្ឋកិច្ចមួយចំនួនស្ថិតនៅក្នុងព្រៃផ្តល់ផលនេះ។

៤. ការផ្គត់ផ្គង់ឈើនៅក្នុងប្រទេសកម្ពុជា ភាគច្រើនគឺការប្រមូលផលឈើពីតំបន់ដីសម្បទានសេដ្ឋកិច្ចដែលមានបរិមាណសរុប ១២៩.៣០០ ម^{3} ក្នុងឆ្នាំ ២០១១ និង ១២៧.១៤២ ម^{3} ក្នុងឆ្នាំ ២០១២ (យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ)។ មានបរិមាណឈើតិចតួចមានប្រភពចេញពីគម្រោងវារីអគ្គិសនី(៧.៧៨១ម^{3} និង ៨.៣៩៦ម^{3}) ត្រូវបានផ្គត់ផ្គង់ក្នុងអំឡុងឆ្នាំ ២០១១ និង ២០១២ និងមិនឃើញមានការកត់ត្រាអំពីឈើដែលចេញពីប្រភពសហគមន៍ព្រៃឈើ ចម្ការឈើដាំ និងតំបន់អាជីវកម្ម។ (យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើឆ្នាំ ២០១១ និង ២០១២)។

៥. តំបន់សម្បទានដីសេដ្ឋកិច្ចដែលគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានការធ្វើសារពើភ័ណ្ឌព្រៃ ដោយប្រើឡូត៍គំរូតាមលក្ខណៈប្រព័ន្ធដើម្បីធ្វើការប៉ាន់ស្មានឈើដែលអាចធ្វើពាណិជ្ជកម្មបាន និងអាចប្រើប្រាស់សម្រាប់ការត្រួតពិនិត្យបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ "ក") និងប្រើសម្រាប់ទិន្នន័យក្នុងលិខិតបើកផ្លូវដឹកជញ្ជូន ផល-អនុផលព្រៃឈើ។

៦. រដ្ឋបាលព្រៃឈើបានកត់ត្រាគ្រប់ឈើទាំងអស់ ដែលបានផលិតពីតំបន់ដីសម្បទានសេដ្ឋកិច្ច ជាឈើមូល (អង្កត់ផ្ចិត ធំជាងឬស្មើ ៣០ស.ម លើកលែងតែឈើប្រណិត) កូនឈើ (អង្កត់ផ្ចិតតូចជាង ៣០ស.ម) ចូលក្នុងបញ្ជីផល-អនុផលព្រៃឈើតាមប្លុកប្រមូលផលនីមួយៗ និងផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ឱ្យសម្បទានិកប្រើប្រាស់ឈើក្រោយពេលបង់ថ្លៃសួយសារួច។ នៅពេលវាស់ឈើរួច រដ្ឋបាលព្រៃឈើ វាយញញ្ជីរត្រាឈើចំនួន ០១ លើកំណាត់ឈើដែលមានអង្កត់ផ្ចិតធំជាង ៣០សម និងបន្ថែមបីញញ្ជីរត្រាទៀត បន្ទាប់ពីបានបង់ថ្លៃសួយសារួច។ រដ្ឋបាលព្រៃឈើផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ រីឯរដ្ឋបាលព្រៃឈើមូលដ្ឋានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកជញ្ជូនឈើទៅកាន់រោងចក្រកែច្នៃឈើ។

រូបទី ៧ ផែនទីគម្រោងវារីអគ្គិសនី (ប្រភព Open Development ២០១៣)



Photo: Kevin Grace

៦. ឈើនាំចូល

៦.១ ប្រព័ន្ធសម្រាប់ការនាំឈើចូល

ដំណើរការនាំឈើចូល មាន៥ដំណាក់កាលសំខាន់ៗ ដូចខាងក្រោម ៖

ដំណាក់កាលទី ១-ពាក្យស្នើសុំនាំចូលផល-អនុផលព្រៃឈើ

អ្នកនាំឈើចូលត្រូវដាក់ពាក្យស្នើសុំនាំចូលឈើ ឬអនុផលព្រៃឈើនៅរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នៅពេលដែលបានទទួលពាក្យស្នើសុំ នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិដែលទទួលបន្ទុកក្នុងការពិនិត្យពាក្យស្នើសុំ និងភាពស្របច្បាប់របស់ឈើ និងធ្វើការផ្តល់មតិជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីសម្រេច។ ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយលិខិតស្នើសុំចំនួន០២ច្បាប់ បញ្ជីឈើឬអនុផលព្រៃឈើ ០១ច្បាប់ វិក្កយបត្រ០១ច្បាប់ កិច្ចសន្យាផ្គត់ផ្គង់និងទទួលទំនិញ០១ច្បាប់ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ០១ច្បាប់ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីអាករលើតម្លៃបន្ថែម ប័ណ្ណប៉ាតង់ លិខិតផ្ទេរសិទ្ធិ (ក្នុងករណីហត្ថលេខីក្នុងពាក្យស្នើសុំមិនមែនជាប្រធានក្រុមហ៊ុន)។ វិញ្ញាបនបត្រពីប្រភពដើមគឺជាតម្រូវការសម្រាប់ការដាក់ពាក្យស្នើសុំនាំចូលឈើ។

ដំណាក់កាលទី ២- ការផ្ទៀងផ្ទាត់ និងការសម្រេចពីរដ្ឋបាលព្រៃឈើ

បន្ទាប់ពីបានទទួលពាក្យស្នើសុំនាំចូល រដ្ឋបាលព្រៃឈើត្រូវពិនិត្យនិងផ្តល់យោបល់លើឯកសារស្នើសុំ រួចហើយបញ្ជូនសំណុំឯកសារស្នើសុំ ព្រមទាំងយោបល់របស់ខ្លួនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យសម្រេច។ បន្ទាប់ពីក្រសួងបានពិនិត្យលើមតិយោបល់របស់រដ្ឋបាលព្រៃឈើ ក្រសួងនឹងបន្តលើកសំណើទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច។

ដំណាក់កាលទី ៣-ការអនុញ្ញាតឱ្យនាំចូល

ការអនុញ្ញាតឱ្យនាំចូលណាដែលជាឈើស្របច្បាប់ មានកិច្ចសន្យាមានបញ្ជាក់អំពីបរិមាណ វត្ថុធាតុដើមជាក់លាក់នៅក្នុងកិច្ចព្រមព្រៀង ដែលត្រូវបានផ្តល់ឱ្យដោយទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកផ្តល់កូតាដែលមានសុពលភាពរយៈពេល០១ ឆ្នាំ។ ការអនុញ្ញាតអាចនឹងពន្យារពេលបាន បើសិនមានលិខិតស្នើសុំពន្យារពេល ដោយបញ្ជាក់ច្បាស់លាស់អំពីមូលហេតុ ភាពយឺតយ៉ាវឬមិនមានលទ្ធភាពក្នុងការនាំចូលទាន់ពេលវេលានូវចំនួនទំនិញដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ឈើ។

ដំណាក់កាលទី៤- អាជ្ញាប័ណ្ណនាំចូល

បន្ទាប់ពីទទួលបានការអនុញ្ញាតនាំចូលពីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការនាំឈើចូល ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាប័ណ្ណនាំចូលនូវចំនួនជាក់ស្តែងដែលត្រូវនាំចូលមួយលើកៗ និងត្រូវមានចំណារឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ។ អាជ្ញាប័ណ្ណនាំចូលនឹងផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ។ អាជ្ញាប័ណ្ណនាំចូលនឹងផ្តល់ទៅតាមបរិមាណផលឈើ ឬអនុផលព្រៃឈើ ដែលមានជាក់ស្តែង និងមានបញ្ជាក់នៅក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ។ ទន្ទឹមនឹងនោះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ផ្តល់លិខិតអនុញ្ញាតសម្រាប់ការជម្រះបញ្ជីទំនិញនាំចូល។

ដំណាក់កាលទី៥- លិខិតអនុញ្ញាតដឹកជញ្ជូន

ដើម្បីដឹកជញ្ជូនឈើពីច្រកព្រំដែន (មាត់ច្រកនាំចូល) មកកាន់គោលដៅចុងក្រោយ អ្នកនាំចូលឈើត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូល-នាំចេញ (PC-IMEX) មករដ្ឋបាលព្រៃឈើ។ ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយ អាជ្ញាប័ណ្ណនាំចូលដែលបរិយាយអំពីទំនិញឈើត្រូវនាំចូល និងទីកន្លែងទទួល។

ផលនិងអនុផលព្រៃឈើដែលអនុញ្ញាតឱ្យធ្វើការនាំចេញ ឬនាំចូលផលិតផលហាមឃាត់ និងលក្ខខណ្ឌសម្រាប់ការនាំចេញឬនាំចូលមានចែងក្នុងអនុក្រឹត្យ ១៣១ អនក្រ ស្តីពីយថាប្រភេទផល-អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ ចុះថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា។

៦.២ ទិន្នន័យនៃការនាំឈើចូល

ប្រភពទិន្នន័យស្ថិតិឈើនាំចូល មាននៅរដ្ឋបាលព្រៃឈើ ក្នុងនាយកដ្ឋានឧស្សាហកម្មព្រៃឈើនិងសហប្រតិបត្តិការអន្តរជាតិ។ ស្ថិតិស្តីពីការនាំឈើចូល មានបោះផ្សាយក្នុងស្ថិតិព្រៃឈើកម្ពុជាឆ្នាំ ២០០៧ - ២០១២។ ស្ថិតិពីឆ្នាំ ២០០៧ ដល់ ២០១២ ឃើញមានបរិមាណឈើនាំចូលតិចតួចប៉ុណ្ណោះសម្រាប់ការកែច្នៃបន្ថែម (តារាង ១៥)។

តារាង ១៥ ឈើនាំចូលពី២០០៧-១២ នៅក្នុងស្ថិតិព្រៃឈើកម្ពុជា ២០១១ (រដ្ឋបាលព្រៃឈើ ២០១២)

ផលិតផល	2007	2008	2009	2010	2011	2012*
ឈើអារ	500	14	635	774	250	1000
ឈើកែច្នៃ	0	0	465	0	0	0
ឈើមូល	0	0	0	0	50	0
ឈើជ្រុង	0	0	382	100	0	0
សរុប(ម^3)	**500**	**14**	**1 483**	**874**	**300**	**1 000**

*ប្រភព៖ ទិន្នន័យពីនាយកដ្ឋានឧស្សាហកម្មព្រៃឈើនិងសហប្រតិបត្តិការអន្តរជាតិ (របាយការណ៍ឆ្នាំ ២០១២)
ឈើកែច្នៃ៖ ឈើ S2S, S4S ក្ដារបន្ទះឈើចំណិតស្ដើង ក្ដារចាក់ពុម្ព ក្ដារឈើគៀប។ល។

ស្ថិតិនៅក្នុងគេហទំព័ររបស់ FAO (FAOSTAT 2013) បង្ហាញទិន្នន័យឈើនាំចូលពីឆ្នាំ ២០០៣ រហូតដល់ឆ្នាំ២០១១ គឺជាប្រភពទិន្នន័យមួយទៀតស្ដីពីការនាំឈើចូលប្រទេសកម្ពុជា។ ឈរលើមូលដ្ឋាននៃការវាយតម្លៃរវាងទិន្នន័យរបស់រដ្ឋបាលព្រៃឈើ និងទិន្នន័យរបស់ FAO ឃើញមានប្រភេទផលិតផលឈើមិនដូចគ្នាទាំងស្រុងទេ។ ទិន្នន័យស្ថិតិរបស់រដ្ឋបាលព្រៃឈើ គឺមានឈើ S2S, S4S ក្ដារបន្ទះឈើចំណិតស្ដើង ឈើចាក់ពុម្ព ក្ដារឈើគៀប។ល។ ជាផលិតផលឈើកែច្នៃ។ ទិន្នន័យនាំចូលរបស់ FAO គឺមានផលិតផលប្រហាក់ប្រហែលនេះដែរ តែឃើញចំនួនឈើសំណង់នាំចូលច្រើនលើសពីទិន្នន័យក្នុងស្ថិតិរបស់រដ្ឋបាលព្រៃឈើ។ ស្ថិតិទិន្នន័យរបស់ FAO អំពីឈើអារ ក្ដារបន្ទះ ឈើចំណិតស្ដើង និងក្ដារធ្វើពីកំទេចឈើ ឃើញមានកត់ត្រាសារចុះសារឡើងចាប់ពីឆ្នាំ ២០០៤ ដល់ ២០០៦ ដូច្នេះ បញ្ជាក់ថាមិនគួរឱ្យទុកចិត្តបាន។ ទិន្នន័យពីឆ្នាំ ២០០៧ ដល់ ២០១១ គឺមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ រវាងទិន្នន័យស្ថិតិរបស់រដ្ឋបាលព្រៃឈើ និង FAO ដែលក្នុងនោះ បរិមាណឈើនាំចូលសរុបដែលកត់ត្រាដោយរដ្ឋបាលព្រៃឈើពីឆ្នាំ ២០០៧ ដល់ ២០១១ គឺមាន ៣.១៧១ម^3 រីឯទិន្នន័យ FAO បង្ហាញថាមានច្រើនជាងរហូតដល់ ១៨.៣១៧ ម^3។

ក្នុងកំឡុងពេលសិក្សា ក្រុមការងារសិក្សាមិនបានធ្វើការសង្កេតអំពីភស្ដុតាងឈើដែលបានដឹកឆ្លងកាត់ប្រទេសកម្ពុជាទេព្រោះរដ្ឋបាលព្រៃឈើបាននិយាយថាពុំមានក្រុមហ៊ុនណាមួយបានដឹកឈើឆ្លងកាត់ប្រទេសកម្ពុជាទេក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ ឈើដឹកឆ្លងកាត់គឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា។ បច្ចុប្បន្ន រដ្ឋបាលព្រៃឈើពុំមានតួនាទីត្រួតពិនិត្យឈើដឹកឆ្លងកាត់ប្រទេសកម្ពុជានោះទេ។

ប្រអប់ ៦ ៖ ការរកឃើញសំខាន់ៗស្តីពីការនាំផលិតផលឈើចូលប្រទេសកម្ពុជា

១. ប្រព័ន្ធសម្រាប់ការនាំឈើចូលត្រូវបានគ្រប់គ្រងតាមរយៈ គណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើ និងក្រសួងពាណិជ្ជកម្ម ក្នុងការចេញគោលការណ៍អាជ្ញាប័ណ្ណនាំចូល ហើយនិងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាអ្នកចេញលិខិតអនុញ្ញាតនាំចូល។

២. ឈើនាំចូលដែលបានរាយការណ៍ក្នុងស្ថិតិព្រៃឈើកម្ពុជាឆ្នាំ ២០១១ គឺមានភាពខុសគ្នាខ្លាំងទៅនឹងស្ថិតិរបស់ FAO ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១១ នេះបញ្ជាក់ឱ្យឃើញថាមានកង្វះខាតទិន្នន័យនិងរបាយការណ៍ដែលគួរឱ្យជឿជាក់បាន។

៣. បរិមាណឈើនាំចូលជាចំណែកមួយតូច(តិចជាង ៥%) នៃចំនួនឈើផ្គត់ផ្គង់ដែលអាចប្រើប្រាស់សម្រាប់ការកែច្នៃ បើប្រៀបធៀបទៅនឹងបរិមាណឈើមូលដែលដកហូតចេញពីតំបន់ដីសម្បទានសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។

៤. រដ្ឋបាលព្រៃឈើពុំមានតួនាទីត្រួតពិនិត្យលើឈើដឹកឆ្លងកាត់ប្រទេសកម្ពុជាទេ។

Photo: Chris Boswe

៧. ការដឹកជញ្ជូន និងការលក់ផ្ទរឈើមូលក្នុងស្រុក

៧.១ ការពិពណ៌នាអំពីបទប្បញ្ញត្តិក្នុងការប្រមូលផលឈើ និងការដឹកជញ្ជូនឈើមូល

រដ្ឋបាលព្រៃឈើគ្រប់គ្រងការប្រមូលផលនិងការដឹកជញ្ជូនឈើទាំងអស់ពីតំបន់ព្រៃធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ ការប្រមូលផលឈើតម្រូវឱ្យមានលិខិតអនុញ្ញាតដែលផ្តល់ដោយស្ថាប័នរាជរដ្ឋាភិបាលដែលគ្រប់គ្រងព្រៃធម្មជាតិ ទៅតាមយុត្តាធិការនៃក្រសួងផ្សេងៗគ្នា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចផ្តល់សម្បទានដីសេដ្ឋកិច្ច នៅក្នុងតំបន់ព្រៃផ្តល់ផលនិងព្រៃការពារ។ ក្រសួងបរិស្ថានមានសិទ្ធិអំណាចផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តម្រូវឱ្យមានការធ្វើសារពើភ័ណ្ឌព្រៃនៅក្នុងតំបន់ដែលមានផែនការប្រមូលផលនៅតាមបណ្តាប្លុកនៃដីសម្បទានសេដ្ឋកិច្ច។ ការធ្វើសារពើភ័ណ្ឌព្រៃមានការគាំទ្រពីរដ្ឋបាលព្រៃឈើមូលដ្ឋាន (ផ្នែក/សង្កាត់រដ្ឋបាលព្រៃឈើ) ហើយដាក់ស្នើសុំក្រសួងកសិកម្មដើម្បីសុំការអនុញ្ញាត (លិខិតអនុញ្ញាតឱ្យកាប់ឈើ) ឱ្យក្រុមហ៊ុនកាប់ឈើនៅក្នុងគុបប្រមូលផលណាមួយជាក់លាក់ដែលមាននៅក្នុងផែនការមេ។

ចំពោះតំបន់សម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានវិញ មិនតម្រូវឱ្យធ្វើសារពើភ័ណ្ឌព្រៃមុនការកាប់ឈើនោះទេ។ ក៏ប៉ុន្តែឈើទាំងអស់ដែលបានដកហូតពីតំបន់ដីសម្បទានសេដ្ឋកិច្ចទោះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានឬក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទក្តី គឺត្រូវតែកត់ត្រាទៅក្នុងបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ “ក”) និងបន្ទាប់មក ត្រូវធ្វើការវាស់ឈើ ដោយមន្ត្រីរដ្ឋបាលព្រៃឈើ ដើម្បីវាយញញួរត្រាឈើ ហើយរដ្ឋបាលព្រៃឈើផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើឱ្យក្រុមហ៊ុន។ ក្រោយពីបង់ថ្លៃ

សួយសារួច រដ្ឋបាលព្រៃឈើមូលដ្ឋានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដើម្បីឱ្យក្រុមហ៊ុនអាចដឹកជញ្ជូនឈើបាន។

រដ្ឋបាលព្រៃឈើមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ចំនួន៣ប្រភេទ ៖

- ប្រភេទ "ក" សម្រាប់ធ្វើការដឹកជញ្ជូនផល-អនុផលព្រៃឈើពីតំបន់ព្រៃសម្បទាន
- ប្រភេទ "ខ" សម្រាប់ធ្វើការដឹកជញ្ជូនផល-អនុផលព្រៃឈើពីតំបន់ព្រៃផ្តល់ផល និងតំបន់ដីសម្បទានសេដ្ឋកិច្ច
- ប្រភេទ "គ" សម្រាប់ធ្វើការដឹកជញ្ជូនផល-អនុផលព្រៃឈើពីព្រៃសហគមន៍

លិខិតអនុញ្ញាតដឹកជញ្ជូលផល-អនុផលព្រៃឈើ-១ គឺជាលិខិតមួយរបស់រដ្ឋបាលព្រៃឈើ សម្រាប់អនុញ្ញាតឱ្យដឹកជញ្ជូនឈើមូលពីតំបន់ដីសម្បទានសេដ្ឋកិច្ច (ដែលផ្ទេរតំបន់ព្រៃធម្មជាតិទៅជាតំបន់ដាំដុះ)។ ការផ្តល់លិខិតនេះ រដ្ឋបាលព្រៃឈើត្រូវចុះបញ្ជីឈើទាំងអស់ដែលបានប្រមូល និងការដឹកជញ្ជូនក្នុងប្រទេសកម្ពុជា។

យោងតាមលិខិតអនុញ្ញាតឱ្យប្រមូលផល ជាធម្មតា ក្រុមហ៊ុនត្រូវចែកប្លុកប្រមូលផលទៅជាអនុប្លុក ហើយធ្វើការកាប់ឈើ និងដឹកជញ្ជូនឈើមកកាន់គំនរឈើដែលស្ថិតក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច។ មន្ត្រីផ្នែករដ្ឋបាលព្រៃឈើចុះទៅពិនិត្យគំនរឈើ ចំពោះឈើមូលណាដែលមានអង្កត់ផ្ចិតធំជាង ៣០សម ត្រូវបង់លេខរៀងនិងវាស់ ហើយកត់ចូលក្នុងបញ្ជីឈើមូល (សៀវភៅ "ក")។ កូនឈើទាំងអស់ (ឈើមានអង្កត់ផ្ចិតតូចជាង ៣០សម) ក៏ត្រូវកត់ត្រាចូលទៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើសម្រាប់ធ្វើការគណនា បង់ថ្លៃសួយសារនិងបុព្វលាភ។ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានវាយញញួរត្រាលើគ្រប់កំណាត់ឈើដែលមានអង្កត់ផ្ចិតធំជាង ៣០សម ដើម្បីបញ្ជាក់ថាឈើទាំងនោះត្រូវបានវាស់រួច។

បញ្ជីឈើមូល គឺជាឯកសារសំខាន់ក្នុងការកត់ត្រាផលិតកម្មឈើមូលដែលប្រមូលផលពីអនុប្លុក។ បញ្ជីឈើមូលនេះ បង្ហាញអំពី ចំនួនដើម ប្រភេទឈើ និងទំហំឈើ និងមាឌឈើ។ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន បញ្ជូនបញ្ជីឈើមូលនេះទៅរដ្ឋបាលព្រៃឈើដើម្បីពិនិត្យសម្រេច។ រដ្ឋបាលព្រៃឈើផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុន ដើម្បីបង់ថ្លៃសួយសារនិងបុព្វលាភ យោងតាមបញ្ជីឈើដែលបានឯកភាព។ ក្រុមហ៊ុនបង់ថ្លៃសួយសារ និងបុព្វលាភ នៅរតនាគារជាពន្ធឈើដែលបានដកហូត និងបុព្វលាភដល់រដ្ឋបាលព្រៃឈើដែលជាផ្នែកមួយនៃហិរញ្ញប្បទានសម្រាប់ធ្វើការស្តារព្រៃឈើឡើងវិញ។ បន្ទាប់ពីការបញ្ជាក់លើការបង់ថ្លៃសួយសារនិងបុព្វលាភរួច រដ្ឋបាលព្រៃឈើត្រួតពិនិត្យសារឡើងវិញព័ត៌មានរបស់ក្រុមហ៊ុន អំពីការប្រមូលផលនិងផលិតកម្មឈើមូល ដោយផ្អែកតាមបញ្ជីត្រួតពិនិត្យផ្លូវការ ចំនួន១៤ ចំណុច។ បន្ទាប់ពីមានការឯកភាពលើបញ្ជីត្រួតពិនិត្យរួច រដ្ឋបាលព្រៃឈើផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ (សរសេរដោយដៃ) ដល់ក្រុមហ៊ុនដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនអាចប្រើប្រាស់ឈើ (ឈើមូល កូនឈើ និងអុស) ដែលមានរាយនៅក្នុងសៀវភៅ "ក" (បញ្ជីឈើមូល) សម្រាប់ប្លុកដែលបានប្រមូលផល។

លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ គឺជាឯកសារផ្លូវការដែលសង្ខេបបញ្ជីឈើមូលដែលបានបង់ពន្ធរួច (ថ្លៃសួយសារនិងបុព្វលាភ)។ លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើបញ្ជាក់អំពីឈ្មោះក្រុមហ៊ុន និងទីតាំងប្លុកដែលបានប្រមូលផល។ លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើសង្ខេបទិន្នន័យអំពីចំនួនកំណាត់ឈើតាមចំណាត់ថ្នាក់គុណភាព និងមាឌឈើ ដែលជាទិន្នន័យមាននៅក្នុងបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ "ក")។ ក៏តម្រូវឱ្យភ្ជាប់មកជាមួយបញ្ជីរាយមុខឈើដែលជាផ្នែកមួយនៃលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។

រូបទី ៨ ឧទាហរណ៍នៃលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើចេញពីព្រៃផ្តល់ផលក្រៅដែនព្រៃសម្បទាន (លេខ ១៤២ រព.កកព/LP/B) ដែលបានផ្តល់ដោយរដ្ឋបាលព្រៃឈើ

បន្ទាប់មក ក្រុមហ៊ុនប្រើលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើដើម្បីទទួលបានការវាយញញ្ជរត្រាឈើ ចំនួន៣បន្ថែមទៀត ហើយទទួលបានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ (ចំនួន០១សន្លឹកឬច្រើនសន្លឹក) ពីផ្នែករដ្ឋបាលព្រៃឈើ ដើម្បីដឹកឈើ(ឈើមូលបង្គោល អុស)ពីតំបន់ព្រៃឈើ ឬតំបន់ដីសម្បទានសេដ្ឋកិច្ចទៅកាន់រោងចក្រកែច្នៃឈើ ឬ កន្លែងទទួលផ្សេងៗទៀត។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ គឺចេញឱ្យទៅតាមមាឌឈើមូល ប្រភេទគុណភាព ដែលមានទំនាក់ទំនងជាមួយនឹងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងបញ្ជីឈើមូល (សៀវភៅ "ក") ដែលអាចត្រូវការរថយន្តជាច្រើនគ្រឿងសម្រាប់ដឹក

ជញ្ជូន។ រដ្ឋបាលព្រៃឈើធ្វើកំណត់ហេតុត្រួតពិនិត្យដាច់ដោយឡែកមួយអំពីឈើមូលទាំងអស់ភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតដឹកជញ្ជូលផល-អនុផលព្រៃឈើ-១ ដាក់តាមរថយន្តដឹកឈើដែលអាចឱ្យគេតាមដានដឹងអំពីប្រភពរបស់ឈើស្របច្បាប់។

ដោយហេតុថា លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដាក់តែទិន្នន័យមាឌឈើមូលសរុបតាមប្រភេទគុណភាពឈើ និងទីសដៅដឹកជញ្ជូន គេត្រូវមានបញ្ជីរាយមុខឈើដោយឡែកមួយដែលបញ្ជាក់អំពី លេខកំណាត់ ឈើនីមួយៗ ប្រភេទឈើ ខ្នាតឈើ និងមាឌឈើនីមួយៗ ដាក់ភ្ជាប់ជាមួយលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដើម្បីអាចឱ្យគេតាមដានដឹងអំពីប្រភពរបស់ឈើស្របច្បាប់។ មានតម្រូវការមួយទៀត គឺត្រូវភ្ជាប់ជាមួយសៀវភៅ "ក" ឬ បញ្ជីឈើមូល ជាផ្នែកមួយនៃលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ប៉ុន្តែមាឌឈើ ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផលអនុផលព្រៃឈើ-១ អាចមានច្រើនជាងចំនួនឈើកំពុងដឹកជញ្ជូនលើរថយន្តមួយណានោះ។ ក្នុងករណីអវត្តមានបញ្ជីឈើមូល លិខិតអនុញ្ញាតដឹកជញ្ជូន ផល-អនុផលព្រៃឈើ-១ គឺពុំមានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើការផ្ទៀងផ្ទាត់ប្រភពដើមនៃឈើមូលនីមួយៗដែលកំពុងដឹកជញ្ជូនពីតំបន់ដែលមានអាជ្ញាប័ណ្ណបានទេ។

រូបទី ៩ ឧទាហរណ៍លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ លេខ ២៩៥ ផរព.លដជ របស់ផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង



ដោយសារតែលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ផ្ទុកទិន្នន័យសង្ខេបអំពីឈើដែលកំពុងដឹកជញ្ជូនទៅកាន់រោងចក្រកែច្នៃឈើ ដែលផ្អែកតាមទិន្នន័យក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ អាចមាន ទិន្នន័យបរិមាណមាឌឈើទាំងអស់ ឬចំណែកមួយនៃឈើ ដូចជាបរិមាណផ្ទុកឈើសម្រាប់តែរថយន្តដឹកជញ្ជូនមួយគ្រឿង ដូច្នេះ បញ្ជីឈើមូលចាំបាច់ត្រូវតែភ្ជាប់ជាមួយលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១។ ឧទាហរណ៍ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ លេខ ២៩៥ ផរព.លដជ មានបរិមាណឈើមូលសរុប ១.៦១៥ កំណាត់ ដឹកពីតំបន់ដីសម្បទានសេដ្ឋកិច្ច ភូម៉ាឌី ដែលមានបរិមាណឈើសរុបទាំងអស់ ២.០១៩,៤៨ ម^{3} ដែលត្រូវដឹក តាមរថយន្តជាច្រើនគ្រឿង។ រថយន្តភាគច្រើនអាចផ្ទុកបានពី ១០ទៅ៣០ម^{3}ឈើមូលទៅតាមទំហំរបស់រថយន្ត។ដូច្នេះដើម្បីដឹកជញ្ជូនឈើទាំងអស់នេះបាន គឺត្រូវប្រើរថយន្តរហូតដល់ទៅ ១០០ គ្រឿង។ ដូច្នេះ បញ្ជីឈើមូល និងបរិមាណមាឌឈើដែលចេញឱ្យសម្រាប់រថយន្តណាមួយដែលអាចផ្ទុកឈើមូលបានពីរបីកំណាត់នោះ អាចនឹងខុសគ្នាច្រើនពីបរិមាណឈើមូល ១.៦១៥ កំណាត់ ដែលបានអនុញ្ញាតនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ លេខ ២៩៥ ផរព.លដជ។

លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ យោងទៅតាមចំនួនលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ មានមួយឬច្រើនសន្លឹក សម្រាប់ដឹកជញ្ជូនឈើពីតំបន់ផ្សេងៗគ្នា។ ឈើមូលអាចធ្វើការលក់ដូរបានពីលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ តាមរយៈការដេញថ្លៃ ដែលបានកត់ត្រាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាផ្នែកមួយនៃផលិតកម្មឈើក្នុងសម្បទានដីសេដ្ឋកិច្ច។ អ្នកទិញអាចប្រើប្រាស់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ មួយឬច្រើនសន្លឹក សម្រាប់ដឹកជញ្ជូនឈើ។ នៅក្នុងប្រព័ន្ធបច្ចុប្បន្ននេះ រដ្ឋបាលព្រៃឈើប្រមូលព័ត៌មានបរិមាណឈើមូលដែលប្រមូលផលចេញពីតំបន់មានអាជ្ញាប័ណ្ណនៅក្នុងព្រៃធម្មជាតិ ក៏ដូចជាវត្ថុធាតុដើមដែលកំពុងដឹកជញ្ជូន។

ឈើដាំ មិនតម្រូវឱ្យមានលិខិតបើកផ្លូវ ឬលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ទេ ដោយសារតែមិនតម្រូវឱ្យបង់ថ្លៃសួយសារនិងបុព្វលាភ។

ប្រអប់ ៧ ៖ការរកឃើញសំខាន់ៗស្តីពីការដឹកជញ្ជូនឈើនិងការលក់ដូរឈើក្នុងស្រុក

១. ផលិតកម្មឈើមូលទាំងអស់ពីព្រៃធម្មជាតិ រួមទាំងតំបន់ដីសម្បទានសេដ្ឋកិច្ច ត្រូវបានកត់ត្រាដោយរដ្ឋបាលព្រៃឈើចូលក្នុងបញ្ជីឈើមូល (សៀវភៅ "ក") ដើម្បីអាចសុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងអាចកំណត់អំពីថ្លៃសួយសារនិងបុព្វលាភដែលត្រូវបង់ ទើបសម្បទានិកអាចប្រើប្រាស់វត្ថុធាតុដើមទាំងនេះបាន។

២. បញ្ជីឈើមូលមិនប្រើប្រាស់ជាផ្លូវការទេ ក្រៅពីតែសម្រាប់សុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ក៏ប៉ុន្តែក្រុមការងារសិក្សាបានសង្កេតឃើញថា បញ្ជីឈើមូលនេះត្រូវបានគេប្រើសម្រាប់កំណត់បរិមាណវត្ថុធាតុដើមចូលរោងចក្រកែច្នៃឈើ។ បរិមាណវត្ថុធាតុដើមឈើមូលដែលផលិតចេញពីតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលដាក់នៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ គឺមាននៅក្នុងស្ថិតិប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ។

៣. ស្នាមញញួរត្រាមួយត្រូវបានវាយលើកំណាត់ឈើដែលបានវាស់វែងរួចដោយមន្ត្រីរដ្ឋបាលព្រៃឈើ និងកត់ត្រាចូលក្នុងបញ្ជីឈើមូល។ ក្រោយពីបានបង់ថ្លៃសួយសារនិងបុព្វលាភរួច មន្ត្រីរដ្ឋបាលព្រៃឈើវាយញញួរត្រាចំនួនបី បន្ថែមទៀតលើកំណាត់ឈើទាំងនោះ ទៅតាមបរិមាណឈើដែលមាននៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។

៤. តម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ (ឬប៉ូសេ) សម្រាប់ដឹកជញ្ជូនឈើពីព្រៃទៅកាន់រោងចក្រកែច្នៃឈើណាមួយ បើទោះជារោងចក្រកែច្នៃឈើនោះស្ថិតនៅក្នុងដែនដីសម្បទានសេដ្ឋកិច្ចក៏ដោយ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ បញ្ជាក់ពីបរិមាណឈើទៅតាមគុណភាពរបស់ឈើ ក៏ប៉ុន្តែមិនបញ្ជាក់អំពីឈើមូលជាក់ស្តែងដែលកំពុងដឹកជញ្ជូននោះទេ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ អាចមានបរិមាណឈើច្រើនជាងបរិមាណនៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ០១ច្បាប់ ដែលគេអាចប្រើរថយន្តច្រើនគ្រឿងសម្រាប់ធ្វើការដឹកជញ្ជូន។ បញ្ជីឈើមូលត្រូវតែភ្ជាប់ជាមួយលិខិតអនុញ្ញាតដឹកជញ្ជូនផលអនុផលព្រៃឈើ-១ ដើម្បីអាចដឹងអំពីឈើមូលដែលកំពុងដឹកជញ្ជូនលើរថយន្ត និងអាចតាមដានដឹងថា ឈើចេញពីតំបន់មានអាជ្ញាប័ណ្ណណាមួយ។ ដូចនេះ បញ្ជីឈើមូលអាចគ្រាន់តែជាចំណែកតូចមួយនៃលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដែលអាចមានទិន្នន័យបរិមាណឈើខុសគ្នា។ ដូច្នេះ ការតាមដាននិងផ្ទៀងផ្ទាត់ឈើមូលអាចធ្វើទៅបានតាមរយៈការពិនិត្យបញ្ជីឈើមូល (សៀវភៅ "ក") លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាត ដឹកជញ្ជូនផល-អនុផលព្រៃឈើ-១។

Photo: Kevin Grace

៨. ផលិតកម្មឈើ និងការនាំចេញ

៨.១ រោងចក្រកែច្នៃ និងទិន្នន័យផលិតកម្មឈើ

យោងតាមស្ថិតិព្រៃឈើជាតិឆ្នាំ២០១១ មានរោងចក្រកែច្នៃឈើបឋមចំនួន ៥០ ដែលបានចុះបញ្ជីដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលប្រើប្រាស់ឈើមូលជាវត្ថុធាតុដើមដើម្បីផលិតជាក្តារបន្ទះ ឈើអារ ផលិតផលឈើចាក់ពុម្ព និងរោងចក្រកែច្នៃឈើចំនួន៣ទៀតធ្វើការកែច្នៃបន្ថែម ដើម្បីផលិតជាគ្រឿងសង្ហារឹម និងផលិតផលកែច្នៃដោយដៃមួយចំនួនទៀត (រាជរដ្ឋាភិបាល ២០១២)។ រោងចក្រកែច្នៃឈើទាំងអស់ដែលបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ តម្រូវឱ្យសុំពន្យារសុពលភាពជាប្រចាំឆ្នាំជាមួយនឹងរដ្ឋបាលព្រៃឈើ។ ក្រសួងបរិស្ថានក៏ចេញអាជ្ញាប័ណ្ណរោងចក្រកែច្នៃឈើនៅក្នុងដីសម្បទានសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ តែមិនបានបង្ហាញនៅក្នុងរបាយការណ៍នៃការសិក្សានេះទេ ដោយសារតែខ្វះទិន្នន័យ។ ទិន្នន័យពីនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិបង្ហាញថា មានរោងចក្រកែច្នៃឈើ ចំនួន ៤៩ ក្នុងឆ្នាំ ២០១២ ដែលមានអាជ្ញាប័ណ្ណពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាធម្មតា គឺមានទីតាំងស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ច (តារាង ១៦)។

តារាង ១៦ ចំនួនរោងកែច្នៃឈើដែលមានសុពលភាពតាមខេត្ត ស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងបរិមាណផលិតផលនាំចេញឆ្នាំ ២០១២ (នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ)

ខេត្ត	រោងចក្រកែច្នៃឈើ ២០១២	បរិមាណផលិតផលក្នុងស្រុក (ម៣)	បរិមាណផលិតផលនាំចេញ (ម៣)
មណ្ឌលគិរី	6	NA	298
រតនគិរី	7	NA	1 605
ស្ទឹងត្រែង	4	NA	0
ក្រចេះ	11	NA	502
កំពង់ចាម	5	NA	0
កំពង់ធំ	1	NA	1 000
សៀមរាប	2	NA	0
បន្ទាយមានជ័យ	0	NA	0
ឧត្តរមានជ័យ	3	NA	282
បាត់ដំបង	0	NA	10 791
កោះកុង	2	NA	0
ពោធិ៍សាត់	0	NA	0
ព្រះវិហារ	3	NA	0
កណ្តាល	3	NA	0
ព្រះសីហនុ	2	NA	15 000 tons*
កំពត	0	NA	0
សរុប	**49**	**NA**	**13 414 m³**

* ចំណាំងឈើ (ស្រស់)ពីដើមអាកាស្យា និងប្រេងខ្យល់ក្នុងចម្ការព្រៃដាំ

NA ៖ មិនមានទិន្នន័យ (ទិន្នន័យផលិតផលក្នុងស្រុក)

៨.២ ផលិតកម្មរោងចក្រកែច្នៃ និងការដឹកជញ្ជូនផលិតផល

បច្ចុប្បន្ន មិនមានទិន្នន័យច្បាស់លាស់អំពីផលិតកម្មក្នុងស្រុក និងការលក់ផលិតផលឈើទេ។ មានការតម្រូវជាផ្លូវការ នៅក្នុងប្រការ២ នៃប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចែងថា "ម្ចាស់រោងចក្រត្រូវតែមានសៀវភៅកត់ត្រាឈើចូលនិងឈើចេញពីរោងចក្រ"។ រដ្ឋបាលព្រៃឈើបានរៀបចំគំរូសៀវភៅកត់ត្រាឈើចូលនិងឈើចេញ សម្រាប់តម្រូវឱ្យរោងចក្រកែច្នៃឈើកត់ត្រាជាប្រចាំថ្ងៃអំពីឈើចូលនិងឈើចេញសម្រាប់រាយការណ៍ជាផ្លូវការ។ ផលិតកម្មឈើអារពីរោងចក្រកែច្នៃឈើគឺអាស្រ័យទៅតាមតំបន់សម្បទានដីសេដ្ឋកិច្ចដែលផលិតឈើមូលពីសកម្មភាពកាប់សម្អាតព្រៃសម្រាប់ផ្តត់ផ្គង់ដល់រោងចក្រកែច្នៃឈើ។ ភាគច្រើន រោងចក្រកែច្នៃឈើគឺមានទីតាំងស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ដូច្នេះបរិមាណឈើចូលរោងចក្រកែច្នៃឈើ គួរតែមានទំនាក់ទំនងគ្នាជាមួយនឹងបរិមាណឈើមូលដែលអាចផលិតបានពីក្នុងតំបន់ព្រៃសម្បទាន។

ប្រអប់ ៨ ៖ ករណីសិក្សា

មិនមែនគ្រប់រោងចក្រកែច្នៃឈើទាំងអស់សុទ្ធតែមានសកម្មភាពកែច្នៃឈើនោះទេ ដូចដែលខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរីបានប្រាប់ថា នៅខេត្តមណ្ឌលគិរីមានរោងចក្រកែច្នៃឈើទាំងអស់ចំនួន៥ ប៉ុន្តែមានរោងចក្រកែច្នៃឈើតែ២ប៉ុណ្ណោះដែលមានដំណើរការ ហើយផលិតសម្រាប់តែទីផ្សារក្នុងស្រុកប៉ុណ្ណោះ។ បច្ចុប្បន្ន ការកាប់ឈើនៅក្នុងព្រៃធម្មជាតិគឺមានតែនៅក្នុងដីសម្បទានសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍សាងសង់ហេដ្ឋារចនាសម្ព័ន្ធតែប៉ុណ្ណោះ ដែលកាប់សម្អាតដីព្រៃ ដូច្នេះរោងចក្រកែច្នៃឈើអាចមានសកម្មភាពតែក្នុងអំឡុងពេលនៃការកាប់សម្អាតដីព្រៃតែប៉ុណ្ណោះ។ ក្រុមការងារសិក្សាបានសង្កេតមើលរោងចក្រកែច្នៃឈើមួយជារបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កូវីហ្វាម៉ា ដែលមិនមានសកម្មភាពតាំងពីខែកញ្ញា ឆ្នាំ២០១១ ដោយសារក្រុមហ៊ុននេះគិតឃើញថា មិនមានផលសេដ្ឋកិច្ច(មិនចំណេញ) ក្នុងការដឹកជញ្ជូន និងលក់ឈើកែច្នៃទៅក្រៅតំបន់ដីសម្បទាន។ ឈើខ្លះដែលបានមកពីសកម្មភាពកាប់សម្អាត ត្រូវបានប្រើប្រាស់សម្រាប់សាងសង់ជម្រកស្នាក់នៅ រីឯឈើនៅសល់ ត្រូវបានទុកចោលឱ្យពុកផុយ។

យោងតាមទិន្នន័យពីសកម្មភាពកាប់សម្អាតដីព្រៃថ្មីៗនេះនៅក្នុងប្លុក១និង២នៅក្នុងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន កូវីហ្វាម៉ា ដែលមានផ្ទៃដី ១.២៧០ ហិកតា សម្រាប់ដាំដុះ បានផ្តល់ផលឈើមូលចំនួន ៣.៤៧៣ ម^{3} (ឈើអង្កត់ផ្ចិតធំជាង ៣០សម) ត្រូវនិងទិន្នផល ២,៧៣ម^{3}/១ហិកតា។ ក្រុមហ៊ុន កូវីហ្វាម៉ា ទទួលខុសត្រូវចំពោះការបង់ថ្លៃសួយសារទាំងអស់ ចំពោះឈើដែលមានអង្កត់ផ្ចិតចាប់ពី៣០ស.មឡើងទៅ និងកូនឈើ(មានអង្កត់តូចជាង ៣០ស.ម)។ ក្រុមហ៊ុនចាំបាច់ត្រូវតែបង់ថ្លៃសួយសារ បើទោះជាក្រុមហ៊ុនលក់ឈើទាំងនោះ ឬទុកឈើឱ្យពុកចោលក៏ដោយ។

ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលព្រៃឈើតម្រូវឱ្យការប្រមូលផលឈើមូល បង្គោល អុស ទាំងអស់ពីតំបន់ព្រៃធម្មជាតិ ត្រូវចុះក្នុងបញ្ជីឈើមូល(សៀវភៅ “ក”) សម្រាប់ការបង់ថ្លៃសួយសារ និង ការសុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើពីរដ្ឋបាលព្រៃឈើ ដើម្បីអាចប្រើប្រាស់វត្ថុធាតុដើមទាំងនោះបាន។ លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ បញ្ជាក់អំពីចំនួននិងបរិមាណមាឌឈើមូល ចំនួនកូនឈើ និងមាឌអុស ដែលបានផលិតពីប្លុកប្រមូលផលមានការអនុញ្ញាត។

ការដឹកជញ្ជូនវត្ថុធាតុដើមឈើតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដែលផ្តល់ឱ្យដោយរដ្ឋបាលព្រៃឈើមូលដ្ឋានទៅតាមបរិមាណដែលកំណត់ក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ មានព័ត៌មានសង្ខេបអំពីបរិមាណនិងប្រភេទគុណភាពឈើសម្រាប់ការដឹកជញ្ជូនទៅកាន់ទីតាំងរោងចក្រកែច្នៃឈើ ដែលបានបញ្ជាក់នៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ បញ្ជីឈើមូលត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ សម្រាប់កំណត់អត្តសញ្ញាណឈើមូល តាមលេខឈើ ប្រភេទឈើ មុខឈើ និងមាឌឈើ ដើម្បីអាចតាមដានដឹងអំពីប្រភពតំបន់អាជីវកម្មដែលបានអនុញ្ញាត។

ការដឹកជញ្ជូនផលិតផលឈើ ត្រូវតែមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដើម្បីដឹកជញ្ជូនពីរោងចក្រកែច្នៃឈើទៅកាន់ទីផ្សារក្នុងស្រុក(រូប ១០)។លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ មានទម្រង់ ដូចគ្នានឹងលិខិតដឹកជញ្ជូនឈើមូលមកកាន់រោងចក្រកែច្នៃឈើដែរ តែខុសគ្នាត្រង់ការពិពណ៌នាអំពីផលិតផលឈើដែលដឹកតែប៉ុណ្ណោះ។ សង្កេតឃើញថា ការប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ត្រូវភ្ជាប់មកជាមួយកំណត់ហេតុត្រួតពិនិត្យរបស់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន រួមមាន បញ្ជីឈើអារដែលបានត្រួតពិនិត្យ(រូប ១១)។ កំណត់ហេតុត្រួតពិនិត្យមានការបញ្ជាក់ច្បាស់អំពីបរិមាណ និងបញ្ជីផលិតផលឈើដែល

រូបទី ១០ ឧទាហរណ៍ស្តីពីលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ៖ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ លេខ ៩៧ ផរព.លជជ ដែលចេញដោយផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

ផ្នែករដ្ឋបាលព្រៃឈើ ...

PC 2

លេខប័ណ្ណ 000798/ខ / PC/B លេខ: ...៩៧... ផរព.លជជ

លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ

អនុញ្ញាតឱ្យឈ្មោះ ...

ដឹកជញ្ជូនផល អនុផល (១) ...

បរិមាណ (២) ...

ចេញដំណើរពីចំណុចនៅ ... ។

ថ្ងៃ ... ខណ្ឌ ... អចិការម្ចាស់ ... ។

នៅថ្ងៃទី ... ខែ ... ឆ្នាំ ...

ផ្លូវ ... ឃុំ ... ស្រុក ... ខេត្ត ...

ចុងបញ្ចប់ដំណើរ ... ។

ដោយមធ្យោបាយដឹកជញ្ជូន (៣) : ... លេខសម្គាល់ ...

យោងលិខិតបើកផ្លូវលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...

ចេញដោយ ...

បង្គាន់ដៃបង់ប្រាក់សរុបលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...

ចំនួនទឹកប្រាក់ (២) : ...

ចេញដោយ : ...

ថ្ងៃ ... ខែ ... ឆ្នាំ ...

ជ.ប.ផ្នែករដ្ឋបាលព្រៃឈើ ...

(១) - ភ្ជាប់មកជាមួយសៀវភៅ "ក" ឬ បញ្ជីលំអិតផល អនុផលព្រៃឈើបញ្ជាក់ដោយប្រធានរដ្ឋបាលព្រៃឈើ

(២) - សរសេរលេខ និងអក្សរ

(៣) - មធ្យោបាយដឹកជញ្ជូនត្រូវបញ្ជាក់ចំនួន និង លេខសម្គាល់ដោយផ្នែករដ្ឋបាលព្រៃឈើ

កំពុងដឹកជញ្ជូននៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២។ ផលិតផលឈើសម្រាប់ការនាំចេញ គឺតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើ និងត្រូវមានអាជ្ញាប័ណ្ណនាំចេញ ដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម។

លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ សម្រាប់ដឹកជញ្ជូនឈើមូលចូលរោងចក្រកែច្នៃឈើ អាចតំណាងឱ្យកំណត់ត្រាឈើមូលដែលរោងចក្រកែច្នៃឈើបានទទួល ចំណែកឯកំណត់ត្រានៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល អាចប្រើប្រាស់សម្រាប់បូកសរុបផលិតផលឈើកែច្នៃទាំងអស់ ដែលចេញពីរោងចក្រកែច្នៃឈើ នៅក្នុងរយៈពេលណាមួយបាន។ ដូច្នេះ ទិន្នន័យឈើចូលនិងឈើចេញពីរោងចក្រកែច្នៃឈើនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ឈើបច្ចុប្បន្ន អាចប្រមូលបានដោយប្រយោល ចេញពីលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល។ ក៏ប៉ុន្តែ បច្ចុប្បន្ននេះ រដ្ឋបាលព្រៃឈើមិនទាន់ធ្វើការប្រមូលផ្តុំឬចងក្រងទិន្នន័យទាំងនេះជារបាយការណ៍ទេ។

៨.៣ ប្រព័ន្ធ/ដំណើរការសម្រាប់ការនាំឈើចេញ

ក្រុមហ៊ុនដែលចង់ធ្វើការនាំឈើចេញ គឺត្រូវមានអាជ្ញាប័ណ្ណនាំចេញពីក្រសួងពាណិជ្ជកម្ម ដោយយោងតាមការឯកភាពលើបរិមាណ និងប្រភេទឈើដែលបានត្រួតពិនិត្យដោយរដ្ឋបាលព្រៃឈើ និងកិច្ចសន្យាលក់ឈើ។ ឯកសារចាំបាច់សម្រាប់ការសុំអាជ្ញាប័ណ្ណនាំចេញ រួមមានកិច្ចព្រមព្រៀងស្តីពីការលក់ដូរ វិក័យប័ត្រ បញ្ជីវេចខ្ចប់ និងលិខិតអនុញ្ញាតឱ្យនាំចេញ (កូតា) ពីទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

អាជ្ញាប័ណ្ណនាំចេញ អាចធ្វើការនាំចេញបានច្រើនជើងនៅក្នុងកិច្ចសន្យាលក់ចេញមួយ។ ប្រព័ន្ធសម្រាប់ការនាំចេញផលិតផលឈើ គឺដូចគ្នានឹងការនាំចូលផលិតផលឈើដែរ ដូចបានបរិយាយនៅក្នុងផ្នែក ៦ខាងលើ។ ឈើមូលនិងឈើអារពីព្រៃធម្មជាតិ គឺមិនអនុញ្ញាតឱ្យធ្វើការនាំចេញទេ ប៉ុន្តែអាចអនុញ្ញាតឱ្យនាំចេញតែឈើកែច្នៃណា ដូចជា ឈើឈូសរំលីង(S2S, S4S) ឈើចំណិតស្តើង (Veneer) ក្តារបន្ទះ (Plywood) ឈើចំណាំង (Woodchip)។ល។ ក្រុមហ៊ុនត្រូវបានអនុញ្ញាតឱ្យនាំចេញឈើមូល និងឈើអារណាដែលមានប្រភពពីចម្ការឈើដាំប៉ុណ្ណោះ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាទទួលខុសត្រូវក្នុងការផ្តល់លិខិតអនុញ្ញតនាំចេញ ដែលមានសុពលភាពរយៈពេលមួយខែ (អាចពន្យារពេលបាន ប៉ុន្តែមិនអាចហួសពីរយៈពេលសុពលភាពនៅក្នុងអាជ្ញាប័ណ្ណដែលផ្តល់ដោយក្រសួងពាណិជ្ជកម្មនោះទេ) និងត្រួតពិនិត្យថា ទំនិញនាំចេញគឺត្រឹមត្រូវតាមឯកសារនាំចេញ ដើម្បីធ្វើការជម្រះបញ្ជីទំនិញនាំចេញ រួមមានឯកសារអាជ្ញាប័ណ្ណនាំចេញ វិក័យប័ត្រពាណិជ្ជកម្ម និងបញ្ជីវេចខ្ចប់ ដែលជាចំណែកមួយនៃការផ្ទុកទំនិញក្នុងកុងតឺន័រ មុនការបិទភ្ជិតកុងតឺន័រសម្រាប់ការនាំចេញ។ ការជម្រះបញ្ជីទំនិញនាំចេញត្រូវត្រួតពិនិត្យផ្ទាល់ ដោយភ្នាក់ងារគយនៅចំណុចត្រួតពិនិត្យ។ តាមបទប្បញ្ញត្តិ និង តាមការស្នើសុំការត្រួតពិនិត្យរបស់គយអាចនឹងប្រព្រឹត្តទៅនៅក្រៅការិយាល័យគយ។ អគ្គនាយកដ្ឋានគយ និង

រដ្ឋាករកម្ពុជាមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យពាណិជ្ជកម្មឆ្លងដែន និងទាមទារមើលអាជ្ញាប័ណ្ណនាំចេញ លិខិតអនុញ្ញាតនាំចេញ និងឯកសារជម្រះបញ្ជីទំនិញ លិខិតអនុញ្ញាតនាំចូល-នាំចេញ ផល-អនុផលព្រៃឈើ។ល។ ដើម្បីឱ្យទំនិញទាំងនោះឆ្លងកាត់ចំណុចត្រួតពិនិត្យតាមច្រកព្រំដែនអន្តរជាតិ និង ច្រកព្រំដែនទ្វេភាគី (រូប ១១)។

រូបទី ១១ ចំណុចប៉ុស្ត៍ត្រួតពិនិត្យសំខាន់ៗរបស់គយ (យោងតាមរាជរដ្ឋាភិបាលកម្ពុជា ២០០១)



៨.៤ ស្ថិតិនាំចេញ

ទិន្នន័យនាំចេញឈើ ពីឆ្នាំ ២០០៣ ដល់ ២០១២ នៅក្នុងស្ថិតិព្រៃឈើកម្ពុជា (រដ្ឋបាលព្រៃឈើ ២០១២) និងស្ថិតិរបស់អង្គការ FAO FAOSTAT (២០១៣)

តារាង ១៧ សង្ខេបទិន្នន័យស្តីពីបរិមាណផលិតផលឈើ (ម^{3}) នាំចេញ និងឈើ
ចំណាំង(តោន) ឆ្នាំ ២០០៣ ដល់ ២០១២ (រដ្ឋបាលព្រៃឈើ ២០១២)

ផលិតផល	2003	2004	2005	2006	2007	2008	2009	2010	2011	2012*
ឈើមូល	0	0	0	0	0	0	0	0	0	0
ឈើអារ	0	0	0	0	0	0	0	0	0	2 000**
S2S / S4S	171	79	297	0	0	17	484	816	501	1 541
ឈើជ្រុង/ ចតុកោណ (មុខអតិបរមា ២៥សម)	0	0	0	0	392	76	3141	13 074	25 212	12 451
ឈើចំណិតស្តើង	0	0	0	0	0	0	0	0	858	200
ក្តារបន្ទះ	0	0	4 530	0	0	0	0	0	297	0
ការ៉ូឈើ	428	0	0	0	0	0	250	0	824	0
សង្ហារឹម	32	46	0	0	0	0	0	7	108	0
កំណល់ផ្លូវ រទេះភ្លើង	951	0	0	0	0	201	0	0	0	0
***ផលិតផលឈើកែច្នៃដទៃទៀត	167	853	3 186	134	910	643	993	0	0	0
សរុប (ម^{3})	**1 749**	**978**	**8 013**	**134**	**1 302**	**937**	**4 868**	**13 896**	**27 800**	**14 193**
ឈើចំណាំង (អាកាស្យា និងប្រេងខ្យល់)	0	0	0	6 000	0	7 000	0	32 257	68 000	15 000
សរុប (តោន)	**0**	**0**	**0**	**6 000**	**0**	**7 000**	**0**	**32 257**	**68 000**	**15 000***

* * ប្រភព ៖ របាយការណ៍រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ ២០១២ (យោងតាមទិន្នន័យលិខិតអនុញ្ញាត)

* * ឈើជាំ

* * * ផលិតផលឈើកែច្នៃដទៃទៀត សំដៅដល់ផលិតផលផ្សេងៗដូចជា ល្បែងលេង ដងឧបករណ៍ ។ល។

ទិន្នន័យស្ថិតិដែលបោះផ្សាយដោយរាជរដ្ឋាភិបាលនៅក្នុងស្ថិតិព្រៃឈើកម្ពុជា ក្នុងឆ្នាំ ២០១២ គឺមានការខុសគ្នាគួរឱ្យកត់សម្គាល់ពីទិន្នន័យរបស់អង្គការ FAO ស្តីពីបរិមាណឈើសរុបដែលនាំចេញប្រចាំឆ្នាំ ពីឆ្នាំ ២០០៣ ដល់ ២០១១។ តាមទិន្នន័យថ្មីៗបំផុតពីឆ្នាំ ២០១០ ដល់ ២០១១ បរិមាណឈើនាំចេញសរុបក្នុងឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល គឺមាន ១៥.៩០៧ ម^{3} រីឯទិន្នន័យរបស់អង្គការ FAO ថាមានរហូតដល់ ៣៩.០១៣ ម^{3} ហើយក្នុងឆ្នាំ ២០១១ ស្ថិតិឈើនាំចេញសរុបរបស់រាជរដ្ឋាភិបាលមាន ២៩.៨១១ ម^{3} រីឯស្ថិតិរបស់អង្គការ FAO បែរជាធ្លាក់ចុះមក ១៧.៧៥១ ម^{3} វិញ។ ទិន្នន័យមិនស្របគ្នាដោយអន្លើក្នុងស្ថិតិនាំចេញរវាងរដ្ឋបាលព្រៃឈើ និងអង្គការ FAO ជាចំណោទអំពីវិធីសាស្ត្រ និងការទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យស្ថិតិរវាងប្រទេសរាយការណ៍ និងអង្គការអន្តរជាតិ។

តារាង ១៨ ផលិតផលឈើនាំចេញក្នុងតំបន់ (ម^{3}) ក្នុងឆ្នាំ ២០១១ (រដ្ឋបាលព្រៃឈើ ២០១២)

ផលិតផល	គោលដៅ(កន្លែងទទួល)					
	ចិន	ជប៉ុន	ម៉ាឡេស៊ី	ថៃ	វៀតណាម	សរុប (ម^{3})
ឈើ S2S, S4S	206	0	0	0	296	502
ឈើចំណិតស្តើង	783	75	0	0	0	858
ក្ដារបន្ទះ	0	297	0	0	0	297
សង្ហារឹម	0	0	0	0	0	0
ការ៉ូឈើ	823	0	0	0	0	823
ឈើជ្រុង/ ចតុកោណ (មុខអតិបរមា ២៥សម)	21 548	0	30	319	3 316	25 213
សរុប (ម^{3})	**23 362**	**372**	**30**	**319**	**3 612**	**27 693**
ជាភាគរយ	85%	1%	0%	1%	13%	100%

ទិន្នន័យអំពីបរិមាណផលិតផលឈើនាំចេញ យោងតាមស្ថិតិព្រៃឈើកម្ពុជា (រាជរដ្ឋាភិបាល ២០១២) បង្ហាញថា ៨៥% នៃបរិមាណផលិតផលឈើនាំចេញសរុបក្នុងឆ្នាំ ២០១១ គឺនាំចេញទៅប្រទេសចិន និងមានតែ ១៣% ប៉ុណ្ណោះ នាំចេញទៅប្រទសវៀតណាម។ ក៏ប៉ុន្តែស្ថិតិរបស់អង្គការ FAO ឆ្នាំ ២០១១ បានរាយការណ៍ទិន្នន័យខុសពីនេះ គឺ ៧១% នាំចេញទៅប្រទេសវៀតណាម និងមានតែ ១១% ប៉ុណ្ណោះនាំចេញទៅប្រទេសចិន។ យោងតាមស្ថិតិ ទាំងរបស់កម្ពុជា និងទាំងរបស់អង្គការ FAO ឈើចំណាំងទាំងអស់ដែលផលិតនៅប្រទេសកម្ពុជា គឺត្រូវបាននាំចេញទៅប្រទេសចិន។ ទិន្នន័យអំពីបរិមាណផលិតផលឈើនាំចេញក្នុងឆ្នាំ ២០១១ គឺមានទិន្នន័យផ្ទុយគ្នា ព្រោះរាជរដ្ឋាភិបាលរាយការណ៍ថា បរិមាណឈើច្រើនបំផុត គឺនាំចេញទៅប្រទេសចិន

ចំណែកឯអង្គការ FAO រាយការណ៍ថា ឈើច្រើនបំផុតនាំចេញទៅប្រទេសវៀតណាមទៅវិញ។ ប្រភពរបាយការណ៍ស្តីពីបរិមាណផលិតផលឈើក៏ខុសគ្នាផងដែរ ដូចជា អង្គការ FAO រាយការណ៍ថាឈើនាំចេញមានបរិមាណ ១.០៧៧ ម^{3} រីឯប្រភពរបស់រាជរដ្ឋាភិបាលកម្ពុជាមិនឃើញមានបរិមាណឈើនាំចេញក្នុងឆ្នាំ ២០១១ ទេ។ ភាពខុសគ្នារវាងទិន្នន័យក្នុងស្ថិតិព្រៃឈើកម្ពុជា និងទិន្នន័យរបស់អង្គការ FAO ឆ្លុះបញ្ចាំងអំពីបញ្ហាក្នុងការបោះផ្សាយរបាយការណ៍ក្នុងស្ថិតិ។

ប្រអប់ ៩ ៖ ការរកឃើញសំខាន់ៗស្តីពី ផលិតកម្មឈើ និងការនាំចេញឈើ

១. រដ្ឋបាលព្រៃឈើប្រមូលកំណត់ត្រាស្តីពីការផលិតឈើមូលទាំងអស់ពីតំបន់ព្រៃឈើ តាមរយៈបញ្ជីឈើមូល និង លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ប្រើសម្រាប់កំណត់វត្ថុធាតុដើមដែលត្រូវដឹកជញ្ជូនពីព្រៃមកកាន់រោងចក្រកែច្នៃឈើ។ រដ្ឋបាលព្រៃឈើក៏ប្រមូលផងដែរនូវព័ត៌មានអំពីផលិតផលដែលដឹកជញ្ជូនទៅកាន់ទីផ្សារក្នុងស្រុក តាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផល ព្រៃឈើ-២ និង ផលិតផលនាំចេញដែលកត់ត្រាក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល។

២. រដ្ឋបាលព្រៃឈើមិនអាចផ្តល់ទិន្នន័យអំពីផលិផលឈើកែច្នៃចេញពីរោងចក្រកែច្នៃឈើ តាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដល់ក្រុមការងារសិក្សាទេ ដោយសារថាលិខិតអនុញ្ញាតទាំងនោះគឺផ្តល់ដោយរដ្ឋបាលព្រៃឈើមូលដ្ឋាន។ រដ្ឋបាលព្រៃឈើចាប់ផ្តើមតម្រូវឱ្យរោងចក្រកែច្នៃឈើ កត់ត្រាឈើចូល-ឈើចេញប្រចាំថ្ងៃ នៅក្នុងសៀវភៅឈើចូល-ឈើចេញ។

៣. ស្ថិតិប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើបង្ហាញថា ផលិតផលឈើនាំចេញក្នុងឆ្នាំ ២០១១ មាន ៧.៨០០ម^{3} និង១៤.១៩២ ម^{3} ក្នុងឆ្នាំ ២០១២។ ទិន្នន័យបរិមាណផលិតផលឈើនាំចេញនេះ គឺមានការខុសគ្នាគួរឱ្យកត់សម្គាល់ បើប្រៀបធៀបជាមួយទិន្នន័យរបស់អង្គការ FAO ក្នុងឆ្នាំ ២០១១ គឺមាន ១១៧.៧៥១ ម^{3}។ ទិន្នន័យបោះផ្សាយរបស់រាជរដ្ឋាភិបាលក្នុងស្ថិតិព្រៃឈើកម្ពុជា ២០១២ ក៏ខុសគ្នាច្រើនពីទិន្នន័យរបស់អង្គការ FAO ស្តីពីបរិមាណឈើនាំចេញប្រចាំឆ្នាំ ពីឆ្នាំ ២០០៣ ដល់ ២០១១។

៤. ផលិតផលឈើនាំចេញដែលរាយការណ៍ដោយរដ្ឋបាលព្រៃឈើក្នុងឆ្នាំ ២០១១ ថា ឈើស្ទើរតែទាំងអស់ត្រូវបាននាំចេញទៅប្រទេសចិន (៨៥%) រីឯការនាំចេញទៅប្រទេសវៀតណាមមានប្រហែលជា ១៣% នៃចំនួនផលិតផល ឈើនាំចេញសរុប។ ក៏ប៉ុន្តែ ស្ថិតិឆ្នាំ ២០១១ របស់អង្គការ FAO បានរាយការណ៍ខុសគ្នាថា ៧១% នៃបរិមាណផលិតផលឈើនាំចេញសរុប គឺនាំចេញទៅប្រទេសវៀតណាម និងមានតែ ១១% ប៉ុណ្ណោះដែលនាំចេញទៅប្រទេសចិន។

៥. មិនមានទិន្នន័យអំពីបរិមាណផលិតផលឈើដែលកំពុងប្រើប្រាស់នៅក្នុងទីផ្សារក្នុងស្រុកទេ ដូចបានបញ្ជាក់នៅក្នុងតារាង ១៦។

Photo: GFS

៩. គំរូនៃការផ្គត់ផ្គង់ឈើ

៩.១ រចនាសម្ព័ន្ធនៃការផ្គត់ផ្គង់និងចរាចរឈើ

ក្រុមការងារសិក្សាបានបង្កើតគំរូប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ឈើមួយនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកតាមការសិក្សានៅទីវាលក្នុងខេត្តទាំងបី គឺខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តព្រះសីហនុ និងទិន្នន័យឈើមូលពីការប្រមូលផលក្នុងតំបន់ព្រៃឈើមានច្បាប់អនុញ្ញាត និងការនាំឈើចូលតាមរយៈរោងចក្រកែច្នៃឈើ និងពាណិជ្ជកម្មឈើនៅទីផ្សារក្នុងស្រុក និងការនាំឈើចេញ។ ផ្អែកលើគំរូដែលបង្ហាញក្នុងរូប ១២ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់អភិបាលកិច្ចចរាចរឈើក្នុងប្រទេសកម្ពុជា ត្រូវបានចងក្រងជាឯកសារ តាមរយៈការចុះទៅជួបអង្គភាពរាជរដ្ឋាភិបាល តំបន់សម្បទានដីសេដ្ឋកិច្ច និងកន្លែងកែច្នៃឈើ។

ការសិក្សាបានសង្កេតឃើញថា ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណប្រមូលផលឈើនៅក្នុងប្រភេទព្រៃណាមួយ។ សម្បទានដីសេដ្ឋកិច្ច ដែលផ្តល់ដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាចំណែកមួយច្រើនជាងគេនៃបរិមាណឈើនៅក្នុងការផ្គត់ផ្គង់ឈើដល់ទីផ្សារក្នុងស្រុក និងការនាំចេញ។ ដីសម្បទានសេដ្ឋកិច្ចស្ទើរតែទាំងអស់ មានរោងចក្រកែច្នៃឈើនៅក្នុងនោះ។ ក្រសួងបរិស្ថានផ្តល់សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ព្រៃដទៃទៀត ហើយធ្វើការកែច្នៃឈើនៅនឹងកន្លែងសម្រាប់ទាំងការផ្គត់ផ្គង់ការនាំចេញ ក៏ដូចជាសម្រាប់ទីផ្សារក្នុងស្រុក។ ប្រភពទី២នៃការផ្គត់ផ្គង់វត្ថុធាតុដើមឈើសម្រាប់ទីផ្សារ គឺបានមកពីគម្រោងវារីអគ្គិសនីពីការកាប់សម្អាតព្រៃដើម្បីយកឈើពាណិជ្ជកម្ម ដែលមានឈើមូលមានអង្កត់ផ្ចិតធំជាង ៣០សម កូនឈើមានអង្កត់ផ្ចិតតូចជាង ៣០សម។

ឈើទាំងអស់ដែលបានដកហូតពីការកាប់សម្អាតព្រៃក្នុងដីសម្បទានសេដ្ឋកិច្ច ឬគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនោះ ត្រូវកត់ត្រាចូលក្នុងបញ្ជីឈើមូលដែលប្រើសម្រាប់សុំលិខិត

បើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើពីរដ្ឋបាល ព្រៃឈើថ្នាក់កណ្តាលនៅភ្នំពេញ និងសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើពីរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីដឹកជញ្ជូនឈើពីប្លុកប្រមូលផលទៅកាន់រោងចក្រកែច្នៃឈើ បើទោះជារោងចក្រកែច្នៃឈើនោះស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ចក៏ដោយ។

រូបទី ១២ គំរូផ្គត់ផ្គង់ឈើនៅក្នុងប្រទេសកម្ពុជា

ប្រភពឈើ ⟶ ចរាចរឈើ



LP&PC-1 = លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និង លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១
PC-IMEX = លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូល-នាំចេញ
PC-2 = លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២

៩.២ ការពិពណ៌នាអំពី ចរាចរណ៍ និងការនាំចេញ

ដូចបានបង្ហាញនៅក្នុងរូប ៩ ប្រភពឈើទាំងអស់មានចំនួន ៦ សម្រាប់ផ្តល់ឈើមូលនាអនាគត ជាឈើបានមកពីការប្រមូលផលនិងការកាប់សម្អាតដីព្រៃ សម្រាប់ផ្តល់ដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ទៅឱ្យអ្នកកែច្នៃឈើ/អ្នកនាំចេញ និងអ្នកលក់ចែកចាយក្នុងស្រុក។ ក្នុងឆ្នាំ ២០១៣ ឈើត្រូវបានផ្គត់ផ្គង់ពីតំបន់ដីសម្បទានសេដ្ឋកិច្ច គម្រោងវារីអគ្គិសនី នឹងគុបប្រមូលផល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការត្រួតពិនិត្យការប្រមូលផលឈើប្លែកៗពីគ្នា។ គ្រប់ឈើទាំងអស់ដែលបានប្រមូលពីការកាប់សម្អាតដីព្រៃនៅក្នុងដីសម្បទានសេដ្ឋកិច្ច គម្រោងវារីអគ្គិសនី គុបប្រមូលផល និងព្រៃសហគមន៍ ត្រូវតែចុះក្នុងបញ្ជីឈើមូល (សៀវភៅ "ក") ដែលត្រួតពិនិត្យដោយមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន។ សៀវភៅ "ក" គឺប្រើសម្រាប់សុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើ បន្ទាប់ពីបានបង់ថ្លៃសួយសារនិងពន្ធផ្សេងៗរួច។ ការដឹកជញ្ជូនឈើមូលពីព្រៃមកកាន់រោងចក្រកែច្នៃឈើ តម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ រីឯការដឹកជញ្ជូនផលិតផលឈើកែច្នៃ គឺតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដើម្បីដឹកជញ្ជូនមកលក់ដូរសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល គឺសម្រាប់ការដឹកជញ្ជូនផលិតផលសម្រាប់ការនាំចូលឬនាំចេញ។ បច្ចុប្បន្ន មិនតម្រូវឱ្យមានលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ សម្រាប់ការដឹកជញ្ជូនផលិតផលឈើចេញពីប្រភពចម្ការឈើដាំទេ។

៩.២.១ ការផ្គត់ផ្គង់ឈើមូល និងឈើអារ

- **តំបន់ដីសម្បទានសេដ្ឋកិច្ច** ៖ តំបន់ទាំងនេះបង្កើតបានប្រភពចម្បងមួយក្នុងការផ្គត់ផ្គង់ឈើសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។ ក្រសួងបរិស្ថានគ្រប់គ្រងតំបន់ដីសម្បទានសេដ្ឋកិច្ចណាដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ រីឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់គ្រងតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលស្ថិតនៅក្នុងតំបន់ប្រភេទព្រៃឈើដទៃទៀត។ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពុំបានបោះផ្សាយទិន្នន័យស្តីពីការផ្តល់តំបន់សម្បទានដីសេដ្ឋកិច្ច និងបរិមាណផលឈើពីតំបន់ដីសម្បទានសេដ្ឋកិច្ចនីមួយៗនោះទេ។ តាមទិន្នន័យមិនមែនផ្លូវការពីអង្គការ Open Development (២០០៣) បានប៉ាន់ស្មានថា មានតំបន់សម្បទានដីសេដ្ឋកិច្ច ប្រហែល ១,៨ លានហិកតា។ រដ្ឋបាលព្រៃឈើបានកត់ត្រាទិន្នន័យអំពីបរិមាណផលិតផលឈើក្នុងឆ្នាំ ២០១១ មាន ១២៩.៣០០ ម^{3} និង ១២៧.១៤២ ម^{3} ក្នុងឆ្នាំ ២០១២ តាមរយៈទិន្នន័យក្នុងលិខិត បើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។ សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឱ្យក្រុមហ៊ុនឯកជន ដោយយោងតាមផែនការមេ ដែលបានកំណត់តំបន់សម្រាប់កាប់សម្អាតដីព្រៃ និងសម្រាប់ដាំដុះ និងតំបន់សម្រាប់អភិរក្ស។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តម្រូវឱ្យក្រុមហ៊ុនធ្វើសារពើភ័ណ្ឌព្រៃឈើ ដូចជា ផ្ទៃដីដែលត្រូវប្រមូលផលឈើ និងត្រូវកាប់សម្អាតព្រៃ ក៏ប៉ុន្តែក្រសួងបរិស្ថានមិនតម្រូវឱ្យធ្វើសារពើភ័ណ្ឌព្រៃឈើ មុនពេលធ្វើការកាប់សម្អាតដីព្រៃនោះទេ។ ទិន្នន័យសារពើភ័ណ្ឌព្រៃ គឺសម្រាប់គណនាប៉ាន់ស្មាន

ទិន្នផលឈើ ដែលជាចំណុចសំខាន់នៃការចាប់ផ្តើមដំបូងក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ដើម្បីអាចប៉ាន់ស្មានទុកជាមុនអំពីផលិតកម្មឈើមូលនៅក្នុងតំបន់ដែលអនុញ្ញាត។ កង្វះទិន្នន័យស្តីពីទិន្នផលឈើ បណ្តាលឱ្យមិនសូវមានប្រសិទ្ធភាពក្នុងការតាមដាននិងត្រួតពិនិត្យបរិមាណឈើដែលត្រូវដកហូត និងការដឹកជញ្ជូនចេញពីតំបន់ប្រមូលផលឈើ និងពីតំបន់កាប់សម្អាតព្រៃ។ ទិន្នផលឈើដែលប៉ាន់ស្មានចេញពីទិន្នន័យសារពើភ័ណ្ឌព្រៃឈើ អាចប្រើសម្រាប់តាមដានបរិមាណ ផលិតកម្មឈើដែលបានចុះក្នុងបញ្ជីឈើមូល និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងការដឹកជញ្ជូនតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។

- **ព្រៃគុបប្រមូលផល** ៖ គឺជាព្រៃសម្រាប់ប្រមូលផលឈើដោយការកាប់ដកហូតឈើនៅក្នុងព្រៃផ្តល់ផលដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ។ ព្រៃផ្តល់ផលមានទំហំ ១,២ លានហិកតា នៅក្រៅដែនព្រៃសម្បទាន គឺអាចធ្វើការបែងចែកនិងដាក់ឱ្យដេញថ្លៃសម្រាប់ការប្រមូលផលឈើ។ ក្នុងឆ្នាំ ២០១២ គឺមានតែព្រៃគុបមួយគត់នៅក្នុងខេត្តមណ្ឌលគិរី (គុបលេខ៤) ដែលមានទំហំ ១.៣៤២ ហិកតា ត្រូវបានប្រមូលផល ហើយប្រមូលបានឈើតែ ៤.៤៥៦ ម^{3}។ បច្ចុប្បន្ន ការប្រមូលផលឈើក្នុងតំបន់ព្រៃគុប មិនដើរតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់ឈើនោះទេ។
- **គម្រោងវារីអគ្គិសនី** ៖ គម្រោងទាំងនេះគ្របដណ្តប់លើផ្ទៃដីទៅតាមការប៉ាន់ស្មានទំហំរបស់អាងទឹក គឺអាចមានទំហំធំជាង ៣០០.០០០ ហិកតា ដែលកំពុងតែស្ថិតក្នុងដំណាក់កាលអនុវត្តផ្សេងៗគ្នា ការកាប់សម្អាតដីក្នុងតំបន់ត្រូវលិចទឹក និងទីតាំងសាងសង់ទំនប់។ រដ្ឋបាលព្រៃឈើបានធ្វើការកត់ត្រាឈើដែលបានផ្គត់ផ្គង់ពីតំបន់គម្រោងវារីអគ្គិសនីក្នុង ឆ្នាំ ២០១១ គឺមាន ៧.៧៨១ ម^{3} និង ៨.៣៩៦ ម^{3} ក្នុងឆ្នាំ ២០១២ ដែលមានតិចជាង ១០% នៃបរិមាណឈើផ្គត់ផ្គង់សរុប។
- **សហគមន៍ព្រៃឈើ** ៖ ព្រៃសហគមន៍គ្របដណ្តប់លើផ្ទៃដី មានប្រហែលជាជាង ៣០៨.៥៦៤ ហិកតា និងបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក៏ប៉ុន្តែបច្ចុប្បន្ននេះ ពុំឃើញមានការកត់ត្រាអំពីការផ្គត់ផ្គង់ឈើនោះទេ នេះបើយោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១១ និង ២០១២ របស់រដ្ឋបាលព្រៃឈើ។ រាជរដ្ឋាភិបាល បានកំណត់គោលដៅបង្កើតសហគមន៍ព្រៃឈើឱ្យបាន ២ លានហិកតានៅទូទាំងប្រទេសកម្ពុជា ដូច្នេះព្រៃសហគមន៍អាចក្លាយជាប្រភពផ្គត់ផ្គង់ឈើបានមួយចំណែកធំនាពេលអនាគត សម្រាប់រោងចក្រកែច្នៃឈើ។
- **ឈើនាំចូល** ៖ ការនាំឈើចូល គឺគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ហើយក្រសួងពាណិជ្ជកម្មជាអ្នកផ្តល់អាជ្ញាប័ណ្ណនាំចូល។ បើពិនិត្យរបាយការណ៍របស់រដ្ឋបាលព្រៃឈើ បង្ហាញថាបរិមាណឈើនាំចូល ជាប្រភពមួយមិនសំខាន់នោះទេ សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើនៅកម្ពុជា ព្រោះមានតែ ២៥០ម^{3} ប៉ុណ្ណោះដែលបាននាំចូលក្នុងឆ្នាំ ២០១១ និង ១.០០០ម^{3} ក្នុងឆ្នាំ២០១២ (តារាង ១៥)។ ក៏ប៉ុន្តែ បើតាមរបាយការណ៍របស់អង្គការ FAO វិញ ពីឆ្នាំ ២០០៧ ដល់ ២០១១ គឺខុសគ្នាខ្លាំងពីរបាយការណ៍របស់រដ្ឋបាលព្រៃឈើ។ របាយការណ៍របស់អង្គការ FAO បង្ហាញថាមាន ការនាំចូលឈើរហូតដល់ចំនួន ៦.៩២៣ ម^{3} នៅក្នុងឆ្នាំ ២០១១។

- **ឈើរឹបអូស** ៖ តាមកំណត់ត្រាប្រចាំឆ្នាំគឺមានប្រមាណជាជិត ៣% នៃបរិមាណផលិតកម្ម ឈើសរុបក្នុងឆ្នាំ ២០១២ (មើលតារាង ១៩ ខាងក្រោម)។ ស្ទើរតែទាំងអស់នៃការរឹបអូសឈើ គឺមកពីពុំមានឯកសារច្បាប់គ្រប់គ្រាន់ និងជាប្រភេទឈើដែលមានតម្លៃយ៉ាងខ្ពស់ ដូចជា ធ្នង់ បេង និងគ្រញូង។ ក៏ប៉ុន្តែ កំណត់ត្រាប្រចាំឆ្នាំនៃឈើរឹបអូស ពុំបានបញ្ជាក់ថាជាប្រភេទឈើប្រណិតទេ ឬកត់ត្រាអំពីតម្លៃឈើប៉ាន់ស្មានរបស់ឈើរឹបអូសទាំងនោះឡើយ។ ជារឿយៗ ការបង្ក្រាបឈើមិនស្របច្បាប់ រួមមាន ការរឹបអូសឈើ និងរឹបអូសទាំងមធ្យោបាយដឹកជញ្ជូនទៀតផង។ រដ្ឋបាលព្រៃឈើត្រូវកសាងសំណុំរឿង ដើម្បីទទួលបានសាលក្រមពីតុលាការសម្រាប់ធ្វើការដេញថ្លៃលក់ឈើរឹបអូសទាំងនេះ។ អ្នកដេញថ្លៃបាន គឺមានសិទ្ធិស្របច្បាប់ក្នុងការទិញយកឈើទាំងនេះ និងអាចធ្វើការកែច្នៃ និងលក់ដូរផលិតផលឈើកែច្នៃ ទៅទីផ្សារក្នុងស្រុក ឬធ្វើការនាំចេញ។

៩.២.២ ចរាចរណ៍

ការដឹកជញ្ជូនឈើមូលទៅកាន់រោងចក្រកែច្នៃឈើ ដែលស្ថិតនៅក្នុងឬនៅក្រៅដីសម្បទានសេដ្ឋកិច្ច តម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើមូលដ្ឋាន។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ មានទិន្នន័យសង្ខេបអំពីឈើដែលកំពុងដឹកជញ្ជូន បរិមាណឈើ និងគុណភាពឈើតែប៉ុណ្ណោះ ដោយមិនមានទិន្នន័យអំពីអត្តសញ្ញាណរូបវន្តរបស់ឈើទេ ដូចជា លេខឈើ ប្រភេទឈើនិងខ្នាតឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ អាចចេញឱ្យសម្រាប់ការដឹកជញ្ជូនបរិមាណឈើលើសពីមួយរថយន្ត ដូច្នេះ បរិមាណដែលដាក់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ គឺអាចមិនដូចគ្នាទៅនឹងបរិមាណឈើដែលកំពុងដឹកជញ្ជូនលើរថយន្តណាមួយជាក់លាក់នោះទេ។ បញ្ជីឈើមូលត្រូវភ្ជាប់មកជាមួយលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ហើយបញ្ជីនេះអាចប្រើសម្រាប់តាមដានដឹងអំពីប្រភពឈើ។ កង្វះទិន្នន័យច្បាស់លាស់អំពីអត្តសញ្ញាណរបស់ឈើមូល នៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ និងបញ្ជីឈើមូលនោះ អាចធ្វើឱ្យពិបាកក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈើ ជាមួយនឹងឯកសារដឹកជញ្ជូនសម្រាប់ការត្រួតពិនិត្យដើម្បី ទប់ស្កាត់ការបន្លំឈើ។

ការដឹកជញ្ជូនផលិតផលឈើទៅកាន់ទីផ្សារក្នុងស្រុក គឺតម្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើមូលដ្ឋាន។ ការដឹកជញ្ជូនផលិតផលឈើសម្រាប់ធ្វើការនាំចេញ គឺតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល។

- **រោងចក្រកែច្នៃឈើរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច** ៖ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចជាច្រើនមានរោងចក្រកែច្នៃ ឈើរបស់ខ្លួនដែលស្ថិតនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ដើម្បីធ្វើការកែច្នៃឈើ ក្នុងអំឡុងពេលនៃការកាប់សម្អាតដីព្រៃ។ ដីសម្បទានសេដ្ឋកិច្ចនេះនឹងអាចជាប្រភពផ្គត់ផ្គង់ឈើនាពេលអនាគត បើសិនជាក្រុមហ៊ុននេះវិនិយោគទុន លើការដាំឈើឡើងវិញ។ មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចជាច្រើនចង់ដាំកៅស៊ូ ក្រោមគម្រោងកសិ-រុក្ខកម្ម ដែលគេអាចប្រមូលជ័រកៅស៊ូ ពី ២០ទៅ៣០ឆ្នាំ ទើបប្រមូលផលឈើដើមកៅស៊ូ។ រដ្ឋបាលព្រៃឈើកត់ត្រាបានតែរោងចក្រកែច្នៃឈើ ចំនួន ៤៨ រោងចក្រនៅក្នុងឆ្នាំ

២០១២ ក្នុងចំណោមសម្បទានដីសេដ្ឋកិច្ចដែលគេអាចប៉ាន់ស្មានថា មានប្រហែលចំនួន ២៤០ កន្លែង។ ការចងក្រងឯកសារស្តីពីការប្រមូលផលឈើនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច មិនទាន់បានល្អនៅឡើយទេ។ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ ថាមានដីសម្បទានសេដ្ឋកិច្ច ៣៦ កន្លែងមានសកម្មភាពប្រមូលផលឈើ ក៏ប៉ុន្តែក្នុងឆ្នាំ២០១២ តំបន់ដីសម្បទានសេដ្ឋកិច្ចដែលមានសកម្មភាពប្រមូលផលមានរហូតចំនួន ៥៦ កន្លែង។

រោងចក្រកែច្នៃឈើរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច អាចទទួលឈើមូលពីក្រៅតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ខ្លួន។ ការប្រមូលផលឈើមូល កូនឈើ និងអុស ដើម្បីធ្វើការដឹកជញ្ជូន ទោះជាស្ថិតនៅក្នុងឬនៅក្រៅដីសម្បទានសេដ្ឋកិច្ចក្តី គឺត្រូវតែកត់ត្រាចូលក្នុងសៀវភៅ “ក” និងត្រូវមានលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ពីរដ្ឋបាលព្រៃឈើសម្រាប់ជាការអនុញ្ញាតឱ្យប្រើប្រាស់ឈើ បន្ទាប់ពីការបង់ថ្លៃសួយសារ និងពន្ធផ្សេងៗទៀត។ ជាធម្មតា រោងចក្រកែច្នៃឈើដែលស្ថិតនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ទទួលឈើមូលពីការកាប់សម្អាតដីព្រៃ គឺត្រូវធ្វើការវាស់វែងនិងកត់ត្រានៅក្នុងតំបន់ដីសម្បទាននេះ។ បន្ទាប់មក ឈើមូលទាំងនេះ ត្រូវដឹកជញ្ជូនមកកាន់រោងចក្រកែច្នៃឈើ ដោយប្រើលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើមូលដ្ឋាន។ ក៏ប៉ុន្តែ រោងចក្រកែច្នៃឈើដែលស្ថិតនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចណាមួយ ក៏អាចទទួលការផ្គត់ផ្គង់ឈើមូលពីប្រភពខាងក្រៅផងដែរ ដែលកំណត់ដោយលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើណាមួយ។

មានតម្រូវការជាផ្លូវការ ក្នុងប្រការ២ នៃប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតរោងចក្រកែច្នៃឈើ បានចែងថា “ម្ចាស់រោងចក្រកែច្នៃឈើត្រូវតែមានសៀវភៅកត់ត្រាឈើចូលនិងឈើចេញសម្រាប់រោងចក្រ”។ រដ្ឋបាលព្រៃឈើបានចាប់ផ្តើមតម្រូវឱ្យរោងចក្រកែច្នៃឈើរាយការណ៍ជាផ្លូវការ អំពីឈើចូលនិងឈើចេញប្រចាំថ្ងៃតាមទម្រង់សៀវភៅស្តង់ដារមួយ។ ឈើមូលដែលទទួលបានពីក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចអាចលាយឡំគ្នាជាមួយឈើដែលទិញចូលពីប្រភពខាងក្រៅផ្សេងៗទៀត។ ក្រុមការងារសិក្សាបានសង្កេតឃើញនៅក្នុងរោងចក្រកែច្នៃឈើមួយដែលស្ថិតនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច បានប្រើប្រាស់សៀវភៅ “ក” សម្រាប់កត់ត្រាឈើមូលចូលរោងចក្រកែច្នៃ ក៏ដូចជាវត្ថុធាតុដើមសម្រាប់ផលិតកម្មដែរ។ ក៏ប៉ុន្តែ ការធ្វើបែបនេះមិនមែនជាការអនុវត្តជាទូទៅនោះទេ។

ដោយសារតែប្រព័ន្ធបច្ចុប្បន្ននេះមិនទាន់មានប្រព័ន្ធផ្លូវការក្នុងការកត់ត្រាឈើចូលនិងឈើចេញសម្រាប់រោងចក្រកែច្នៃឈើនោះ ការបូកសរុបទិន្នន័យបរិមាណឈើនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលរោងចក្រកែច្នៃឈើទទួលបាន បង្ហាញអំពីបរិមាណឈើស្ពុក និងឈើចូលក្នុងរោងចក្រកែច្នៃ។ ការដឹកជញ្ជូនផលិតផល ឈើកែច្នៃ គឺតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ សម្រាប់ទីផ្សារក្នុងស្រុក ឬលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូលសម្រាប់ធ្វើការនាំចេញ។ ផលិតផលឈើចេញពីរោងចក្រកែច្នៃឈើ អាចប៉ាន់ស្មានបាន ដោយផ្អែកតាមបរិមាណឈើសរុបនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ និង លិខិតអនុញ្ញាត

ដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ក៏ប៉ុន្តែត្រូវគិតទាំងស្តុកផលិតផលឈើ សម្រេចផងដែរ។

យោងតាមកម្រិតទិន្នផលទូទៅនៃការកែច្នៃឈើមូល ចេញជាឈើអារគឺមានពី ៤០% ទៅ ៥០% តាមការគិតទុកជាមុនបរិមាណផលិតផលកែច្នៃក្នុងឆ្នាំ ២០១១ ពីឈើមូល ១២៩.៣០០ម^{3} និង ១២៧.១៤២ ម^{3} ក្នុងឆ្នាំ២០១២ អាចផលិតចេញឈើកែច្នៃបានតិចជាង ៦០.០០០ម^{3} ក្នុង១ឆ្នាំ។ រោងចក្រកែច្នៃឈើដែលស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ច អាចផ្គត់ផ្គង់ផលិតផលឈើដល់ទីផ្សារក្នុងស្រុកនិងផលិតផលនាំចេញ គឺអាស្រ័យទៅតាមការទទួលអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតនាំចេញ។

- **រោងចក្រកែច្នៃឈើមិនមែនជារបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ៖** រោងចក្រនេះផលិតឈើកែច្នៃបឋម ដូចជា ពីឈើមូលទៅជាឈើអារ និងការបន្ថែមតម្លៃដល់ផលិតផលឈើ ដូចជា ការផលិតទៅជា ក្តារចាក់ពុម្ព ក្តារក្រាល និង សង្ហារឹម។ រដ្ឋបាលព្រៃឈើមិនមានទិន្នន័យស្តីពីចំនួនរោងចក្រកែច្នៃឈើដែលស្ថិតនៅក្រៅនិងនៅក្នុងដីសម្បទានសេដ្ឋកិច្ចទេ។

  រោងចក្រកែច្នៃឈើដែលស្ថិតនៅក្រៅដីសម្បទានសេដ្ឋកិច្ច គឺត្រូវទិញវត្ថុធាតុដើមឈើពីតំបន់ដែលមានច្បាប់ អនុញ្ញាតតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកជញ្ជូនវត្ថុធាតុដើមឈើពីព្រៃធម្មជាតិ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើមូលដ្ឋានក្នុងបរិមាណឈើណាមួយកំណត់ ដែលអាចមានបរិមាណឈើលើសពីបន្ទុករថយន្តមួយគ្រឿង។ ថ្វីបើលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ បានកំណត់ទីកន្លែងទទួល (ទិសដៅ) បរិមាណឈើមូល និងគុណភាពឈើដែលត្រូវដឹកជញ្ជូនក្តី តែមិនបានកំណត់ទិន្នន័យឱ្យបានច្បាស់លាស់អំពីឈើទេ ដូចជា លេខឈើ ខ្នាតឈើ។ ដូច្នេះ ការតាមដានឱ្យដឹងអំពីប្រភពឈើមូលដែលមានច្បាប់អនុញ្ញាតគឺមានភាពមិនច្បាស់លាស់ទេ។ ការប្រមូលទិន្នន័យបរិមាណឈើសរុប តាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលរោងចក្រកែច្នៃឈើទទួលបាននោះ អាចឃើញបរិមាណឈើចូលតិចជាងស្តុកឈើ។

  រោងចក្រកែច្នៃឈើមិនតម្រូវឱ្យមានប្រព័ន្ធខ្សែសង្វាក់គ្រប់គ្រងផលិតកម្ម សម្រាប់ត្រួតពិនិត្យផលិតកម្មឬការបែងចែកផលិតផលតាមប្រភេទនោះទេ។ កន្លងមក រដ្ឋបាលព្រៃឈើមិនបានតម្រូវឱ្យកត់ត្រា ឬរាយការណ៍ជាផ្លូវការអំពី ឈើចូល-ឈើចេញពីរោងចក្រកែច្នៃឈើនោះទេ ក៏ប៉ុន្តែបច្ចុប្បន្ននេះ កំពុងតែផ្តួចផ្តើមរៀបចំប្រព័ន្ធកត់ត្រាឈើចូល-ឈើចេញ សម្រាប់ឱ្យរោងចក្រកែច្នៃឈើទាំងអស់អនុវត្ត។ រោងចក្រកែច្នៃឈើអាចផ្គត់ផ្គង់ផលិតផលឈើដល់ទីផ្សារក្នុងស្រុក ដោយប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ឬសម្រាប់ធ្វើការនាំចេញដោយផ្ទាល់ គឺត្រូវមានអាជ្ញាប័ណ្ណនាំចេញពីក្រសួងពាណិជ្ជកម្ម និងការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ (លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ នាំចេញ-នាំចូល) និងគយ។

ប្រអប់ ១០ ៖ ការរកឃើញសំខាន់ៗស្តីពីគំរូផ្គត់ផ្គង់ឈើ

១. មាន៦ប្រភពសម្រាប់ផ្គត់ ឬរំពឹងថាអាចផ្គត់ឈើមូលនិងឈើដល់ខ្សែសង្វាក់ផ្គត់ផ្គង់ ពីតំបន់ព្រៃឈើ ពីការប្រមូលផលឈើ និងការកាប់សម្អាតដីព្រៃ សម្រាប់ផ្គត់ដល់អ្នកកែច្នៃឈើ/អ្នកនាំចេញ និងអ្នកចែកចាយក្នុងស្រុក។

២. ឈើដែលមានប្រភពមកពីដីសម្បទានសេដ្ឋកិច្ច រួមចំណែកជាង ៩០% នៃឈើផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ចំពោះដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ និង ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចំពោះដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ប្រភេទព្រៃផ្សេងៗទៀត។

៣. ឈើដែលបានដកហូត ជាឈើមូល (អង្កត់ផ្ចិតចាប់ពី ៣០ស.ម ឡើង) កូនឈើ (អង្កត់ផ្ចិតតូចជាង ៣០សម) ត្រូវបានចុះក្នុងសៀវភៅ “ក” ដែលប្រើសម្រាប់សុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ការបង់ថ្លៃសួយសារ និងបន្ទាប់មកសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ដឹកជញ្ជូនវត្ថុធាតុដើមឈើពីតំបន់ព្រៃឈើទៅកាន់រោងចក្រកែច្នៃឈើ។

៤. លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ត្រូវបានផ្តល់សម្រាប់ផលិតផលឈើកែច្នៃ រីឯលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ត្រូវបានផ្តល់សម្រាប់ផលិតផលនាំចេញ។

១០. ប្រព័ន្ធតាមដានត្រួតពិនិត្យ

ដើម្បីដោះស្រាយមូលហេតុនៃការបាត់បង់និងរេចរឹលព្រៃឈើ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់លុបបំបាត់សកម្មភាពល្មើសច្បាប់នៅក្នុងវិស័យព្រៃឈើ និងសម្រាប់រៀបចំការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបតាមស្តង់ដារអន្តរជាតិ ក៏ដូចជាតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ២០០១គ រាជរដ្ឋាភិបាលកម្ពុជា ២០០៦)។ រាជរដ្ឋាភិបាលអនុវត្តវិធានការចម្រុះក្នុងការអនុវត្តច្បាប់ស្តីពីព្រៃឈើ រួមមាន ការទប់ស្កាត់ ស្ទើបអង្កេត និងបង្ក្រាប និងជួយគាំទ្រដល់គ្រប់ស្ថាប័នជាតិ និងទីភ្នាក់ងារអន្តរជាតិ។ រាជរដ្ឋាភិបាល គាំទ្រដល់អាជ្ញាធរខេត្ត តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ និងកម្មវិធីផ្សព្វផ្សាយដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន និងលើកទឹកចិត្តពួកគេឱ្យចូលរួមចំណែកក្នុងការអនុវត្តច្បាប់ និងការតាមដានឧក្រិដ្ឋកម្មព្រៃឈើ។

នាយកដ្ឋាននីតិកម្មនិងពង្រឹងការអនុវត្តច្បាប់ មានតួនាទីនិងភារកិច្ច៖

- សិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងកសាងបទដ្ឋានច្បាប់ បទដ្ឋានបច្ចេកទេស លិខិតបទដ្ឋានក្រោមច្បាប់ និងរៀបចំយុទ្ធសាស្ត្រ និងផែនការពង្រឹងការអនុវត្តច្បាប់គ្រប់គ្រង និងតាមដានវាយតម្លៃការអនុវត្តផែនការ

- ផ្សព្វផ្សាយ វាយតម្លៃ ណែនាំលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន តាមដាន និង រាយការណ៍ពីបទល្មើសព្រៃឈើ ការកាប់រាន ឈូសឆាយដីព្រៃឈើ
- គ្រប់គ្រង តាមដានឯកសារសំណុំរឿងបទល្មើសព្រៃឈើគ្រប់ប្រភេទ ពង្រឹងទំនាក់ទំនង និងសហការជាមួយស្ថាប័ន និងអង្គការជាតិ អន្តរជាតិដើម្បីអភិវឌ្ឍន៍ និងអនុវត្តការងារពង្រឹងការអនុវត្តច្បាប់
- តាមដានស្រាវជ្រាវអង្កេត ដើម្បីពង្រឹងការអនុវត្តនីតិវិធីច្បាប់ និងអន្តរាគមន៍បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃក្នុងទូទាំងប្រទេសតាមការចាំបាច់
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋបាលព្រៃឈើប្រគល់ជូន

១០.១ ការពិពណ៌នាអំពីប្រព័ន្ធតាមដានត្រួតពិនិត្យ

មានប្រព័ន្ធធ្វើអាជីវកម្មឈើខុសគ្នានៅក្នុងតំបន់ព្រៃឈើ ដូចជា ប្រព័ន្ធកាប់រលីង និងប្រព័ន្ធកាប់ដោយជ្រើសរើស។ ការកាប់រលីងត្រូវបានអនុវត្តនៅតំបន់សម្រាប់ការអភិវឌ្ឍ និងជាតំបន់សម្បទានដីសេដ្ឋកិច្ចសម្រាប់ធ្វើការដាំដុះ ឬការប្រើប្រាស់ផ្សេងៗទៀត ដែលត្រូវកាប់សម្អាតឈើចេញទាំងអស់ (ឈើមូល កូនឈើ អុស)។ ការកាប់ជ្រើសរើស គឺអនុវត្តនៅតាមព្រៃគុបក្នុងតំបន់ព្រៃផ្តល់ផល ដែលតម្រូវឱ្យមានការធ្វើសារពើភ័ណ្ឌព្រៃ និងជ្រើសរើសដើមឈើសម្រាប់ប្រមូលផល ហើយត្រូវមានបញ្ជីឈើនៅក្នុងផែនការប្រមូលផលឈើ។ សម្បទានិកព្រៃគុបប្រចាំឆ្នាំត្រូវចុះបញ្ជីនៅរដ្ឋបាលព្រៃឈើនូវគ្រឿងចក្រ និងយានយន្តទាំងអស់ ដើម្បីទទួលបានប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់យានយន្ត និងរណារយន្តអារកាត់ឈើទាំងអស់។ មានការហាមឃាត់ចំពោះគ្រឿងចក្រ និងយានយន្តដែលមិនបានចុះបញ្ជី និងមិនមានការអនុញ្ញាតឱ្យធ្វើចរាចរនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

ក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺតម្រូវឱ្យធ្វើសារពើភ័ណ្ឌព្រៃឈើដើម្បីធ្វើការប៉ាន់ស្មានបរិមាណឈើឈរនៅក្នុងតំបន់ព្រៃនេះ។ ក្រោយពីបានកាប់រំលំ ឈើមូលត្រូវបានវាស់វែង និងកត់ត្រាចូលក្នុងបញ្ជីឈើមូល (សៀវភៅ “ក”) ដែលជាធម្មតាគឺធ្វើនៅក្នុងប្លុកប្រមូលផល ហើយមន្ត្រីផ្នែក និងសង្កាត់ រដ្ឋបាលព្រៃឈើវាយញញ្ជូរត្រាមួយ ដើម្បីបញ្ជាក់ថាឈើមូលត្រូវបានវាស់វែងនិងចុះក្នុងសៀវភៅ “ក”។ ឈើមូលត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទ និងគុណភាពរបស់ឈើ រួមមាន ប្រភេទឈើមានចំណាត់ថ្នាក់ ដូចជា **ឈើប្រណិត ឈើលេខ១ ឈើលេខ២ ឈើលេខ៣** និងប្រភេទឈើក្រៅចំណាត់ថ្នាក់។ ឈើមូល និងកូនឈើ គឺត្រូវបង់ថ្លៃសួយសារ។ ក្រោយពីសម្បទានិកបានបង់ថ្លៃសួយសារនិងបុព្វលាភរួច រដ្ឋបាលព្រៃឈើវាយញញ្ជូរត្រាថែមចំនួនបីទៀត។ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើបានដៅសម្គាល់ឈើទាំងនេះ។ ជាសរុប គឺមានស្នាមញញ្ជូរត្រាចំនួន៤នៅលើកំណាត់ឈើទាំងអស់ ហើយត្រូវបានធ្វើការផ្ទៀងផ្ទាត់ដោយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល។ ផ្នែករដ្ឋបាលព្រៃឈើផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដើម្បីឱ្យក្រុមហ៊ុនមានលទ្ធភាពដឹកជញ្ជូនឈើមូលទាំងនោះ។

គ្រប់ផលនិងអនុផលព្រៃឈើទាំងអស់ត្រូវតែជញ្ជូនពីព្រៃមកដាក់នៅគំនរឈើតែក្នុងរយៈពេល

មួយខែក្រោយពីការប្រមូលផល ដើម្បីឱ្យមន្ត្រីរដ្ឋបាលព្រៃឈើធ្វើការវាស់វែង និងដើម្បីទទួលបានលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ គឺផ្តល់ដោយផ្នែករដ្ឋបាលព្រៃឈើ ដើម្បីធ្វើការដឹកជញ្ជូនឈើមូលទៅកាន់រោងចក្រកែច្នៃឈើដែលបានកំណត់ទិសដៅ។

នៅក្នុងរោងចក្រកែច្នៃឈើ ផ្នែកនិងសង្កាត់រដ្ឋបាលព្រៃឈើមានមន្ត្រីរៀងៗខ្លួនដើម្បីធ្វើការត្រួតពិនិត្យឈើមូល ចូលនិងឈើអារនិងផលិតផលកែច្នៃចេញ។ ផ្នែករដ្ឋបាលព្រៃឈើផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ ដើម្បីដឹកផលិតផលឈើពីរោងចក្រកែច្នៃឈើទៅកាន់ទីផ្សារក្នុងស្រុក។ ក្រុមហ៊ុនដែលមានបំណងធ្វើការនាំចេញផលិតផលឈើ តម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ដែលផ្តល់ដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើនិងសហប្រតិបត្តិការអន្តរជាតិនៃរដ្ឋបាលព្រៃឈើភ្នំពេញ។

ការដឹកជញ្ជូនឈើមូល/ឈើទាំងអស់ ត្រូវបានត្រួតពិនិត្យនៅតាមបណ្តាចំណុចត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន(ថ្នាក់ផ្នែក/សង្កាត់)។ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើឯកសារទាំងអស់ដែលជាតម្រូវការសម្រាប់ការដឹកជញ្ជូនឈើ និងផលិតផលឈើ។ មន្ត្រីរដ្ឋបាលព្រៃឈើមានថ្នាក់ផ្នែក និងសង្កាត់នៅក្នុងក្រុមត្រួតពិនិត្យរបស់ខណ្ឌរដ្ឋបាលព្រៃឈើ ធ្វើការដើរល្បាតនៅតាមដងផ្លូវ និងក្នុងដែនព្រៃដែលជាចំណែកមួយនៃការតាមដានត្រួតពិនិត្យ។ ដើម្បីបង្ក្រាបការកាប់ឈើនិងដឹកជញ្ជូនឈើអនាធិបតេយ្យ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានអាចទទួលព័ត៌មានពីប្រភពផ្សេងៗ ដូចជា ពីអ្នកភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត តាមរយៈខ្សែបណ្តាញរបស់គេ។

ក្នុងករណីសង្កេតឃើញមានអំពើល្មើសច្បាប់ក្នុងការដឹកជញ្ជូនឈើ មន្ត្រីរដ្ឋបាលព្រៃឈើ កងរាជអាវុធហត្ថ និង នគរបាលដែលមានការចាត់តាំង មានសិទ្ធិចាប់ឃាត់ជនល្មើស រឹបអូសផលិតផលឈើដែលផ្ទុកលើមធ្យាបាយដឹកជញ្ជូន ហើយចងក្រងសំណុំរឿងបទល្មើសជាក់ស្តែងដាក់មកខណ្ឌរដ្ឋបាលព្រៃឈើ ហើយបន្ទាប់មកទៀត បញ្ជូនសំណុំរឿងទៅតុលាការ។

១០.២ ឈើរឹបអូស

ផ្អែកតាមទិន្នន័យដែលបានប្រមូលនៅពេលចុះទស្សនកិច្ចនៅទីវាល រដ្ឋបាលព្រៃឈើអាចធ្វើការរឹបអូសឈើ ដែលមានប្រភពមកពីព្រៃធម្មជាតិ ជាឈើដែលគ្មានការអនុញ្ញាតក្នុងការធ្វើអាជីវកម្ម ឬការដឹកជញ្ជូន(លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ) ឬលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។ ឈើដាមិនតម្រូវឱ្យមានលិខិតបើកផ្លូវ ដឹកជញ្ជូនផល-អនុផលព្រៃឈើ ឬលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើទេ។

មន្ត្រីរដ្ឋបាលព្រៃឈើ កងរាជអាវុធហត្ថ និងនគរបាលមូលដ្ឋាន ធ្វើការងាររួមគ្នាដើម្បីចាប់រឹបអូសឈើល្មើសច្បាប់ និងឃាត់ខ្លួនជនល្មើសដែលពាក់ព័ន្ធ។ ជារឿយៗ ការបង្ក្រាបបទល្មើសនេះគឺមានការចាប់ឃាត់ឈើ និងមធ្យោបាយដឹកជញ្ជូន។ ជំហានដំបូង នៅពេលត្រួតពិនិត្យឃើញថាជាឈើល្មើសច្បាប់នោះ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ធ្វើកំណត់ហេតុបទល្មើសជាក់ស្តែងនិងរបាយការណ៍ស៊ើបអង្កេតដំបូង។

របាយការណ៍ស៊ើបអង្កេតដំបូង-ប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើ

នៅពេលដែលត្រួតពិនិត្យឃើញថាជាឈើល្មើសច្បាប់ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានចាំបាច់ត្រូវធ្វើកំណត់ហេតុបទល្មើសជាក់ស្តែង និងរបាយការណ៍ស៊ើបអង្កេតដំបូង ដើម្បីចងក្រងឯកសារភស្តុតាងនៃសកម្មភាពបទល្មើសនិងវត្ថុតាង ហើយបញ្ជូនរបាយការណ៍ស៊ើបអង្កេតដំបូងទៅរដ្ឋបាលព្រៃឈើ ដើម្បីបញ្ជូលទៅក្នុងប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើ។ របាយការណ៍ស៊ើបអង្កេតដំបូង រៀបរាប់លម្អិតអំពីទិដ្ឋភាពនៃបទល្មើសព្រៃឈើ រួមមាន ៖

- លេខករណីបទល្មើសព្រៃឈើ
- របាយការណ៍ឧប្បត្តិហេតុដែលកើតមានឡើង
- ទីកន្លែងកើតហេតុ
- កាលបរិច្ឆេទ
- ប្រភេទព្រៃ
- ព័ត៌មានអំពីជនសង្ស័យ
- ព័ត៌មានស្តីពីមធ្យោបាយដឹកជញ្ជូនឈើល្មើសច្បាប់
- ព័ត៌មានស្តីពីវត្ថុតាងដែលត្រូវចាប់រក្សាទុក
- ព័ត៌មានលម្អិតផ្សេងៗស្តីពីបទល្មើស រួមមាន រូបថត និងភស្តុតាងដទៃទៀត។

លេខករណីបទល្មើសប្រើសម្រាប់ជាលេខយោងសម្គាល់ សម្រាប់ការចុះព័ត៌មានលម្អិតស្តីពីវត្ថុតាងរឹបអូស ទៅក្នុងមូលដ្ឋានទិន្នន័យប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើ។ រដ្ឋបាលព្រៃឈើធ្វើការស៊ើបអង្កេតបន្ត (កំណត់ហេតុឧក្រិដ្ឋកម្ម/បទល្មើសព្រៃឈើ) ដោយយោងតាមរបាយការណ៍ស៊ើបអង្កេតដំបូង ដើម្បីកំណត់បន្ថែមថាតើ បទល្មើសត្រូវពិន័យអន្តរការណ៍ ឬបញ្ជូនទៅតុលាការវិនិច្ឆ័យ។ មូលដ្ឋានទិន្នន័យនេះ គឺប្រើប្រាស់ក្នុងការផ្តល់ព័ត៌មានលម្អិតអំពីករណីនីមួយៗ សម្រាប់រាយការណ៍ទៅតុលាការ ឬការពិន័យអន្តរការណ៍។ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យនេះ ប្រើប្រាស់ដោយរដ្ឋបាលព្រៃឈើ សម្រាប់រាយការណ៍ផ្ទៃក្នុង ក៏ដូចជាភស្តុតាងសម្រាប់តុលាការ។ ប្រសិនបើតុលាការសម្រេចឱ្យរដ្ឋបាលព្រៃឈើឈ្នះក្តីនេះ ឈើនិងមធ្យោបាយដឹកជញ្ជូនទាំងនោះនឹងត្រូវលក់ឡាយឡុង តាមរយៈការដេញថ្លៃ។ ប្រាក់ទាំងអស់ដែលទទួលបានពីការពិន័យអន្តរការណ៍ និងការលក់វត្ថុតាងរឹបអូស គឺត្រូវបង់ចូលរតនាគារជាតិ។ មានការផ្តល់ប្រាក់រង្វាន់សម្រាប់ការបង្ក្រាបបទល្មើសព្រៃឈើ គឺ ៤៩% ជាប្រាក់រង្វាន់សម្រាប់អ្នកអនុវត្ត(រដ្ឋបាលព្រៃឈើមូលដ្ឋាន និងនគរបាល) ១% សម្រាប់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ៥០% សម្រាប់ជាថវិកាជាតិ។

ឈើរឹបអូសត្រូវបានកត់ត្រាទុកនិងបូកសរុបប្រចាំឆ្នាំ ហើយក៏មានផលប៉ះពាល់ដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើខ្លះដែរ ព្រោះថា ភាគច្រើនក្នុងចំណោមឈើទាំងនោះ មានប្រភេទឈើប្រណិតដែលមានតម្លៃខ្ពស់។ កំណត់ត្រានៃឈើ រឹបអូសនៅក្នុងប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើ កំណត់ប្រភេទវត្ថុតាងបទល្មើស ដូចជាប្រភេទឈើប្រណិត និងតម្លៃប៉ាន់ស្មានរបស់ឈើ។ បរិមាណឈើរឹបអូសសរុបដែលបានកត់ត្រាមានជិត ៣% នៃបរិមាណផលិតផលឈើសរុប (តារាង១៩)។

តារាង ១៩ កំណត់ត្រាឈើរឹបអូស ឆ្នាំ ២០០៨ - ២០១២ (នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ ២០១៣)

	2008	2009	2010	2011	2012
ចំនួនករណី	569	498	1 378	1 673	993
ឈើមូល/ជ្រុង (ម^{3})	355	1 053	1 443	815	2 255
ឈើអារ (ម^{3})	1 540	1 573	7 739	2 704	2 337
សរុប (ម^{3})	**1 895**	**2 626**	**9 182**	**3 519**	**4 592**

ប្រអប់ ១១ ៖ ការរកឃើញសំខាន់ៗស្តីពីការតាមដានត្រួតពិនិត្យ

១. ការតាមដានត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើ រួមមាន ការវាស់វែង និងការកត់ត្រាឈើមូលចូលបញ្ជី ការត្រួតពិនិត្យ រូបវន្ត និងការវាយញញ្ជូរត្រាសម្គាល់។ ប៉ុន្តែនៅខ្វះទិន្នន័យស្តីពីសក្តានុពលឈើ និងទិន្នផលឈើប្រមូលបានជាក់ស្តែង នៅក្នុងតំបន់ទទួលបានការអនុញ្ញាតឱ្យប្រមូលផលឈើ។

២. ទិន្នន័យសារពើភ័ណ្ឌព្រៃឈើក្នុងតំបន់ទទួលបានការអនុញ្ញាតឱ្យប្រមូលផល និងការកាប់សម្អាតដីព្រៃ គឺមានសារសំខាន់បំផុតក្នុងការប៉ាន់ស្មានទិន្នផលប្រមូលផលឈើ។ កង្វះទិន្នន័យសារពើភ័ណ្ឌព្រៃ ធ្វើឱ្យប្រសិទ្ធភាពក្នុងការតាមដានបរិមាណឈើដែលបានដកហូត និងការដឹកជញ្ជូនឈើពីតំបន់ព្រៃឈើ គឺនៅមានកម្រិត។ ទិន្នផលប៉ាន់ស្មានពីទិន្នន័យសារពើភ័ណ្ឌព្រៃ អាចប្រើប្រាស់សម្រាប់ការត្រួតពិនិត្យតាមដានបរិមាណផលិតផលឈើដែលបានចុះក្នុងបញ្ជីឈើមូល (សៀវភៅ "ក") និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងការដឹកជញ្ជូនតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ

៣. ប្រសិទ្ធភាពក្នុងការតាមដានត្រួតពិនិត្យឈើមូលដែលឆ្លងកាត់ និងឈើដែលដឹកទៅកាន់រោងចក្រកែច្នៃឈើ គឺនៅមានកម្រិត នៅពេលដែលបរិមាណឈើក្នុងបញ្ជីឈើមូលមិនត្រូវគ្នាទៅនឹងឈើជាក់ស្តែងនៅលើរថយន្តកំពុង ដឹកជញ្ជូនក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដែលភ្ជាប់មកជាមួយ។

៤. រដ្ឋបាលព្រៃឈើបានបង្កើតប្រព័ន្ធតាមដានឧក្រិដ្ឋកម្មព្រៃឈើ សម្រាប់កត់ត្រាករណីបទល្មើសព្រៃឈើទាំងអស់ នូវព័ត៌មានលម្អិតស្តីពីផលិតផលព្រៃឈើដែលបានរឹបអូស និងមធ្យោបាយដឹកជញ្ជូនបទល្មើស។ រដ្ឋបាលព្រៃឈើធ្វើរបាយការណ៍ស៊ើបអង្កេតដំបូង និងតាមដានបន្ត ផ្អែកតាមកំណត់ហេតុបទល្មើសជាក់ស្តែង ដើម្បីកំណត់ប្រភេទបទល្មើស ថាតើត្រូវពិន័យអន្តរការណ៍ ឬបញ្ជូនបទល្មើសទៅតុលាការដើម្បីវិនិច្ឆ័យ។

Photo: GFS

១១. ការពិភាក្សា និង ការផ្តល់អនុសាសន៍

១១.១ ប្រភពធនធាន

គោលបំណងសំខាន់នៃការសិក្សានេះ គឺដើម្បីបង្កើនការយល់ដឹងអំពីចរាចរណ៍ឈើក្នុងប្រទេសកម្ពុជា និងយល់ដឹងអំពីតួនាទីរបស់អង្គភាពរាជរដ្ឋាភិបាល ដែលចូលរួមពាក់ព័ន្ធក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឈើ ចាប់ពីតំបន់ព្រៃឈើរហូតដល់ការកែច្នៃឈើ និងការធ្វើពាណិជ្ជកម្ម។ កម្ពុជាមានដីព្រៃឈើចំនួន ១០,៨ លានហិកតា បើយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សាគម្របព្រៃឈើ ៦០%។ វិស័យព្រៃឈើត្រូវបានគ្រប់គ្រងដោយក្រសួងចំនួនពីរគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន។ ច្បាប់សំខាន់ៗដែលទាក់ទងនឹងការផ្គត់ផ្គង់ឈើមានច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (មករា ២០០៨)។ រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីព្រៃឈើជាតិ ដែលបានកំណត់ការប្រើប្រាស់ដីមានចំនួន៥ប្រភេទ នៅលើផ្ទៃដី ១០,៨ លានហិកតានេះ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាននិង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការសិក្សាអំពីចរាចរណ៍ឈើនេះ បានចងក្រងឯកសារអំពីចំណាត់ថ្នាក់ព្រៃឈើ ដែលរួមមានតំបន់ការពារធម្មជាតិ (៣,៣ លានហិកតា) ព្រៃការពារ (១,៦ លានហិកតា) ព្រៃសហគមន៍ (០,២ លានហិកតា) និងព្រៃសម្បទាន(៣,៣ លានហិកតា)។ ចំពោះប្រភេទព្រៃផ្តល់ផលដែលមានទំហំ ១,២ លានហិកតានោះ រដ្ឋបាលព្រៃឈើមិនទាន់បានកំណត់ទៅតាមបណ្តាខេត្ត ឬគួរផែនទី ច្បាស់លាស់ទេ។ តំបន់ការពារធម្មជាតិដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ត្រូវចែកជាតំបន់ស្នូល និងតំបន់អភិរក្សដែលមិនអនុញ្ញាតឱ្យប្រមូលផលសម្រាប់ការផ្គត់ផ្គង់ឈើទេ រីឯតំបន់

ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ គឺអនុញ្ញាតឱ្យសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសហ-គមន៍។ អនុលោមតាមច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ២០០៨ ក្រសួងបរិស្ថានកំពុងពិចារណាដល់ការរៀបចំចែកប្រភេទតំបន់ទាំងនេះនៅក្នុងតំបន់ការពារធម្មជាតិ ក៏ប៉ុន្តែត្រូវការជំនួយគាំទ្រដើម្បីធ្វើការសិក្សាតាមបែបវិទ្យាសាស្ត្រ ក្នុងការកំណត់ប្រភេទតំបន់ទាំងនេះនៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ។

ប្រអប់ ១២ ៖ អនុសាសន៍

១. ចំណាត់ថ្នាក់ការប្រើប្រាស់ដីរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាតំបន់ការពារធម្មជាតិ ព្រៃការពារ ព្រៃសហគមន៍ព្រៃសម្បទាន និងព្រៃផ្តល់ផល ត្រូវកំណត់ឱ្យបានច្បាស់តាមខេត្តនីមួយៗ គួរជាផែនទី និងធ្វើការបោះផ្សាយ។

២. ការចែកប្រភេទតំបន់ប្រើប្រាស់នៅក្នុងតំបន់ការពារធម្មជាតិជា តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និង តំបន់សហគមន៍ ត្រូវកំណត់ឱ្យបានច្បាស់លាស់ គួរជាផែនទី និងធ្វើការបោះផ្សាយ ត្រូវអនុវត្តតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(២០០៨)។ ក្រសួងបរិស្ថានអាចប្រើប្រាស់ជំនួយពីខាងក្រៅដើម្បីកំណត់ប្រភេទតំបន់ទាំង៤នេះនៅក្នុងតំបន់ការពារធម្មជាតិ។

៣. ព្រៃសម្បទានមានប្រមាណជា ៣,៣ លានហិកតា ដែលស្ថិតក្នុងការផ្អាកដំណើរការអាជីវកម្ម គួរតែពិនិត្យឡើងវិញ ដើម្បីធ្វើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ស្របតាមស្តង់ដារអន្តរជាតិ។ ព្រៃសម្បទានដែលនៅមានសុពលភាពកិច្ចព្រមព្រៀងស្របច្បាប់ និងមានការគ្រប់គ្រងល្អ អាចផ្គត់ផ្គង់ឈើស្របច្បាប់មួយចំណែកធំដល់ទីផ្សារ។

៤. ការបង្កើតសហគមន៍ព្រៃឈើ មានទិសដៅបង្កើនរហូតដល់ ២លានហិកតា។ បច្ចុប្បន្នព្រៃសហគមន៍មានទំហំ ៣០៨.៥៦៤ ហិកតា ដែលមានការទទួលស្គាល់ អាចនឹងក្លាយជាប្រភពឈើស្របច្បាប់មួយចំណែកក្នុងការផ្គត់ផ្គង់ឈើដល់ទីផ្សារ។ ការគ្រប់គ្រងព្រៃសហគមន៍តម្រូវឱ្យមានការគាំទ្រពីរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និង សហគមន៍ព្រៃឈើសាមី ដើម្បីធានាថាព្រៃឈើត្រូវគ្រប់គ្រងបានល្អ និងផ្តល់ផល និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព។

៥. រដ្ឋបាលព្រៃឈើគួរផ្តល់ព័ត៌មានច្បាស់លាស់អំពីតំបន់ព្រៃផ្តល់ផល ព្រៃឯកជន និងចម្ការឈើ ដែលអាចផ្តល់ឈើដល់ខ្សែសង្វាក់ផ្គត់ផ្គង់ឈើក្នុងប្រទេសកម្ពុជានាពេលអនាគត។

១១.២. ការផ្គត់ផ្គង់ឈើ

ការផ្គត់ផ្គង់ឈើជាចម្បងក្នុងប្រទេសកម្ពុជា គឺបានមកពីតំបន់សម្បទានដីសេដ្ឋកិច្ចដែលស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងបរិស្ថានចំពោះសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំពោះសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ព្រៃឈើផ្សេងៗទៀត។ ទិន្នន័យសម្បទានដីសេដ្ឋកិច្ចមានមិនច្បាស់លាស់ និងមិនមានការបោះផ្សាយ ដូចជាអំពីផ្ទៃដី ទីតាំង និងបរិមាណឈើដែលបានផ្គត់ផ្គង់ដល់ទីផ្សារ។ តាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើក្នុងឆ្នាំ ២០១១ - ២០១២ បង្ហាញថា បរិមាណឈើមូល (អង្កត់ផ្ចិតចាប់ពី ៣០សមឡើងទៅ) ពីតំបន់ដីសម្បទានសេដ្ឋកិច្ចទាំងអស់ ដែលបានចូលទៅកាន់ទីផ្សារ គឺមានចំនួន តិចជាង ១៣០.០០០ម^{3} ក្នុង១ ឆ្នាំ។ ប្រភពឈើដទៃទៀតដូចជាគម្រោងវារីអគ្គិសនី និងព្រៃគុបប្រចាំឆ្នាំ មានតិចជាង ១០% នៃបរិមាណឈើផ្គត់ផ្គង់សរុប។

តារាង ២០ កំណត់ត្រាសង្ខេបអំពីការផ្គត់ផ្គង់និងចរាចរឈើនៅកម្ពុជា

ប្រភព/សកម្មភាព	ផ្ទៃដីប្រហាក់ប្រហែល (ហិកតា)	បរិមាណឈើ (ម^3) ២០១១	បរិមាណឈើ (ម^3) ២០១២
សម្បទានដីសេដ្ឋកិច្ច (ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)	1 800 000	129 300	127 100
គម្រោងវារីអគ្គិសនី	305 000	7 781	8 396
ព្រៃគុបប្រចាំឆ្នាំ	1 300	0	4 456
តំបន់អាជីវកម្ម២	401 000	0	0
ព្រៃសហគមន៍	207 000	0	0
ឈើនាំចូល	NA	250	1 000
សរុបបរិមាណឈើផ្គត់ផ្គង់	**NA**	**137 331**	**140 952**
ផលិតផលឈើនាំចេញ	NA	27 800	16 192

បច្ចុប្បន្នការផ្គត់ផ្គង់ឈើក្នុងប្រទេសកម្ពុជា គឺបានមកពីសម្បទានដីសេដ្ឋកិច្ចដែលជាផ្នែកមួយនៃសកម្មភាពកាប់សម្អាតដីព្រៃ ប៉ុន្តែការផ្គត់ផ្គង់មិនអាចផ្តល់បានក្នុងរយៈពេលវែងបានទេ បើសិនជាផ្ទៃដីមួយចំនួនធំត្រូវបានដាំជាដំណាំកៅស៊ូ និង ដំណាំកសិកម្មផ្សេងៗទៀតនោះ។ ចម្ការកៅស៊ូត្រូវការកម្លាំងពលកម្មច្រើនសម្រាប់ការងារចាក់ និងប្រមូលជ័រ ក៏ប៉ុន្តែ នៅតំបន់ជនបទ ពុំមានកំលាំងពលកម្មនេះគ្រប់គ្រាន់សម្រាប់ការងារនេះឡើយ។ ជាធម្មតាចម្ការកៅស៊ូ គឺត្រូវថែរក្សាចាក់យកជ័រពី ២៥ដល់៣០ឆ្នាំ ទើបកាប់ប្រមូលផលដើមកៅស៊ូ ហើយដាំសារជាថ្មីឡើងវិញ។ បច្ចុប្បន្ន តំបន់ដីសម្បទានសេដ្ឋកិច្ច កំពុងតែកាប់សម្អាតព្រៃ តែមិនមានការដាំដុះតាមកិច្ចព្រមព្រៀងទេ។ ក្រុមការងារសិក្សាបានសង្កេតឃើញថា នៅខេត្តមណ្ឌលគីរី និងខេត្តក្រចេះ មានតំបន់សម្បទានដីសេដ្ឋកិច្ចមួយចំនួនបានកាប់សម្អាតព្រៃរួចអស់ហើយ តែមិនឃើញមានការដាំដំណាំអ្វីទេ។

កំណត់ត្រាអំពីការផ្គត់ផ្គង់ឈើ គឺពឹងផ្អែកលើការប្រមូលទិន្នន័យ តាមរយៈការប្រមូលផលដែលមាននៅក្នុងបញ្ជីឈើមូល (សៀវភៅ "ក") ដែលប្រើសម្រាប់សំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើដើម្បីប្រើប្រាស់ឈើទាំងនោះបាន។ តំបន់ដីសម្បទានសេដ្ឋកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានការធ្វើសារពើភ័ណ្ឌព្រៃជាប្រព័ន្ធក្នុងប្លុកប្រមូលផល និងដោយមានការគាំទ្រពីរដ្ឋបាលព្រៃឈើ។ ទិន្នន័យសារពើភ័ណ្ឌព្រៃអាចផ្តល់នូវការប៉ាន់ស្មានមួយគួរឱ្យជឿជាក់អំពីបរិមាណឈើដែលអាចដកហូតបានពីដីសម្បទានសេដ្ឋកិច្ច។ សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន (នៅក្នុងតំបន់ការពារធម្មជាតិ) មិនតម្រូវឱ្យធ្វើសារពើភ័ណ្ឌព្រៃឈើមុនធ្វើការប្រមូលផលទេ ដូច្នេះគេពុំអាចដឹងអំពីបរិមាណឈើដែលត្រូវដកហូតពីតំបន់ដីសម្បទានសេដ្ឋកិច្ចនោះទេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ ធ្វើការផ្ទៀងផ្ទាត់ត្រឹមតែកំណត់ត្រាផលឈើដែលបង្ហាញក្នុង

បញ្ជីឈើមូល (សៀវភៅ "ក") ដើម្បីផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ វាយញញ្ជរគ្រាលើឈើ និងផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ សម្រាប់ការដឹកជញ្ជូនឈើតែប៉ុណ្ណោះ។ កង្វះខាតក្នុងការត្រួតពិនិត្យបរិមាណឈើពីដីសម្បទានសេដ្ឋកិច្ចក្នុងតំបន់ការពារធម្មជាតិ អាចផ្តល់លទ្ធភាពច្រើនសម្រាប់បន្លំការប្រមូលផលឈើ ដោយបន្ថែមឈើពីក្រៅតំបន់ដីសម្បទាននេះ ដាក់បញ្ចូលទៅក្នុងបញ្ជីឈើមូល។ បញ្ហានេះត្រូវពិនិត្យឡើងវិញ ព្រោះជាផ្នែកមួយនៃការចុះបញ្ជីឈើមូល និងចេញលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។

ប្រអប់ ១៣ ៖ អនុសាសន៍

១. តំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណសម្បទានដីសេដ្ឋកិច្ច ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់ឱ្យបានច្បាស់តាមខេត្តនីមួយៗគួរជាផែនទីនិងធ្វើការផ្សព្វផ្សាយ។ តំបន់សម្បទានដីសេដ្ឋកិច្ចមិនគួរត្រួតគ្នាជាមួយនឹងតំបន់ព្រៃសម្បទានទេ លើកលែងតែមានកិច្ចព្រមព្រៀងជាផ្លូវការជាមួយព្រៃសម្បទានិក។

២. តំបន់ប្រើប្រាស់ដោយចីរភាពនៅក្នុងតំបន់ការពារធម្មជាតិ ចាំបាច់ត្រូវកំណត់ឱ្យបានរួចរាល់សិន មុនធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីឱ្យស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨)។

៣. គួរតែធ្វើសារពើភ័ណ្ឌព្រៃប៉ាន់ស្មានបរិមាណឈើស្តុក ដែលជាផ្នែកមួយនៃការរៀបចំផែនការមេកំណត់តំបន់សម្រាប់ជាំដុះ និងដើម្បីប៉ាន់ស្មានឱ្យបានច្បាស់លាស់អំពីធនធានឈើដែលអាចដកហូតបាននៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។

៤. បរិមាណឈើដែលដកហូត និងតំបន់ដែលត្រូវកាប់សម្អាតក្នុងដីសម្បទានសេដ្ឋកិច្ច និងតំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណផ្សេងៗទៀត គួរមានកំណត់ត្រាច្បាស់លាស់ និងបញ្ចូលទិន្នន័យទាំងនេះក្នុងរបាយការណ៍ប្រចាំឆ្នាំ។

៥. ផ្ទៃដីបានប្រមូលផលឈើ(កាប់សម្អាត)រួចក្នុងដីសម្បទានសេដ្ឋកិច្ច គួរធ្វើការដាំដុះស្របទៅតាមកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច។

៦. ឈើពាណិជ្ជកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារ ដែលមានប្រភពមកពីសហគមន៍ព្រៃឈើដែលមានកិច្ចព្រមព្រៀង និង មានការឯកភាពលើផែនការគ្រប់គ្រង និងមានប្រភពឈើចេញចម្ការឈើ គួររៀបចំឯកសារតាមប្រព័ន្ធអនុវត្តបច្ចុប្បន្ន ដូចគ្នាទៅនឹងឈើដែលចេញពីព្រៃធម្មជាតិដែរ ដោយធ្វើការកត់ត្រាឈើដកហូតចូលទៅក្នុងសៀវភៅបញ្ជីឈើ ហើយការដឹកជញ្ជូនឈើ គឺត្រូវប្រើលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាត ដឹកជញ្ជូនផល-អនុផលព្រៃឈើ។

៧. គួរធ្វើការតាមដានតាមការកាប់សម្អាតព្រៃក្នុងគម្រោងទំនប់វារីអគ្គិសនី និងធ្វើការកត់ត្រាឈើមូលដែលប្រមូលបានដោយផ្អែកតាមផែនការមេ។

៨. ត្រូវរក្សាទុកកំណត់ត្រាការនាំឈើចូលជាមួយនឹងអាជ្ញាប័ណ្ណនាំចូល ឯកសារនេះត្រូវកំណត់ទម្រង់ព័ត៌មានតាមស្តង់ដារអន្តរជាតិ (សុខដុមកម្មប្រព័ន្ធកូដ) ដូចជា ព័ត៌មានស្តីពីគោលដៅនៃការនាំចូលមាឌឈើបរិមាណឈើ។ល។ដែលអាចប្រើសម្រាប់ការផ្ទៀងផ្ទាត់និងរាយការណ៍ទៅអង្គការអន្តរជាតិ ដូចជា អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក(ITTO) និងអង្គការ FAO។

១១.៣. ការដឹកជញ្ជូនឈើ និង ការលក់ដូរ

ការដឹកជញ្ជូនឈើគឺយោងតាមបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ ក) ដែលបានកត់ត្រាឈើមូលទាំងអស់តាមលេខឈើ ប្រភេទ ខ្នាត និងមាឌឈើ និងត្រូវបានប្រើប្រាស់សម្រាប់សុំលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ បន្តមកគឺការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើជូនរដ្ឋ។ លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ យោងទៅតាមបញ្ជីផល-អនុផលព្រៃឈើ និងសង្ខេបទិន្នន័យគ្រប់គ្រាន់នៃបញ្ជីផល-អនុផលព្រៃឈើ។ ផ្នែករដ្ឋបាលព្រៃឈើផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដើម្បីដឹកជញ្ជូនឈើទៅកាន់ទិសដៅ ដោយផ្អែកតាមបរិមាណដែលមាននៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ មិនបានបញ្ជាក់អំពីឈើជាក់ស្តែងដែលបានដឹកទេ ប៉ុន្តែជាទិន្នន័យសង្ខេបអំពីបរិមាណ និងមាឌឈើតាមចំណាត់ថ្នាក់គុណភាពឈើ។ មិនមានប្រព័ន្ធច្បាស់លាស់សម្រាប់ការផ្ទៀងផ្ទាត់ថា ឈើដែលកំពុងដឹកជញ្ជូន គឺមកពីតំបន់ដែលមានច្បាប់អនុញ្ញាតនោះទេ ក្នុងខណៈដែលលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ មិនមានព័ត៌មានអំពីបញ្ជីផល-អនុផលព្រៃឈើជាក់ស្តែង (រួមមានលេខឈើ) ដែលមានក្នុងសៀវភៅ “ក” ។ បន្ថែមលើនេះ បរិមាណឈើដែលបានសរសេរនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ អាចជាបរិមាណសម្រាប់តែមួយរថយន្ត ឬ ច្រើនរថយន្ត គឺយោងតាមតែបរិមាណដែលមានក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ ដូច្នេះ បច្ចុប្បន្ននេះ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ គឺមិនមានព័ត៌មានគ្រប់គ្រាន់ឡើយសម្រាប់ធ្វើការតាមដានដឹងអំពីប្រភពដើមនៃឈើដែលកំពុងដឹកជញ្ជូននោះទេ។

ប្រអប់ ១៤ ៖ អនុសាសន៍

១. លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ សង្ខេបព័ត៌មានអំពីមាឌឈើមូលដែលផ្អែកតាមគុណភាពឈើដាក់ចូលក្នុងបញ្ជីឈើមូលមួយដាច់ដោយឡែក និងបញ្ជាក់ឱ្យបានច្បាស់អំពីឈើដែលត្រូវដឹកជញ្ជូនតាមរថយន្តនីមួយៗ ដើម្បីអាចផ្ទៀងផ្ទាត់ព័ត៌មានរបស់ឈើទាំងនោះបាន។ មាឌឈើអាចនឹងខុសគ្នារវាងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ និងបញ្ជីឈើមូល ព្រោះថាលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ អាចមានមាឌឈើមូលច្រើនជាង ដែលត្រូវដឹកជញ្ជូនតាមរថយន្តលើសពីមួយគ្រឿង។ បញ្ហានេះ ធ្វើឱ្យលំបាកក្នុងការផ្ទៀងផ្ទាត់បរិមាណឈើដែលកំពុងដឹកជញ្ជូន ថាជាចំណែកណាមួយនៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ ដែលអាចពិនិត្យផ្ទៀងផ្ទាត់រវាងសៀវភៅ “ក” និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១។

២. លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ គួរតែចេញឱ្យតាមបរិមាណឈើដែលអាចផ្ទុកលើរថយន្តតែ ០១គ្រឿង និងបង្ហាញព័ត៌មានតាមបញ្ជីឈើមូល ដូចជា លេខឈើ ប្រភេទឈើ ទំហំឈើ និងមាឌរបស់ឈើ ដែលកំពុងដឹកជញ្ជូនលើមធ្យោបាយដឹកជញ្ជូនណាមួយ ពីតំបន់មានអាជ្ញាប័ណ្ណណាមួយ និងមានលិខិតបើកផ្លូវ ដឹកជញ្ជូនផល-អនុផលព្រៃឈើទៅកាន់គោលដៅណាមួយ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ គួរដាក់ព័ត៌មានណាដែលអាចធ្វើការផ្ទៀងផ្ទាត់ដឹងថាឈើដែលកំពុងដឹកជញ្ជូន គឺត្រូវគ្នាជាមួយនឹងបណ្តាឯកសារដែលកំពុងប្រើប្រាស់សម្រាប់ការដឹកជញ្ជូន។

១១.៤. ផលិតកម្មក្នុងស្រុក និងការនាំចេញ

កំណត់ត្រាផលិតកម្មឈើក្នុងស្រុកពីរោងចក្រកែច្នៃឈើ ពុំបានអនុវត្តផ្ទាល់ដោយរដ្ឋបាលព្រៃឈើទេ ប៉ុន្តែគេអាចរកបានកំណត់ត្រាទាំងនេះ អំពីការដឹកជញ្ជូនផលិតផលទៅកាន់ទៅទីផ្សារក្នុងស្រុក តាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ និងកំណត់ត្រាអំពីការនាំចេញ តាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ នាំចេញ-នាំចូល ដូចជាបរិមាណឈើអារ និងផលិតផលឈើចាក់ពុម្ព។ រដ្ឋបាលព្រៃឈើមានផែនការប្រមូលទិន្នន័យផលិតកម្មឈើប្រចាំថ្ងៃរបស់រោងចក្រកែច្នៃឈើ ស្តីពីបរិមាណឈើចូលនិងឈើចេញនៅក្នុងឆ្នាំ ២០១៤។ ផលិតកម្មឈើ អាចធ្វើការប៉ាន់ស្មានបានតាមរយៈអត្រាប៉ាន់ស្មានទិន្នផលឈើកែច្នៃចេញពីឈើមូល។ ជាទូទៅ ទិន្នផលឈើកែច្នៃ មានពី ៤០%ទៅ៥០%។ ដូច្នេះ ឈើមូលចំនួន ១២៩.០០០ម^{3} ដែលផលិតបានក្នុងឆ្នាំ ២០១១ (យោងតាមទិន្នន័យ ក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ) អាចផ្តល់ឈើអារប្រហែលពី ៥០.០០០ ដល់ ៥៥.០០០ម^{3}។ ភាគរយ នៃផលិតផលឈើដែលបានលក់ប្រើប្រាស់ទីផ្សារក្នុងស្រុក អាចគណនាបាន ដោយយកបរិមាណប៉ាន់ស្មាន ផលិតផល ឈើសរុប(ខាងលើ) ដកបរិមាណឈើនាំចេញដែលមាននៅក្នុងរបាយការណ៍។ ដូច្នេះក្នុងឆ្នាំ ២០១១ ការប៉ាន់ស្មាន ផលិតផលឈើគឺ ៥០.០០០ម^{3} ដក ២៥.០០០ ម^{3} ជាបរិមាណឈើនាំចេញ(ក្នុងរបាយការណ៍) បង្ហាញថាទីផ្សារក្នុង ស្រុកប្រើប្រាស់ឈើប្រមាណជា ៥០% នៃផលិតកម្មឈើសរុប។

ក្រុមហ៊ុនដែលចង់នាំចេញផលិតផលឈើ ត្រូវតែមានអាជ្ញាប័ណ្ណនាំចេញពីក្រសួងពាណិជ្ជកម្ម។ អាជ្ញាប័ណ្ណនាំចេញមានសុពលភាពក្នុងរយៈពេលមួយកំណត់ (អតិបរមា ២ខែ) រីឯគោលការណ៍នាំចេញ ជាទូទៅគឺមានរយៈពេលមួយឆ្នាំ។ គោលការណ៍នាំចេញមួយអាចផ្តល់អាជ្ញាប័ណ្ណលើសពីមួយ។ ផលិតផលនាំចេញត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គយ រដ្ឋបាលព្រៃឈើ និងកាំកុងត្រូលនៅមុនការផ្ទុកទំនិញចូលទៅក្នុងកុងតឺន័រនៅឯរោងចក្រកែច្នៃឈើ ឬកំពង់ផែ ដែលជាផ្នែកមួយនៃនីតិវិធីជម្រះទំនិញនាំចេញ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ផ្តល់លិខិតអនុញ្ញាតនាំចេញ ទៅតាមជើងដឹកជញ្ជូនជាក់លាក់ណាមួយសម្រាប់ធ្វើការនាំចេញតាមកិច្ចសន្យាលក់។ ប្រព័ន្ធនាំចេញនៅប្រទេសកម្ពុជា រួមមាន ការត្រួតពិនិត្យផលិតផលនាំចេញ ដែលអាចតាមដានដឹងអំពីអ្នកនាំចេញ និងរោងចក្រកែច្នៃឈើ តាមរយៈឯកសារនាំចេញដូចជា លិខិតអនុញ្ញាត ដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល លិខិតអនុញ្ញាតនាំចេញ(គោលការណ៍នាំចេញ) និងអាជ្ញាប័ណ្ណនាំចេញ។

ទិន្នន័យបោះផ្សាយដោយរដ្ឋាភិបាលក្នុងស្ថិតិព្រៃឈើកម្ពុជា ២០១២ មានការខុសគ្នាច្រើនពីរបាយការណ៍ របស់អង្គការ FAO អំពីបរិមាណឈើនាំចេញសរុបប្រចាំឆ្នាំ ពីឆ្នាំ ២០០៣ ដល់ ២០១១។

ប្រអប់ ១៥ ៖ អនុសាសន៍

១. ទោះបីមានការតម្រូវជាផ្លូវការឱ្យម្ចាស់រោងចក្រកែច្នៃឈើត្រូវមានសៀវភៅកត់ត្រាឈើចូលនិងឈើចេញពីរោងចក្រកែច្នៃឈើក៏ដោយ រដ្ឋបាលព្រៃឈើក៏ត្រូវប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីរោងចក្រកែច្នៃឈើ និងផលិតផលឈើកែច្នៃដែរ គឺតាមរយៈកំណត់ត្រាដែលមានក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-២ និង លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល សម្រាប់ធ្វើការវិភាគ និងធ្វើផែនការក្នុងវិស័យព្រៃឈើ។ រដ្ឋបាលព្រៃឈើបានចាប់ផ្តើមតម្រូវឱ្យរោងចក្រកែច្នៃឈើរាយការណ៍ជាផ្លូវការអំពីឈើចូល-ឈើ ចេញប្រចាំថ្ងៃ តាមទម្រង់កត់ត្រាស្តង់ដារមួយ។

២. ការកត់ត្រាវត្ថុធាតុដើមឈើចូលដែលមិនទាន់កែច្នៃ ដូចជា ចំនួនឈើមូល មាឌឈើ និងឯកតាផលិតកម្ម (ទិន្នផលឈើកែច្នៃចេញពីឈើមូល) ដើម្បីអាចផ្តល់ជាប្រព័ន្ធមួយដែលអាចផ្ទៀងផ្ទាត់បាន រវាងបរិមាណឈើមូលចូល និងបរិមាណផលិតផលឈើកែច្នៃដែលទទួលបាន(ចេញ)។

៣. កំណត់ត្រាការនាំចេញឈើតម្រូវឱ្យរក្សាទុកជាមួយអាជ្ញាប័ណ្ណនាំចេញ ដែលអាចផ្ទៀងផ្ទាត់ផលិតផលជាមួយឯកតាផលិតកម្ម។ កំណត់ត្រាផលិតផលឈើនាំចេញ គួរកំណត់ឱ្យបានច្បាស់លាស់តាមស្តង់ដារអន្តរជាតិ (សុខដុមនីយកម្មប្រព័ន្ធកូដ HS. Code) អំពីទិសដៅ (កន្លែងទទួល) មាឌឈើ បរិមាណឈើ។ល។ ដែលអាចប្រើប្រាស់សម្រាប់តាមដាន អំពីប្រភពផលិតផលឈើ និងអាចរាយការណ៍ទៅអង្គការអន្តរជាតិ ដូចជាអង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក(ITTO) និងអង្គការ FAO។

១១.៥. ការតាមដានត្រួតពិនិត្យ

នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ស្ថិតនៅក្រោមរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានតួនាទី ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅទូទាំងប្រទេសតាមការចាំបាច់ ដើម្បីគាំទ្រឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រង ការការពារ និងការអភិវឌ្ឍព្រៃឈើ។ នៅក្នុងតំបន់ព្រៃឈើ មានប្រព័ន្ធធ្វើអាជីវកម្មឈើកាប់រលីង និងប្រព័ន្ធធ្វើអាជីវកម្មឈើកាប់ដោយជ្រើសរើស។ ប្រព័ន្ធកាប់រលីង គឺអនុវត្តនៅតំបន់អភិវឌ្ឍន៍ និងតំបន់សម្បទានដីសេដ្ឋកិច្ច សម្រាប់ធ្វើការដាំដុះឬការប្រើប្រាស់ផ្សេងៗទៀត គឺត្រូវកាប់ព្រៃឈើចេញទាំងអស់ (ឈើមូល កូនឈើ និងអុស)។ ប្រព័ន្ធកាប់ដោយជ្រើសរើស គឺអនុវត្តសម្រាប់ព្រៃគុបប្រចាំឆ្នាំ នៅក្នុងតំបន់ព្រៃផ្តល់ផល ដែលតម្រូវឱ្យធ្វើសារពើភ័ណ្ឌព្រៃឈើ ដើម្បីជ្រើសរើសដើមឈើសម្រាប់កាប់ប្រមូលផលឈើ ដែលមាននៅក្នុងផែនការប្រមូលផលឈើ។

ផលនិងអនុផលព្រៃឈើទាំងអស់ ត្រូវតែដឹកជញ្ជូនពីព្រៃទៅកាន់គំនរឈើ ក្នុងរយៈពេលមួយខែក្រោយការប្រមូលផល ដើម្បីធ្វើការវាស់វែងដោយមន្ត្រីរដ្ឋបាលព្រៃឈើ ដើម្បីធ្វើសៀវភៅកត់ត្រាឈើមូល (សៀវភៅ "ក") និង ទទួលបានលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ។ លិខិតអនុញ្ញាតដឹកជញ្ជូនផល- អនុផលព្រៃឈើ ដែលផ្តល់ ដោយផ្នែករដ្ឋបាលព្រៃឈើ ដើម្បីដឹកជញ្ជូនឈើមូលទៅកាន់រោងចក្រកែច្នៃឈើណាមួយជាក់លាក់។ លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ មិនបរិយាយទិន្នន័យគ្រប់គ្រាន់អំពីឈើមូលដែលកំពុងដឹកជញ្ជូន សម្រាប់ធានាដល់ការត្រួតពិនិត្យជាក់ស្តែង ដែលអាចតាមដានដឹងថាឈើមូលនេះចេញពីតំបន់មានច្បាប់អនុញ្ញាតមកកាន់រោងចក្រកែច្នៃឈើនោះទេ។ ការដឹកជញ្ជូនឈើមូល/ឈើត្រូវបានធ្វើការត្រួត

ពិនិត្យនៅតាមចំណុចត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើ ដែលជាចំណែកមួយនៃការពង្រឹងការអនុវត្តច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីផ្ទៀងផ្ទាត់គ្រប់ឯកសារសម្រាប់ការដឹកជញ្ជូនឈើ។ មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋាន (ខណ្ឌ ផ្នែក សង្កាត់) ក៏មានការយាមល្បាត និងត្រួតពិនិត្យតាមដងផ្លូវ និងជុំវិញតំបន់ព្រៃឈើ ដែលជាផ្នែកនៃការតាមដានត្រួតពិនិត្យផងដែរ។

ប្រអប់ ១៦ ៖ អនុសាសន៍

១. កង្វះទិន្នន័យស្តីពីកម្រិតកំណត់ទិន្នផលក្នុងការប្រមូលផល ធ្វើឱ្យការតាមដានត្រួតពិនិត្យបរិមាណឈើដកហូត និងការដឹកជញ្ជូនពីតំបន់ប្រមូលផលនិងតំបន់កាប់សម្អាតព្រៃ មិនសូវមានប្រសិទ្ធភាពទេ។ ទិន្នផលប៉ាន់ស្មាន ចេញពីទិន្នន័យសារពើភ័ណ្ឌព្រៃឈើអាចប្រើប្រាស់សម្រាប់តាមដានបរិមាណផលិតកម្មដែលបានកត់ត្រានៅក្នុងបញ្ជីឈើមូល(សៀវភៅ “ក”) និងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ហើយនិងការដឹកជញ្ជូនតាមរយៈលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។

២. ការតាមដានឈើមូលក្នុងការដឹកជញ្ជូន និងឈើចូលរោងចក្រកែច្នៃឈើ អាចកែលម្អកាន់តែប្រសើរថែមទៀត បើសិនជាលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ-១ មានព័ត៌មានស្តីពីអត្តសញ្ញាណច្បាស់លាស់របស់ឈើមូលដែលកំពុងដឹកជញ្ជូន(ពីតំបន់ព្រៃឈើមានអាជ្ញាប័ណ្ណ)នៅលើមធ្យោបាយដឹកជញ្ជូនណាមួយនោះ ដូចជា លេខឈើ ប្រភេទឈើ និង ខ្នាតឈើ ដែលអាចធ្វើការវាស់វែង និងផ្ទៀងផ្ទាត់បាន។

១១.៦. កិច្ចព្រមព្រៀងភាពជាដៃគូស្ម័គ្រចិត្ត

ការសិក្សាអំពីចរាចរឈើនេះ គឺដើម្បីផ្តល់ព័ត៌មានលម្អិតអំពីប្រព័ន្ធនិងនីតិវិធីដែលមានក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ និងលើកឡើងវិធីដោះស្រាយដែលចាំបាច់ ដើម្បីធានាភាពស្របច្បាប់ក្នុងការផ្គត់ផ្គង់ឈើនៅកម្ពុជា។ ថ្មីៗនេះសហភាពអឺរ៉ុបបានចេញបទប្បញ្ញត្តិស្តីពីការធ្វើពាណិជ្ជកម្មឈើដែលបានចូលជាធរមានតាំងពីខែមីនា ឆ្នាំ ២០១៣ ឥឡូវ នេះផលិតផលឈើខុសច្បាប់ត្រូវបានហាមនាំចូលទៅកាន់ទីផ្សារសហភាពអឺរ៉ុប។ ក៏ប៉ុន្តែ តាមការប៉ាន់ស្មាន គឺមានឈើ ប្រមាណតែ ១០% ប៉ុណ្ណោះដែលបាននាំចូលសហភាពអឺរ៉ុប ហើយគេជឿថាប្រហែល ២០% នៃចំនួននោះ គឺនាំចូលពីប្រភពមិនស្របច្បាប់។ ប្រទេសកម្ពុជាផ្គត់ផ្គង់ឈើត្រូពិកទៅកាន់ប្រទេសចិន វៀតណាម និងថៃ ជាទីប្រមូលផ្តុំរោងចក្រ កែច្នៃឈើផ្គត់ផ្គង់ទៅកាន់ទីផ្សារអឺរ៉ុប (បទបង្ហាញរបស់ EU FLEGT Facility នៅកូឡាឡាំពូ ម៉ាឡេស៊ី ថ្ងៃទី៨ កក្កដា ២០១១)។ ជាទូទៅ ឈើនៅតំបន់ត្រូពិកមានកេរ្តិ៍ឈ្មោះមិនល្អទេ អំពីភាពស្របច្បាប់របស់ឈើ។ អ្នកផ្គត់ផ្គង់ឈើចាំបាច់ត្រូវមានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីប្រភពឈើ ដើម្បីឆ្លើយតបនឹងប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ សម្រាប់ការនាំឈើចូលទៅសហភាពអឺរ៉ុប ឬក៏មានអាជ្ញាប័ណ្ណតាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូរស្ម័គ្រចិត្ត (VPA) ដើម្បីបំពេញតាមបទប្បញ្ញត្តិស្តីពីការធ្វើពាណិជ្ជកម្មឈើក្នុងសហភាពអឺរ៉ុប។

ជាទូទៅ គឺតែងតែមិនមានសង្គតិភាពគ្នាច្រើនដែរ រវាងប្រភពទិន្នន័យផ្សេងៗគ្នា ចំពោះបញ្ហាមួយចំនួននៅក្នុងការកត់ត្រាអំពី ការផ្គត់ផ្គង់ ផលិតកម្ម និងពាណិជ្ជកម្មឈើ។ ប្រភពធនធានព្រៃឈើសំខាន់បំផុត គឺត្រូវធ្វើអត្តសញ្ញាណកម្ម រួមមាន តំបន់ព្រៃផ្តល់ផល១,២ លាន ហិកតា ក៏

ដូចជាព័ត៌មានទាក់ទងនឹងអាជ្ញាប័ណ្ណសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាក្រសួងបរិស្ថានផងដែរ។ មិនមានក្រសួងណាមួយបានបោះផ្សាយព័ត៌មានអំពីតំបន់ដីសម្បទានសេដ្ឋកិច្ចនិងផែនទីតំបន់សម្បទានដីសេដ្ឋកិច្ចនៅតាមខេត្តនីមួយៗទេ ដែលជាតម្រូវការសម្រាប់ការតាមដានប្រភពស្របច្បាប់របស់ឈើ និងសម្រាប់បំពេញតាមតម្រូវការរបស់ប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ។

បញ្ហាសំខាន់បំផុតមួយនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ឈើនៅកម្ពុជា គឺការចុះបញ្ជីឈើមូលទៅក្នុងសៀវភៅ “ក” ដែលជាចំណែកមួយនៃដំណើរការសុំលិខិតបើកផ្លូវដឹកជញ្ជូន និងសម្រាប់រដ្ឋបាលព្រៃឈើអាចធ្វើការវាស់ឈើមូលទាំងអស់ (ដែលមានអង្កត់ផ្ចិតចាប់ពី ៣០ស.ម) និងកត់ត្រាកូនឈើ និងអុស ដែលបានប្រមូលផលពីការកាប់សម្អាតព្រៃធម្មជាតិ។ នៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ មិនបានដាក់ព័ត៌មានច្បាស់លាស់ អំពីឈើដែលត្រូវដឹកជញ្ជូន គឺដាក់តែព័ត៌មានសង្ខេបអំពីបរិមាណឈើ និងចំណាត់ថ្នាក់គុណភាពដែលមិនគ្រប់គ្រាន់សម្រាប់ការតាមដាន និងត្រួតពិនិត្យទេ។

ដំណោះស្រាយជាមូលដ្ឋានសម្រាប់ តម្លាភាព និងការតាមដាន-ត្រួតពិនិត្យ ៖

- ធ្វើអត្តសញ្ញាណកម្មជាផ្លូវការអំពីតំបន់ព្រៃឈើដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ការប្រើប្រាស់ដីព្រៃ ដែលអាចបង្កើតជាប្រភពផ្គត់ផ្គង់ឈើសម្រាប់កម្ពុជា។
- ការផ្តល់អាជ្ញាប័ណ្ណកាប់សម្អាតតំបន់ព្រៃសម្រាប់ការប្រមូលផលឈើ និងការកាប់សម្អាតព្រៃនៅក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច គម្រោងអភិវឌ្ឍន៍ និងព្រៃសហគមន៍ គួរមានផែនទីស្តីពីតំបន់ដែលបានអនុញ្ញាតឱ្យ។
- ការផ្តល់អាជ្ញាប័ណ្ណ គួរមានឯកសារប៉ាន់ស្មានបរិមាណឈើដែលអាចជឿជាក់បាន នៅក្នុងតំបន់ព្រៃដែលអនុញ្ញាតឱ្យ។ មានសក្តានុពលក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីធ្វើអត្តសញ្ញាណកម្មដើមឈើ និងការកត់ត្រាទិន្នន័យ។
- ធានាថាឈើទាំងអស់ដែលប្រមូលបាននៅក្នុងតំបន់ដែលបានអនុញ្ញាត គឺត្រូវចុះបញ្ជីទៅក្នុងបញ្ជីផល-អនុផលព្រៃឈើ (សៀវភៅ “ក”) និងដាក់ព័ត៌មានយោងស្តីពីតំបន់មានអាជ្ញាប័ណ្ណប្រមូលផលឈើ និងលិខិតអនុញ្ញាត។
- រក្សាទុកកំណត់ត្រាលម្អិត និងសង្ខេបស្តីពីការលក់ឈើដែលមាននៅក្នុងលិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើ ជាមួយបញ្ជីផល-អនុផលព្រៃឈើ និងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ ដែលគួរមានអត្តសញ្ញាណឈើមូលឱ្យបានច្បាស់លាស់ (ដូចជា លេខឈើ ប្រភេទឈើ និង ខ្នាតឈើ) ដែលត្រូវដឹកជញ្ជូននៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើ។
- តម្រូវឱ្យរោងចក្រកែច្នៃឈើធ្វើការចុះបញ្ជីឈើជាផ្លូវការ សម្រាប់ការត្រួតពិនិត្យរបស់អង្គភាពរាជរដ្ឋាភិបាល។
- រោងចក្រកែច្នៃឈើត្រូវមានទិន្នន័យអំពីផលិតកម្មឈើ ដែលអាចធ្វើការតាមដាននិងត្រួតពិនិត្យឈើចូល។

- ការកត់ត្រាទិន្នន័យស្តីពីការនាំចេញផលិតផលឈើ ត្រូវធ្វើឱ្យបានច្បាស់និងស្របទៅតាមស្តង់ដារអន្តរជាតិ រួមមាន បរិមាណ មាឌឈើ និងគោលដៅដឹកជញ្ជូន ហើយត្រូវរក្សាទុកទិន្នន័យរបស់ក្រុមហ៊ុននាំចេញទាំងអស់។

ការចូលរួមក្នុងដំណើរការឆ្ពោះទៅរកកិច្ចព្រមព្រៀងភាពដៃគូស្ម័គ្រចិត្ត (VPA) គឺបង្ហាញអំពីការប្តេជ្ញាជាផ្លូវការរបស់ប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាចំណុចខ្សោយទាំងឡាយដែលលើកឡើងនៅក្នុងរបាយការណ៍នៃការសិក្សាអំពីចរាចរឈើនេះ ដើម្បីកែលម្អដល់ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច និងដើម្បីត្រួសត្រាយផ្លូវ ឆ្ពោះទៅរកការធ្វើពាណិជ្ជកម្មឈើមានអាជ្ញាប័ណ្ណ FLEGT ។ ដំណើរការឈានទៅរកការរៀបចំកិច្ចព្រមព្រៀង VPA អាចចាប់ផ្តើមបាន បើសិនប្រទេសកម្ពុជាធ្វើទំនាក់ទំនងជាផ្លូវការជាមួយនឹងសហភាពអឺរ៉ុប ដើម្បីបង្ហាញអំពីការប្តេជ្ញារបស់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍប្រព័ន្ធធានាភាពស្របច្បាប់របស់ឈើ TLAS ជាផ្លូវការ។

ដំណើរការចរចាកិច្ចព្រមព្រៀង VPA តម្រូវឱ្យអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិទាំងអស់ត្រូវចូលរួមក្នុងការកំណត់ភាពស្របច្បាប់របស់ឈើ ការរៀបចំប្រព័ន្ធ TLAS និងចូលរួមចំណែកក្នុងការពិភាក្សាអំពីតម្លាភាព ដើម្បីធានាដល់ការអភិវឌ្ឍកិច្ចព្រមព្រៀង VPA ប្រកបដោយការជឿជាក់ និងមានការគាំទ្រពីថ្នាក់ជាតិ។ ការចរចាកិច្ចព្រមព្រៀង VPA រវាងសហភាពអឺរ៉ុបនិងប្រទេសកម្ពុជាតម្រូវឱ្យមានការចូលរួមពីបណ្តាអ្នកពាក់ព័ន្ធមកពីស្ថាប័នរាជរដ្ឋាភិបាល វិស័យឧស្សាហកម្ម និងសង្គមស៊ីវិល។ ព័ត៌មានដែលបានផ្តល់ក្នុងការសិក្សាចរាចរឈើនេះ អាចប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មានក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ និងក្នុងការចរចាជាមួយសហភាពអឺរ៉ុប ដើម្បីកំណត់ចំណុចចន្លោះប្រហោង និងភាពទន់ខ្សោយនៅក្នុងប្រព័ន្ធបច្ចុប្បន្ន និងកំណត់បណ្តាសកម្មភាពចាំបាច់សម្រាប់ដោះស្រាយបញ្ហាទាំងនេះ។

សហភាពអឺរ៉ុបបានចរចាកិច្ចព្រមព្រៀង VPA ជាមួយប្រទេសមួយចំនួន។ មាន៦ ប្រទេសបានចរចាដោយជោគជ័យ ហើយកំពុងតែរៀបចំប្រព័ន្ធមួយចំនួន និងកសាងសមត្ថភាពដើម្បីស្វែងយល់ប្រការទាំងឡាយដែលមានក្នុងកិច្ចព្រមព្រៀង VPA របស់គេ។ នៅពេលដែលប្រព័ន្ធទាំងនេះដំណើរការស្របតាមប្រការទាំងឡាយនៅក្នុងកិច្ចព្រមព្រៀង VPA នោះ ប្រទេសនេះនឹងអាចនាំចេញផលិតផលឈើដែលមានអាជ្ញាប័ណ្ណ FLEGT ទៅកាន់សហភាពអឺរ៉ុប។

ឯកសារយោង

FAOSAT 2013. អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) ស្ថិតិឈើនិងផលិតផលឈើនាំចេញ នាំចូល រ៉ូម អ៊ីតាលី http://faostat.fao.org/site/628/default.aspx

រដ្ឋបាលព្រៃឈើ ឆ្នាំ២០១៣ ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា ឆ្នាំ២០១៣

អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក (ITTO) ឆ្នាំ២០០៥ ស្ថានភាពនៃការគ្រប់គ្រងព្រៃឈើតំបន់ត្រូពិក ប្រទេសកម្ពុជា

អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក (ITTO) ឆ្នាំ២០១០ គម្រោងព្រៃឈើកម្ពុជា ITTO-PD493/07 Rev.1 (F).

ក្រសួងបរិស្ថាន ឆ្នាំ២០១១, ផែនការសកម្មភាពអនុវត្តអនុសញ្ញាស្តីអំពីជីវចម្រុះ កម្មវិធីការងារតំបន់ការពារធម្មជាតិ បានដាក់ជូនទៅលេខាធិការដ្ឋានអនុសញ្ញាស្តីអំពីជីវចម្រុះ នាថ្ងៃទី ១០ ធ្នូ ភ្នំពេញ ប្រទេសកម្ពុជា

គេហទំព័រ(វ៉េបសាយ)របស់អង្គការ Open Development Cambodia ឆ្នាំ២០១៣

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០១ ច្បាប់ភូមិបាល (ឆ្នាំ២០០១) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០២ ច្បាប់ស្តីពីព្រៃឈើ (២០០២ក) ថ្ងៃទី ៣១ សីហា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០២ខ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣ របាយការណ៍គោលដៅសហស្សវត្សរ៍កម្ពុជា (២០០៣ខ) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣ក)ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ថ្ងៃទី២០ ធ្នូ ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣ អនុក្រឹត្យ លេខ ១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច (២០០៣គ) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៤ បទបញ្ជា ០១បប ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ថ្ងៃទី ០៩ មិថុនា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥ អនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ច ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥ អនុក្រឹត្យលេខ ៥៣អនក្រ.បក ស្តីពី នីតិវិធី ការបង្កើត ការចាត់ថ្នាក់ ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ថ្ងៃទី ០១ មករា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦ បទបញ្ជាលេខ ០១ បប ស្តីពី ការទប់ស្កាត់ការកាប់រានដីព្រៃ ឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ ថ្ងៃទី ១០ មីនា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦ អនុក្រឹត្យ ស្តីពីយថាប្រភេទ ផល-អនុផលព្រៃឈើ អនុញ្ញាតឱ្យនាំចេញ-នាំចូល (២០០៦ក) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧ សារាចរលេខ ០២ស្តីពី ការទន្ទ្រាន និងកាន់កាប់ដីរដ្ឋដោយ ខុសច្បាប់ (២០០៧ក) ថ្ងៃទី ២៦ កុម្ភៈ រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្តីពីការផ្តល់សម្បទាន ច្បាប់បកប្រែឡើងវិញដោយ នាយកដ្ឋានកិច្ចការនីតិកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CIB/CDC ថ្ងៃទី ២៦ សីហា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ អនុក្រឹត្យលេខ ១១៤៦ អនក្រ.តត ស្តីពី ការតែងតាំងសមាស ភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ថ្ងៃទី ១៦ តុលា ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ អនុក្រឹត្យ (លេខ ២៦ អនក្រ.បក) ស្តីពី វិធាននៃការផ្តល់សិទ្ធិ ប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ (២០០៨ គ) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦ខ) ភ្នំពេញ កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨យ) ភ្នំពេញ កម្ពុជា

